**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ដែនសមុទ្រកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **អានឧិត្យវណ្ណារ៉េត**

កញ្ញា **ម៉ៅ ស៊ីវហួង**

សាស្ត្រាចារ្យណែនាំ

លោក **អ៊ឹង រដ្ឋា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៧

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ


នាងខ្ញុំ **ម៉ៅ ស៊ីវហ្វេង** និងខ្ញុំបាទ **អាន ទិត្យវណ្ណារ៉េត** ជានិស្សិតថ្នាក់បរិញ្ញាបត្រជំនាញនីតិសាស្ត្រ ដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមថ្លែងកតញ្ញូតាធម៌ និងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតៈ

- សូមលើកអញ្ជលីឱនកាយវាចារចិត្តដល់ លោកឪពុក អ្នកម្តាយ ដែលបានផ្តល់កំណើតដល់យើងខ្ញុំ ចិញ្ចឹមបីបាច់ថែរក្សាផ្តល់នៅក្តីស្រលាញ់ប្រកបដោយព្រហ្មវិហារធម៌ អប់រំទូន្មានប្រៀនប្រដៅ និងទំនុកបម្រុងគ្រប់បែបយ៉ាងទាំងសម្ភារៈ ស្មារតី និងថវិការឲ្យកូនបានសិក្សាដល់ពេលនេះ។
- ឯកឧត្តម **លុយ ចន្ទណ្ណា** សាកលវិទ្យាធិការ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតឲ្យយើងខ្ញុំបានចូលសិក្សានៅក្នុងសាកលវិទ្យាល័យនេះ និងបង្កលក្ខណៈងាយស្រួលដល់ការសិក្សារបស់យើងខ្ញុំ។
- លោកសាស្ត្រចារ្យ **អ៊ឹុខ រដ្ឋា** ជាសាស្ត្រចារ្យណែនាំក្នុងការធ្វើសារណានេះ។ ពោលគឺ លោកសាស្ត្រចារ្យបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការណែនាំ កែលម្អ និងផ្តល់ជាដំបូន្មានជាច្រើនទាក់ទងនឹងការចងក្រងសារណានេះឡើង ទោះបីជាលោកមានភាពមមាញឹកយ៉ាងណាក៏ដោយ ក៏លោកបានជួយជ្រោមជ្រែងពួកយើងរហូតបានសម្រេចនូវសារណាមួយនេះ។
- សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតថែមទៀត ចំពោះអ្នកនិពន្ធ អ្នកប្រាជ្ញ ព្រមទាំង ទស្សនៈវិទូល្បីៗក្នុងលោក ដែលយើងខ្ញុំបានសិក្សាស្រាវជ្រាវពីស្នាដៃរបស់អស់លោក លោក ស្រីក្នុងការបំពេញកិច្ចការស្រាវជ្រាវកន្លងមក។

សូមមេត្តាទទួលនូវអំណរគុណដ៏ជ្រាលជ្រៅ និងមិនអាចបំភ្លេចបាននូវគុណឧបការដ៏ធំធេងអំពីយើងខ្ញុំ។

ជាទីបញ្ចប់យើងខ្ញុំសូមប្រសិទ្ធិពរជ័យ សិរីបវរជូនដល់លោកអ្នកមានគុណ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា និងសាស្ត្រចារ្យទាំងអស់សូមប្រកកបតែជោគជ័យគ្រប់ភាតកិច្ច និងសូមទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

សារណាបញ្ចប់ការសិក្សាស្តីពី " ដែនសមុទ្រកម្ពុជា " គឺ ជាស្នាដៃ និងសមិទ្ធិផលដែលបានខិតខំប្រឹងប្រែងនៅក្នុង  ការសិក្សា ស្រាវជ្រាវ និងចងក្រងរបស់ខ្ញុំទាំងពីររូប ក្រោមការណែនាំ របស់លោកស្រ្តាចារ្យ អ៊ឹង រដ្ឋា ។ សារណានេះ បានធ្វើការបកស្រាយឆ្លុះបញ្ចាំងយ៉ាងលម្អិតពីព័ត៌មាននៃប្រធានបទមួយនេះ។

ប្រធានបទដែលក្រុមយើងខ្ញុំបានធ្វើការស្រាវជ្រាវនេះគឺជាប្រធានបទដែលមានភាពស្មុគស្មាញ និងមានភាពពិបាកក្នុង ការស្រាវជាវ។ នេះជាមូលហេតុចម្បងដែរបានជម្រុញអោយក្រុមយើងខ្ញុំខិតខំពុះពារដើម្បីចងក្រងឯកសារនេះឡើង និងគួបផ្សំជាមួយការណែនាំរបស់លោកស្រ្តចារ្យ

អ៊ឹង រដ្ឋា ។ បន្ថែម លើសពីនេះទៅទៀត កិច្ចការសារជ្រាវនេះបានរៀបរាប់ និងពន្យល់យ៉ាងច្បាស់ពីការកំណត់ដែនសមុទ្រតាមច្បាប់អន្តរជាតិ និង ដែនសមុទ្ររបស់កម្ពុជា ។

ជាការពិតណាស់សារណាមួយនេះពិតជាប្រាកដជាមានកំហុសខុសឆ្គងកើតមានឡើងជាក់ជាពុំខាន។ដោយហេតុថាយើងខ្ញុំទាំង ពីរជួបការលំបាកនៅក្នុងការស្វែងរកឯកសារ និងព័ត៌មានដែលពាក់ព័នមួយចំនួន។ ហេតុដូចនេះហើយ ក្រុមយើងខ្ញុំសូមអភ័យទោសទុកជាមុនពីសំណាក់ សម្តេច ទ្រង់ ឯកឧត្តម

លោក លោកស្រី និង ប្រិយមិត្ត អ្នកអានទាំងអស់ប្រសិនបើខ្លឹមសារសារណារបស់យើងខ្ញុំមានការកំហុសនិងចន្លោះខ្វះខាតទាំងឡាយដែលកើតមានដោយអចតនា នៅក្នុងសារណានេះ។ ជាចុងក្រោយនេះយើងខ្ញុំមានសេចក្តីសោមន្សរីករាយជានិច្ច ដើម្បីទទួលយកនូវមតិរិះគុណកែលម្អរាល់កំហុស និងកង្វះខាតទាំងឡាយ។

# មាតិកា

**សេចក្តីផ្តើម ........................................................................ ១**

## ជំពូកទី១

## ទ្រឹស្តីទូទៅនៃការកំណត់ដែនសមុទ្រ

១.១ ដែនសមុទ្រតាមច្បាប់អន្តរជាតិ ........................................ ៣
១.១.១ ដែនទឹកផ្ទៃក្នុង ........................................ ៣
១.១.១.១ ដែនសមត្ថកិច្ចនាវា ........................................ ៤
១.១.១.២ ដែននាវាចម្បាំងបរទេស ........................................ ៤
១.១.១.៣ សិទ្ធិនាវាក្នុងកំពង់ផែ ........................................ ៥
១.១.២ ខ្សែបន្ទាត់មូលដ្ឋាន ........................................ ៥
១.១.២.១ ខ្សែបន្ទាត់មូលដ្ឋានធម្មតា ........................................ ៥
១.១.២.២ ខ្សែបន្ទាត់មូលដ្ឋានត្រង់ ........................................ ៦
១.១.៣ សមុទ្រដែនដី ........................................ ៦
១.១.៣.១ ការឆ្លងកាត់ស្លូតត្រង់ក្នុងសមុទ្រដែនដី ........................................ ៧
១.១.៣.២ សមត្ថកិច្ចរបស់ឆ្នេរសមុទ្រ ........................................ ៨
១.១.៣.៣ នាវាចម្បាំង និងនាវារដ្ឋមិនបម្រើពាណិជ្ជកម្ម ........................................ ៩
១.១.៤ តំបន់តជាប់ឆ្នេរសមុទ្រ ........................................ ៩
១.១.៥ តំបន់សេដ្ឋកិច្ចផ្តាច់មុខ ........................................ ១១
១.១.៥.១ សិទ្ធិរបស់រដ្ឋជាប់ឆ្នេរសមុទ្រក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ........................................ ១២
១.១.៥.២ សិទ្ធិរបស់រដ្ឋដទៃក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ........................................ ១២
១.១.៦ តំបន់ខ្ពង់រាបបាតសមុទ្រ ........................................ ១២
១.១.៦.១ សិទ្ធរបស់រដ្ឋជាប់ឆ្នេរសមុទ្រ ........................................ ១៣
១.១.៦.២ សិទ្ធិរបស់រដ្ឋទៃ ........................................ ១៤
១.១.៦.៣ ការកំណត់ព្រំដែនខ្ពង់រាបបាតសមុទ្រទាំងរដ្ឋជាប់ឆ្នេរ ........................................ ១៤
១.១.៧ នាយសមុទ្រ ........................................ ១៥
១.១.៧.១ សេរីភាពក្នុងការធ្វើនាវាចរណ៍ និងសិទ្ធិរបស់រដ្ឋម្ចាស់នាវា ........................................ ១៥
១.១.៧.២ យុត្តាធិការអន្តរជាតិ ........................................ ១៦
១.១.៧.៣ ការគោរពបទបញ្ជារបស់រដ្ឋជាប់ឆ្នេរ ........................................ ១៨
១.១.៨ តំបន់បាតសមុទ្រអន្តរជាតិ ........................................ ១៩

១.១.៨.១ បេតិកភណ្ឌរួមមនុស្សជាតិ ........ ១៩
១.១.៨.២ សិទ្ធិស្របច្បាប់របស់រដ្ឋជាប់ឆ្នេរ ........ ២០
១.១.៩ ច្រកសមុទ្រ ........ ២១
១.១.៩.១ សមត្ថកិច្ចរបស់រដ្ឋជាប់ឆ្នេរ ........ ២២
១.១.១០ រដ្ឋប្រជុំកោះ ........ ២២

# ជំពូកទី២

# ដែនសមុទ្រកម្ពុជា

២.១ ដែនសមុទ្រ ........ ២៣
២.១.១ ការទាមទារដែនសមុទ្រ ........ ២៣
២.១.១.១ ការទាមទារនៅឆ្នាំ១៩៥៧ ........ ២៣
២.១.១.២ ការទាមទារនៅក្នុងឆ្នាំ១៩៧២ ........ ២៥
២.១.១.៣ ការទាមទារនៅឆ្នាំ១៩៨២ ........ ២៦
២.១.២ តារាងអនុសញ្ញាព្រំដែនសមុទ្រ ........ ២៧
២.១.៣ បញ្ហាវិវាទព្រំដែន ........ ២៩
២.២ វិសាលភាពលំហមុទ្រកម្ពុជា ........ ៣១
២.២.១ តំបន់អធិបតេយ្យ ........ ៣១
២.២.១.១ តំបន់ដែនទឹកផ្ទៃក្នុង ........ ៣២
២.២.១.១.១ កំពង់ផែសមុទ្រកម្ពុជា ........ ៣២
២.២.១.២ តំបន់សមុទ្រដែនដី ........ ៣៣
២.២.២ តំបន់សិទ្ធិអធិបតេយ្យ ........ ៣៤
២.២.២.១ តំបន់តជាប់ និងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ........ ៣៤
២.២.២.២ តំបន់ខ្ពង់រាបបាតសមុទ្រ ........ ៣៥
២.២.៣ កោះរបស់ប្រទេសកម្ពុជា ........ ៣៦

# ជំពូកទី៣

# ធនធានសេដ្ឋកិច្ចសមុទ្រ

៣.១ ធនធានរ៉ែប្រេងកាត និងឧស្ម័ន ........ ៣៨
៣.១.១ តបន់រ៉ែពុំមានជម្លោះក្នុងប្រទេសកម្ពុជា ........ ៣៩
៣.១.២ តំបន់រ៉ែមានជម្លោះក្នុងប្រទេសកម្ពុជា ........ ៣៩
៣.២ ការនេសាទ ៤០

៣.៣ ធនធានធម្មជាតិផ្សេងៗ.................................................. ៤១
៣.៣.១ ដើមកោងកាង .................................................. ៤១
៣.៣.២ ផ្កាថ្ម និងថ្មប៉ប្រះទឹក.................................................. ៤២
៣.៣.៣ ស្មៅសមុទ្រ .................................................. ៤២
**សេចក្ដីសន្និដ្ឋាន .................................................. ៤៣**
**អនុសាសន៍.................................................. ៤៤**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

លំហសមុទ្របានគ្រប់ដណ្តប់លើផែនដីទាំងមូលមានប្រមាណប្រហែលជា ៧០% នៃផែនដី។ សមុទ្រជាលំហផ្ទៃទឹកប្រៃដែលសម្បូរដោយធនធានធម្មជាតិ និងរ៉ែធម្មជាតិជាច្រើន។ ដើម្បីឲ្យមាន ការអាស្រ័យផលត្រឹមត្រូវ គេត្រូវធ្វើការបែងចែកតំបន់សមុទ្រទៅតាមតំបន់ដើម្បី កាន់កាប់ក៏ដូចជាការគ្រប់គ្រង និងទទួលខុសត្រូវចំពោះដែនសមុទ្ររបស់ខ្លួនផងដែរ។ នៅក្នុង ឆ្នាំ១៩៨២ សន្ធិសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ដែលហៅថាសន្ធិសញ្ញា ស្តីពីច្បាប់សមុទ្របានចាប់ផ្តើមមានវត្តមាននៅក្នុងឆាកអន្តរជាតិរួមទាំងមានសមាជិកចំនួន១៦៨ និងមានប្រទេសជាហត្ថលេខីចំនួន ១៥៧។ វត្តមានរបស់សន្ធិសញ្ញាស្តីពីច្បាប់សមុទ្រនេះបាន បង្ហាញពីភាពល្អប្រសើរ និងមានលក្ខណៈច្បាស់លាស់ក្នុងការគ្រប់គ្រងដែនសមុទ្រ។ ការកំណត់តំបន់ដែនសមុទ្ររួមមានតំបន់ដែនទឹកផ្ទៃក្នុង ខ្សែបន្ទាត់មូលដ្ឋាន សមុទ្រដែនដី តំបន់តជាប់ តំបន់សេដ្ឋកិច្ចផ្តាច់មុខ ខ្ពង់រាបបាតសមុទ្រ នាយសមុទ្រ តំបន់បាតសមុទ្រអន្តរជាតិ ច្រកសមុទ្រ រដ្ឋប្រជុំកោះ ត្រូវបានទទួលស្គាល់ក្រោមច្បាប់អន្តរជាតិនៅ ក្នុងសន្ធិសញ្ញាស្តីពីច្បាប់សមុទ្រ។ ដោយស្របទៅតាមការចែងរបស់សន្ធិសញ្ញា យើងបានសង្កេត ឃើញមានការកំណត់ពីសិទ្ធិ និងសេរីភាពក្នុងការធ្វើនាវាចរណ៍ ការនេសាទ ការធ្វើអាជីវកម្ម ធនធានផ្សេងៗ និងកំណត់ពី យុត្តាធិការ ដែនសមត្ថកិច្ចរបស់បណ្តាលរដ្ឋជាប់ឆ្នេរ និងរដ្ឋបរទេស។ ប្រទេសកម្ពុជាជាប្រទេស មួយមានដែនសមុទ្រផ្ទាល់ខ្លួនដែលស្ថិតក្នុងឈូងសមុទ្រថៃ។ កម្ពុជាបានកំណត់តំបន់សមុទ្ររបស់ខ្លួន ឲ្យស្ថិតក្នុងតំបន់អធិបតេយ្យនិងក្រោម សិទ្ធិអធិបតេយ្យស្របតាមសន្ធិសញ្ញាស្តីពីច្បាប់សមុទ្រ។ ដោយប្រទេសកម្ពុជាបានស្ថិតនៅក្រោមអាណានិគមអស់រយៈពេល ៩០ឆ្នាំ អាណានិគមបារាំងបានបញ្ចប់បារាំងបានបន្សល់នូវភាពស្មុគស្មាញមួយចំនួនមកដល់ប្រទេសកម្ពុជាដូចជា បញ្ហា ព្រំដែនគោក ព្រំដែនសមុទ្រជាដើម។ ចាប់ពីឆ្នាំ១៩៥៧ មកប្រទេសកម្ពុជាបានចាប់ ផ្តើមធ្វើការទាម ទារយកដែនសមុទ្ររបស់ខ្លួនមកវិញដែលធ្វើឲ្យមានជម្លោះដែនសមុទ្រដល់បច្ចុប្បន្ននេះ។ អ្វីដែលសំខាន់ជាងនេះទៀត តំបន់ជម្លោះរវាងកម្ពុជា និងថៃជាកន្លែងដែលមានធនធាន ប្រេងកាត រ៉ែ ឧស្ម័ន និងធនធានផ្សេងៗជាច្រើនសន្ធឹកសន្ធាប់។ ជាក់ស្តែងតំបន់ឆ្នេរសមុទ្រកម្ពុជា ក៏សម្បូរដោយ ធនធានធម្មជាតិមានប្រព័ន្ធអេកូឡូស៊ី និងអំណោយ ផលលើការនេសាទទាំងអស់នេះ ជាធនធាន សេដ្ឋកិច្ចសមុទ្រដ៏សំខាន់។ ដូច្នេះតើការកំណត់ដែនសមុទ្រក្នុងសន្ធិសញ្ញាស្តីច្បាប់សមុទ្រអន្តរជាតិ មានលក្ខណដូចម្តេចខ្លះ? ហើយប្រទេសកម្ពុជាបានគោរពតាមការកំណត់ក្នុងសន្ធិសញ្ញានេះដែរឬទេ? ស្របតាមច្បាប់អន្តរជាតិ តើកម្ពុជាបានទាមទារអ្វីខ្លះនៅក្នុងជម្លោះព្រំដែនសមុទ្រជាមួយ ភាគីថៃ និងវៀតណាម។ ចំណែកក្នុងតំបន់សមុទ្រកម្ពុជាវិញ មានធនធានសេដ្ឋកិច្ចសមុទ្រអ្វីខ្លះ?

នៅក្នុងសារណានេះ យើងខ្ញុំនឹងធ្វើការបកស្រាយពីការកំណត់ដែនសមុទ្រតាមច្បាប់អន្តរជាតិ និងដែនសមុទ្រកម្ពុជារួមទាំងបកស្រាយពីតំបន់អធិបតេយ្យ ការទាមទារតំបន់សមុទ្រ និងធនធានសេដ្ឋកិច្ចសមុទ្រផងដែរ។ យើងខ្ញុំបានបែងចែកសារណានេះ ជាបីជំពូកដូចជា

ជំពូកទី១ ទ្រឹស្តីទូទៅនៃការកំណត់ដែនសមុទ្រ

ជំពូកទី២ ដែនសមុទ្រកម្ពុជា

ជំពូកទី៣ ធនធានសេដ្ឋកិច្ចសមុទ្រ

# ជំពូក១
# ទ្រឹស្តីទូទៅនៃការកំណត់ដែនសមុទ្រ

## ១.១ ដែនសមុទ្រតាមច្បាប់អន្តរជាតិ

លំហសមុទ្រមានទំហំធំល្វឹងល្វើយដែលគ្រប់ដណ្តប់លើភពផែនដីនេះ។ កាលពីរាប់រយឆ្នាំ មុន លំហសមុទ្រត្រូវបានប្រើប្រាស់ដោយសេរីរួមទាំង ការនេសាទ ការនាវាចរណ៍ ការដឹកជញ្ជូន និងការធ្វើអាជីវកម្មធនធានធម្មជាតិផ្សេងៗ។ បន្ទាប់ពីមានការចាប់អារម្មណ៍របស់រដ្ឋជាប់ឆ្នេរលើ សុវត្ថិភាពជាតិរបស់ប្រទេសខ្លួន និងការពារការធ្វើពាណិជ្ជកម្មនានាលើដែនសមុទ្ររដ្ឋទាំងអស់នៅ ជាប់ឆ្នេរមានគោលបំណងចង់ពង្រីកលំហសមុទ្រ និងកំណត់ព្រំដែនសមុទ្ររៀងៗខ្លួន។ នៅពេល បច្ចុប្បន្ន សន្ធិសញ្ញាអង្គការសហប្រជាជាតិស្តីពី ច្បាប់សមុទ្រ UNCLOS បានចែងពីការកំណត់ ព្រំដែនសមុទ្ររួមមានដែនទឹកផ្ទៃក្នុង សមុទ្រដែនដី តំបន់តជាប់ តំបន់សេដ្ឋកិច្ចផ្តាច់មុខ តំបន់ខ្ពង់រាបបាតសមុទ្រ តំបន់នាយសមុទ្រ និងសិទ្ធិសេរីភាពក្នុងការប្រើដែនសមត្ថកិច្ចក្នុងដែនសមុទ្រ។ តំបន់សមុទ្រទាំង នេះត្រូវបានវាស់ពីខ្សែបន្ទាត់មូលដ្ឋាន ដែលបានកំណត់ស្របតាមច្បាប់អន្តរជាតិតាមទំនៀមទំលាប់ ដែលបានឆ្លុះបញ្ចាំងក្នុងសន្ធិសញ្ញាស្តីពីច្បាប់សមុទ្រ។ ព្រំដែននៃតំបន់ដែនសមុទ្ររវាងប្រទេសឆ្នេរ សមុទ្របានបង្កើតឡើងតាមរយៈកិច្ចព្រមព្រៀងអន្តរជាតិធ្វើឡើងពីប្រទេសទាំងនោះ។

### ១.១.១ ដែនទឹកផ្ទៃក្នុង

ដែនទឹកផ្ទៃក្នុង ជាដែនទឹកដែលស្ថិតនៅក្នុងខ្សែបន្ទាត់មូលដ្ឋាន ហើយវានៅជាប់នឹងឆ្នេររបស់រដ្ឋ។ ដែនទឹកដែលរាប់បញ្ចូលជាដែនទឹកផ្ទៃក្នុងមានបាងសមុទ្រ កំពង់ផែ ចំណតកំពង់ផែ ច្រាំងចោទខ្លាំង ឆកដែលមានមុខកាត់មិនលើសពី ២៤ ម៉ាល(Mile) ឆកប្រវត្តិសាស្ត្រ សមុទ្របិទ ព្រមទាំងដីនៅក្រោមដី និងលំហអាកាសនៅពីលើផងដែរ។[1]

ដែនទឹកផ្ទៃក្នុងស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់រដ្ឋ និងមានអធិបតេយ្យពេញលេញ។ រដ្ឋជាប់ឆ្នេរមានសិទ្ធិទាំងស្រុងលើការគ្រប់គ្រងដែនទឹកនេះ ហើយមានសិទ្ធិធ្វើសកម្មភាពជាច្រើនដូចជាការធ្វើនាវាចរណ៍ ការនេសាទ និងការយកធនធានធម្មជាតិ។ ដូចច្នេះបានជានាវា បរទេសត្រូវតែគោរពទៅតាមច្បាប់របស់រដ្ឋជាប់ឆ្នេរ និងដែនយុត្តាធិការរបស់រដ្ឋជាប់ឆ្នេរសមុទ្រដែលទាក់ទង ទៅនឹងអំពើខុសច្បាប់ណាមួយដែលបានប្រព្រឹត្តិនៅលើនាវា និងនៅលើដីនៃដែនទឹកក្នុង។ ម៉្យាងទៀត នាវាបរទេសត្រូវសុំការអនុញ្ញាតពីរដ្ឋជាប់ឆ្នេរមុនធ្វើការឆ្លងកាត់តំបន់ដែនទឹកផ្ទៃក្នុង។ លើសពីនេះរដ្ឋជាប់ឆ្នេរមានអំណាចយុត្តាធិការទាំងផ្នែកព្រហ្មទណ្ឌ និងផ្នែករដ្ឋប្បវេណីទៅលើនាវាបរទេសដែធ្វើ ចរាចរណ៍ក្នុងតំបន់នេះ។ [2]

---

[1] លោកសាស្ត្រចារ្យ អ៊ឹង រដ្ឋា, *ច្បាប់សមុទ្រអន្តរជាតិ* (បោះពុម្ពលើកទី១), ៨៧។

[2] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា៨។

### ១.១.១.១ ដែនសមត្ថកិច្ចនាវា

នាវាបរទេសមិនមានសិទ្ធិសេរីភាពក្នុងការធ្វើនាវាចរណ៍ដោយសេរីក្នុង ដែនទឹកផ្ទៃក្នុងរបស់ រដ្ឋជាប់ឆ្នេរទេ។ ប៉ុន្តែអាចធ្វើការឆ្លងកាត់ដែនទឹកបានបើមានការអនុញ្ញាត។ ការនេសាទ ការយកប្រេង ឬការយកឧស្ម័នផ្សេងៗត្រូវបានហាមឃាត់ ប្រសិនបើគ្មានការអនុញ្ញាតពីម្ចាស់រដ្ឋជាប់ឆ្នេរ។ ដោយសារ តែមានការបញ្ហាចោទឡើងនៅពេលដែលនាវាបរទេសចូលក្នុងដែនទឹកផ្ទៃក្នុងដូចជា កំពង់ផែ និងការ ស្នាក់នៅរបស់នាវានៅក្នុងដែនទឹកនេះបានជាគេអនុវត្តវិធានខុសគ្នារវាងនាវារបស់រដ្ឋ និងនាវាឯកជន។

នាវាឯកជន ឬនាវារដ្ឋដែលបម្រើពាណិជ្ជកម្ម មានលក្ខណៈជាការដឹកទំនិញរដ្ឋទៅលក់បរទេស ឬជួលនាវាឲ្យឯកជន អាចមានសេរីភាពចេញចូលកំពង់ផែសមុទ្របាន។ ប៉ុន្តែករណីដើម្បីការពារសុខុមាលភាព និងរក្សាសណ្តាប់ធ្នាប់សាធារណរបស់ខ្លួន រដ្ឋជាប់ឆ្នេរអាចហាមមិនឲ្យចូលបាន។ លើកលែងតែនាវាស្ថិតក្នុងស្ថានភាពស្លន់ស្លោ រដ្ឋជាប់ឆ្នេរត្រូវអនុញ្ញាតឲ្យនាវានោះចូល។ លើសពីនេះ នាវាបរទេសដែលស្នាក់នៅក្នុងដែនទឹកនេះត្រូវតែស្ថិតក្រោមសមត្ថកិច្ចដែនដី និងគោរពបទបញ្ញត្តរបស់ រដ្ឋជាប់ឆ្នេរលើការធ្វើនាវាចរណ៍ សារពើព័ន្ធ អនាម័យ ការគ្រប់គ្រងបច្ចេកទេស ។

ប្រសិនបើសមាជិកនាវា ឬសមាជិកនាវិកបានបទល្មើសព្រហ្មទណ្ឌណាមួយក្នុងនាវារដ្ឋជាប់ ឆ្នេរមិនមានសមត្ថកិច្ចទេ។ រដ្ឋជាប់ឆ្នេរអាចមានសមត្ថកិច្ចលុះត្រាតែរំខានដល់សណ្តាប់ធ្នាប់សាធារណ ឬបទល្មើសប្រព្រឹត្តលើនាវាបង្កពីអ្នកដំណើរ (ចារី ឬជនរងគ្រោះ) ឬអាជ្ញាធរនាវាស្នើសុំឲ្យរដ្ឋជាប់ ឆ្នេរធ្វើអន្តរាគមន៍។[3]

### ១.១.១.២ ដែននាវាចម្បាំងបរទេស

នាវាចម្បាំង នាវាស៊ីវិលរបស់គយ ឬនាវារបស់ក្រសួងស៊ីវិលជានាវារដ្ឋដែលមិនបម្រើពាណិជ្ជ-កម្មត្រូវគោរពលក្ខខណ្ឌតឹងរឹង។ ប៉ុន្តែម្ចាស់នាវានៅតែមានសមត្ថកិច្ចរបស់ខ្លួនដដែលនៅពេលស្នាក់នៅក្នុងដែនទឹកផ្ទៃក្នុងនេះ និងរួចផុតពីយុត្តាធិការស៊ីវិលរបស់រដ្ឋជាប់ឆ្នេរដោយសារតែមានគោលការណ៍អភ័យឯកសិទ្ធិអធិបតេយ្យ។ ទោះបីជាយ៉ាងណា រដ្ឋជាប់ឆ្នេរក៏មាននូវឆន្ទានុសិទ្ធិក្នុងការសម្រេចឲ្យចូល ឬមិនឲ្យចូល[4]ក្នុងករណីការពារខ្លួននៅពេលនាវាមិនគោរពច្បាប់របស់រដ្ឋជាប់ឆ្នេរ។ តាម មាត្រា ១៣ នៃសន្ធិសញ្ញាទីក្រុងហ្សឺណែវ ១៩២៣ នាវាចម្បាំងចូលកំពង់ផែត្រូវប្រាប់រដ្ឋជាប់ឆ្នេរឲ្យដឹងមុន ប៉ុន្តែក្នុងពេលសង្គ្រាមនាវាចម្បាំងត្រូវតែសុំការអនុញ្ញាតជានិច្ច។

---

[3] Anne Bardin, “Coastal States’ Jurisdiction over foreign vessels,” ( Peace International law review, 2002), 4-5។
http://www.google.com/url?sa=t&rct=j&q=&esrc=s&source=web&cd=1&ved=0ahUKEwjSqf_0tJXVAh-WCjLwKHeDKD1EQFggnMAA&url=http%3A%2F%2Fdigitalcommons.pace.edu%2Fcgi%2Fviewcontent.cgi%3Farti-cle%3D1188%26context%3Dpilr&usg=AFQjCNFniWROJ48lcHAXztiPYZHhwVXOnQ

[4] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា៣០។

រដ្ឋម្ចាស់នាវាមានសមត្ថកិច្ចលើនាវារបស់ខ្លួន ហើយរដ្ឋជាប់ឆ្នេរមិនមានសិទ្ធិបង្ខំ (ចាប់ខ្លួន ឬឆែកឆេរ)ណាមួយទៅលើនាវាបានទេ។ ប្រសិនបើមានបទល្មើសប្រព្រឹត្តនៅក្នុងនាវាដោយសមាជិកនាវិករដ្ឋជាប់ឆ្នេរមិនមានសមត្ថកិច្ចទេ ប៉ុន្តែបើសមាជិកនាវិកប្រព្រឹត្តនៅក្រៅនាវា តុលាការរបស់រដ្ឋជាប់ឆ្នេរមានសមត្ថកិច្ចលើករណីនេះ។

#### **១.១.១.៣ សិទ្ធិនាវាក្នុងកំពង់ផែ**

កំពង់ផែត្រូវបានដាក់បញ្ចូលក្នុងដែនទឹកផ្ទៃក្នុង។ កំពង់ផែសំដៅលើកន្លែងដែលរៀបចំសម្រាប់នាវាផ្ទុក ឬដាក់អ្នកដំណើរនិងទំនិញ។ វានៅជាប់ឆ្នេរសមុទ្រមានលក្ខណៈអចិន្ត្រៃយ៍ដែលជាផ្នែកសំខាន់នៃប្រព័ន្ធកំពង់ផែតូចៗ។ ផ្លូវចំណតនាវាជាធម្មតាប្រើសម្រាប់ផ្ទុក ផ្ទេរទំនិញ និងបោះយុថ្កានាវាក្នុងស-មុទ្រដែនដី។ ចំពោះសំណង់ដែលនៅក្បែរឆ្នេរកោះសិប្បនិម្មិតមិនមានលក្ខណៈអចិន្ត្រៃយ៍មិនរាប់បញ្ចូលជាផែទេ។[5]

នៅពេលនាវាចង់ធ្វើដំណើរចូលកំពង់ផែដែលនៅក្នុងដែនទឹកផ្ទៃក្នុង នាវាបរទេសត្រូវគោរពច្បាប់ជាតិរបស់រដ្ឋជាប់ឆ្នេរ ហើយរដ្ឋជាប់ឆ្នេរមានសិទ្ធិអាចបណ្តេញចេញពីកំពង់ផែ ឬបិទកំពង់ផែ មិនឲ្យ ចូលបើមានការប៉ះពាល់ដល់សុវត្ថិភាពនៃការធ្វើនាវាចរណ៍ សណ្តាប់ធ្នាប់ សន្តិសុខ បរិស្ថានឆ្នេរសមុទ្រ និងវត្តមាននៃការដំឡើងរបស់យោធានៅកំពង់ផែ (សិទ្ធិចូលចតនៅកំពង់ផែមិនច្បាស់ក្នុងសន្ធិសញ្ញា វាអាចអាស្រ័យលើកិច្ចព្រមព្រៀងមិត្តភាព ពាណិជ្ជកម្ម ឬអាចកំណត់ដោយរដ្ឋកំពង់ផែខ្លួនឯង)។ ក្នុងករណីមានបទល្មើសព្រហ្មទណ្ឌកើតឡើងក្នុងនាវានៅពេលនាវាបរទេសចូលចត នៅកំពង់ផែរបស់រដ្ឋជាប់ឆ្នេរសមុទ្រ។ រដ្ឋជាប់ឆ្នេរសមុទ្រមានសមត្ថកិច្ចអាចឃាត់នាវា ឡើងនាវាឃាត់មនុស្សក្នុងនាវា និងនាំខ្លួនទៅតុលាការបាន។[6]

### **១.១.២ ខ្សែបន្ទាត់មូលដ្ឋាន**

ខ្សែបន្ទាត់មូលដ្ឋានជាខ្សែបន្ទាត់ប្រើសម្រាប់វាស់ចម្ងាយសមុទ្រដែនដី។ ខ្សែបន្ទាត់នេះដែលគេប្រើប្រាស់សម្រាប់បែងចែករវាងដែនគោក និងសមុទ្រដែនដី។ ជាទូទៅខ្សែបន្ទាត់មូលដ្ឋានត្រូវបានវាស់តាមបន្ទាត់ខ្សែទឹកនាចនៅតាមបណ្តោយឆ្នេរ។ រដ្ឋនីមួយៗអាចគូសចម្ងាយខ្សែបន្ទាត់មូលដ្ឋានរបស់ខ្លួនតាម ២របៀប គឺខ្សែបន្ទាត់មូលដ្ឋានធម្មតា និងខ្សែបន្ទាត់មូលដ្ឋានត្រង់។

[5] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា ១១, ១២។

[6] Anne Bardin, "Coastal States' Jurisdiction over foreign vessels,"( Peace International law review, 2002), 6។

**១.១.២.១ ខ្សែបន្ទាត់មូលដ្ឋានធម្មតា**

ខ្សែបន្ទាត់មូលដ្ឋានធម្មតាជាខ្សែបន្ទាត់ទឹកនាចអស់កម្លាំងបំផុតតាមបណ្តោយឆ្នេរ ដោយស្រប តាមមាត្រា៥ នៃសន្ធិសញ្ញាស្តីពីច្បាប់សមុទ្រឆ្នាំ១៩៨២ UNCLOS។ ខ្សែបន្ទាត់មូលដ្ឋានធម្មតាជាខ្សែ បន្ទាត់សម្រាប់វាស់ចម្ងាយសមុទ្រដែនដី។ ចំពោះទឹកនាចអស់បំផុតត្រូវមានចម្ងាយពីគោកក្រោម ចម្ងាយ ១២ម៉ាល(Mile) ប្រសិនបើលើសពីចម្ងាយនេះវាមិនមែនជាខ្សែបន្ទាត់មូលដ្ឋានធម្មតានោះទេ។[7] ការគូសខ្សែបន្ទាត់មូលដ្ឋានធម្មតានេះ គឺអាចធ្វើបានសម្រាប់តែឆ្នេរដែលមិនមានជម្រៅជ្រៅគ្មានលក្ខ-ណៈស្មុគស្មាញងាយស្រួលគូសហើយត្រូតលើឆ្នេរតែមួយ។

**១.១.២.២ ខ្សែបន្ទាត់មូលដ្ឋានត្រង់**

ខ្សែបន្ទាត់មូលដ្ឋានត្រង់ជាខ្សែបន្ទាត់ដែលបានភ្ជាប់ពីចំណុចមួយទៅកាន់ចំណុចមួយ។[8] ការ គូសខ្សែបន្ទាត់មូលដ្ឋានត្រង់នេះមានលក្ខណៈស្មុគស្មាញខ្លាំង តួរយ៉ាងដូចជាឆ្នេរមានស្ថានភាពក្រហូង ខ្លាំង មានផ្ទាំងថ្មធំៗ ឬកោះតូចៗ ជាច្រើនតាមបណ្តោយឆ្នេរត្រង់ពាមដែលបានហូរចាក់ទៅក្នុងសមុទ្រ ឬពីមុខឆក ដែលមានប្រវែងមុខកាត់ជាពាក់កណ្តាលរង្វង់មិនលើសពី ២៤ម៉ាល(Mile) ឬពីមុខឆកប្រវត្តិ សាស្ត្រ ដោយស្របតាមមាត្រា១០.៤នៃ UNCLOS។

- មាត់ទន្លេរ Mouth of Rivers : ជាចំនុចប្រសព្វនៅពេលទន្លេរហូរចូលចាក់ទៅសមុទ្រ។ បន្ទាត់មូលដ្ឋាន និងគូសកាត់មាត់ទន្លេររវាងចំណុចទឹកនាចនៃច្រាំងទន្លេ។[9]
- ឆកសមុទ្រ Bay : ជាកន្លែងផតដែលផ្ទៃរបស់វាធំជាងផ្ទៃរបស់កន្លះរង្វង់ដែលត្រូវបាន គូសកាត់តាមមាត់របស់កន្លែងផតនោះ។[10]
- ឆ្នេរផតជ្រៅ Deeply Indented Coastline : ជាផ្នែកនៃទឹកសមុទ្រដែលផតជ្រៅចូលទៅ កាន់ដីគោកតាមបណ្តោយឆ្នេរ។
- ជាទូទៅខ្សែបន្ទាត់មូលដ្ឋានត្រូវបានគេយកមកប្រើប្រាស់ ទៅតាមកន្លែងណាដែលមាន ឆ្នេរសមុទ្រជ្រៅហើយមានលក្ខណៈស្មុគស្មាញ។

**១.១.៣ សមុទ្រដែនដី**

សមុទ្រដែនដីជាលំហសមុទ្រដែលស្ថិតនៅចន្លោះរវាងដែនដីគោក ត្រឹមខ្សែបន្ទាត់មូលដ្ឋានមក ខាងដែនដីសមុទ្រ និងនាយសមុទ្រ (សមុទ្រអន្តរជាតិ)។ យោងតាមមាត្រា៣ នៃUNCLOS ការកំណត់

---

[7] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា១៣។

[8] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា៧។

[9] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា៩។

[10] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា១០(២)។

ផ្ទៃសមុទ្រដែនដីមិនឲ្យលើសពី១២ ម៉ែល (Mile) ដែលបានវាស់ចេញពីខ្សែបន្ទាត់មូលដ្ឋាន។ រាល់ការហោះហើរខាងលើសមុទ្រដែនដីក្តីក៏ត្រូវសុំអនុញ្ញាតពីរដ្ឋដែលជាម្ចាស់ឆ្នេរសមុទ្រផងដែរ។ មិនត្រឹមតែប៉ុណ្ណោះ ការឆ្លងកាត់នាវាបរទេសក្នុងតំបន់នេះនូវមានកំរិតមិនអាចធ្វើអ្វីបានដោយសេរី ភាពទេ។ រដ្ឋជាប់ឆ្នេរត្រូវទទួលបានអធិបតេយ្យភាពទៅលើដែនទឹក លំហអាកាស បាតសមុទ្រ និងដែនក្រោមបាតសមុទ្រ[11]។ រដ្ឋជាប់ឆ្នេរមានសិទ្ធិអនុវត្តសមត្ថកិច្ចផ្តាច់មុខចំពោះ ការនេសាទ អាជីវកម្មធនធានរ៉ែ នាវាចរណ៍ គយ សុខភាពសាធារណៈ ការពារបរិស្ថាន និងសន្តិសុខ។

### ១.១.៣.១ ការឆ្លងកាត់ស្លូតត្រង់ក្នុងសមុទ្រដែនដី

នាវារបស់រដ្ឋទាំងអស់ទោះមិនមែនជារបស់រដ្ឋជាប់ឆ្នេរ ឬរដ្ឋជាប់ឆ្នេរសមុទ្រមានសិទ្ធិឆ្លងកាត់ដោយស្លូតត្រង់ក្នុងសមុទ្រដែនដី។[12] ការឆ្លងកាត់ដោយស្លូតត្រង់នេះមានន័យថាការធ្វើចរាចណ៍ឆ្លងកាត់ដោយ មិនបង្ករគ្រោះថ្នាក់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ឬសុវត្ថិភាពរបស់រដ្ឋជាប់ឆ្នេរ។ សកម្មភាពមួយចំនួនដែលចាត់ទុកថាបង្កគ្រោះថ្នាក់ និងត្រូវហាមឃាត់៖

- ការគំរាមគំហែងប្រើប្រាស់កម្លាំងប៉ះពាល់ដល់សន្តិភាព សណ្តាប់ធ្នាប់ សន្តិ-សុខ
- សមយុទ្ធយោធា ឬប្រើប្រាស់សព្វាវុធ ដោយគ្មានការអនុញ្ញាត
- ការធ្វើសកម្មភាពរំលោភគោលការណ៍ច្បាប់អន្តរជាតិដែលចែងក្នុងសន្និសញ្ញាអង្គការសហប្រជាជាតិ
- ការហោះឡើង ឬចុះចតលើនាវា
- ការបំពុលបរិស្ថានធ្ងន់ធ្ងរ
- ការនេសាទ ស្រាវជ្រាវ វាស់ស្ទង់
- ការធ្វើសកម្មភាពដទៃទៀតដែលប៉ះពាល់មិនផ្ទាល់នៅពេលឆ្លងកាត់[13]។

នៅពេលឆ្លងកាត់សមុទ្រដែនដីនាវាមុជទឹក និងជលយាន្តក្រោមទឹក ដែលធ្វើនាវាចរណ៍ត្រូវងើបឡើងលើផ្ទៃទឹក និងបង្ហាញទង់ជាតិរបស់ខ្លួន (មាត្រា២០ UNCLOS)។ ចំពោះនាវាបរទេសដែលប្រើដោយថាមពលនុយក្លេអ៊ែរ ឬផ្ទុកសារធាតុបង្កគ្រោះថ្នាក់ ឬសារធាតុពុល ហើយកំពុងអនុវត្តសិទ្ធិកាន់កាប់ដោយស្លូតត្រង់ត្រូវមានឯកសារភ្ជាប់ជាមួយ និងត្រូវប្រុងប្រយ័ត្នជាពិសេសតាមកិច្ចព្រមព្រៀងអន្តរជាតិ[14]។

---

[11] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា២,៣។

[12] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា១៧។

[13] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា១៧-១៩។

[14] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា ២៣។

រដ្ឋជាប់ឆ្នេរសមុទ្រមិនត្រូវបដិសេធ ឬរារាំងការឆ្លងកាត់ដោយស្លូតត្រង់របស់នាវាក្នុងសមុទ្រដែនដីឡើយ។ រដ្ឋជាប់ឆ្នេរមិនអាចយកថ្លៃពន្ធពីនាវាបរទេសលើការឆ្លងកាត់សមុទ្រដែនដីឡើយ លើកលែងតែមានការផ្តល់សេវា និងមិនអាចរើសអើងចំពោះនាវា (សញ្ជាតិ ប្រភពដំណើរ ឬគោលដៅរបស់នាវា)។ ដោយឡែកចំពោះរាល់ការឆ្លងកាត់ដោយស្លូតត្រង់នេះមិនបានតម្រូវឲ្យមាន ការជូនដំណឹង ជាមុនឡើយ ប៉ុន្តែអំឡុងពេលកំពុងធ្វើដំណើរត្រូវគោរពច្បាប់ និងបទបញ្ញត្តិរបស់ រដ្ឋជាប់ឆ្នេរសមុទ្រ និងបទបញ្ញត្តិអន្តរជាតិស្តីពីការប៉ះទង្គិចគ្នានៅសមុទ្រ។[15]

រដ្ឋជាប់ឆ្នេរអាចមិនឲ្យមានការឆ្លងកាត់ដោយស្លូតត្រង់ក្នុងដែនដីខ្លួនបាន ក្នុងករណីនាវាបន្តចូលក្នុងដែនទឹកក្នុង ចតដាក់ឧបករណ៍របស់កំពង់ផែក្រៅដែនទឹកខ្លួន។ ដើម្បីការការពារសន្តិសុខ ឬមានការសមយុទ្ធសព្វាវុធ រដ្ឋជាប់ឆ្នេរសមុទ្រអាចព្យួរបណ្តោះអាសន្ននូវការឆ្លងកាត់បាន (ការព្យួរចូលជាធរមានលុះត្រាតែមានការប្រកាសជាសាធារណៈប៉ុណ្ណោះ)។[16]

ការឆ្លងកាត់មានន័យថា ការធ្វើនាវាចរណ៍ដោយមិនចូលក្នុងដែនទឹកក្នុង ឬចូលចតចំណត ឬកំពង់ផែនៅក្រៅដែនទឹកក្នុង។ នាវាត្រូវធ្វើនាវាចរណ៍ជាលក្ខណៈបន្តដំណើរមិនអាចឈប់នាវា ឬបោះយុថ្កាបានឡើយ។ ក្នុងករណីដែលនាវាអាចឈប់ ឬបោះយុថ្កាបានលុះត្រាតែជួបឧប្បត្តិហេតុដូចជាប្រធានសក្តិ ឬជួបគ្រោះមហន្តរាយ គ្រោះថ្នាក់ ឬឈប់ជួយសង្គ្រោះ (មនុស្ស នាវា យន្តហោះស្ថិតក្នុងគ្រោះថ្នាក់) ផ្អែកតាមមាត្រា ១៨ នៃUNCLOS។

ការឆ្លងកាត់ និងការឆ្លងកាត់ដោយស្លូតត្រង់មានលក្ខណៈផ្សេងគ្នាមិនដូចគ្នាទេ។ នាវា និងយន្តហោះរបស់ប្រទេសទាំងអស់មានសិទ្ធិឆ្លងកាត់នៅក្នុងច្រកសមុទ្រ ដែលនាវាធ្វើចរាចរណ៍ដោយសេរី (high sea or EEZ)។ ចំពោះការឆ្លងកាត់នេះ ទទួលស្គាល់សេរីភាពហោះហើរយន្តហោះរដ្ឋនានា ដោយមិនបាច់សុំច្បាប់ពីរដ្ឋម្ចាស់ច្រកសមុទ្រដើម្បីឆ្លងកាត់។ នាវាមុជទឹកអាចបើកបរនៅក្រោមទឹកដោយមិនចាំបាច់ងើបលើផ្ទៃទឹកទេ។ ម្យ៉ាងវិញទៀតការឆ្លងកាត់នេះ រដ្ឋជាប់ឆ្នេរមិនអាចព្យួរសិទ្ធិឆ្លងកាត់របស់នាវារដ្ឋនានាបានឡើយ។

**១.១.៣.២ សមត្ថកិច្ចរបស់ឆ្នេរសមុទ្រ**

រដ្ឋឆ្នេរសមុទ្រមានយុត្តាធិការព្រហ្មទណ្ឌ តែលើនាវារដ្ឋាភិបាលដែលបម្រើពាណិជ្ជកម្មផ្អែកតាមមាត្រា២៧ UNCLOS ប៉ុន្តែមិនមានយុត្តាធិការព្រហ្មទណ្ឌលើនាវាបរទេសកំពុងឆ្លងកាត់សមុទ្រដែនដីដូចជា មិនអាចចាប់ខ្លួនជនណាម្នាក់ ការស៊ើបអង្កេតបទល្មើសលើនាវាកំពុងឆ្លងកាត់បានទេ។ ប៉ុន្តែមានករណីខ្លះដែលរដ្ឋជាប់ឆ្នេរអាចអនុវត្តយុត្តាធិការព្រហ្មទណ្ឌលើនាវានោះបានរួមមាន៖

[15] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា២១។

[16] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា២៥។

- បើសិនបទល្មើសនោះប្រព្រឹត្តនៅលើនាវាអំឡុងពេលនៅក្នុងសមុទ្រដែនដី ហើយបទល្មើសនោះបង្កឲ្យមានផលប៉ះពាល់ដល់រដ្ឋជាប់ឆ្នេរ និងរំខានដល់សន្តិសុខសណ្តាប់ធ្នាប់របស់ រដ្ឋជាប់ឆ្នេរ ។
- បើសិនម្ចាស់នាវា ឬភ្នាក់ងារការទូតនៃរដ្ឋម្ចាស់នាវាបានស្នើសុំជំនួយពីអាជ្ញាធរមូលដ្ឋាន
- បើសិនបទល្មើសជាការជួញគ្រឿងញៀនខុសច្បាប់ ឬសារធាតុគីមី ( ត្រូវស្នើសុំទៅមន្ត្រីការទូត ឬមន្ត្រីកុងស៊ុលរបស់រដ្ឋម្ចាស់នាវាសិន ឬធ្វើសកម្មភាព និងជូនដំណឹងក្នុងពេលតែមួយក៏បាន)។

ចំពោះករណីរដ្ឋប្បវេណីដែលទាក់ទង់នឹងមនុស្សណាម្នាក់លើនាវារដ្ឋជាប់ឆ្នេរមិនអាចបញ្ឈប់ ឬចាប់ឃាត់នាវាបរទេសដែលឆ្លងកាត់បានទេ ប៉ុន្តែមានវិធានការឃាត់បណ្តោះអាសន្នដើម្បីអនុវត្តសាលក្រម ឬដីកាក្នុងគោលបំណងឲ្យគោរពកាតព្វកិច្ចសន្យា និងការទទួលខុសត្រូវ។[17]

### ១.១.៣.៣ នាវាចម្បាំង និងនាវារដ្ឋមិនបម្រើពាណិជ្ជកម្ម

នាវាចម្បាំងសំដៅលើនាវាដែលជាកម្មសិទ្ធិរបស់កម្លាំងប្រដាប់អាវុធរបស់រដ្ឋ ហើយស្ថិតក្រោមការបញ្ជារបស់នាយទាហានជើងទឹក រួមទាំងនាវាមានសញ្ជាតិក្នុងបញ្ជីកងប្រដាប់អាវុធ។ ប្រសិនបើរដ្ឋឆ្នេរសមុទ្រទទួលការខូចខាត ឬប៉ះពាល់ឆ្នេរសមុទ្ររបស់ខ្លួនដោយសារនាវាទាំងនេះ រដ្ឋម្ចាស់នាវាត្រូវតែទទួលខុសត្រូវ។ បន្ថែមពីនេះក្នុងពេលនាវានេះមិនគោរពច្បាប់ជាតិ ឬបទបញ្ជាដែលបានកំណត់ពី ការឆ្លងកាត់សមុទ្រដែនដី រដ្ឋឆ្នេរសមុទ្រអាចបញ្ជាឲ្យចេញពីដែនសមុទ្រខ្លួនភ្លាម។[18] ផ្អែកតាម មាត្រា៣២ នៃUNCLOS នាវាចម្បាំងបរទេសមានអភ័យឯកសិទ្ធិ ដែលជាសិទ្ធិពិសេសក្នុងការរួច ផុតពីការវិនិច្ឆ័យ ឬអនុវត្តសាលក្រមរដ្ឋផ្សេងបានទេ។ ដូច្នេះបានជារដ្ឋជាប់ឆ្នេរសមុទ្រមិនមានសមត្ថកិច្ច ចំពោះបទល្មើលដែលប្រព្រឹត្តបានឡើយ។

សមុទ្រដែនដីរវាងរដ្ឋទល់មុខគ្នា ឬរដ្ឋជាប់គ្នាត្រូវបានកំណត់តាមវិធី១ ក្នុងចំណោមវិធី៣យ៉ាង៖

- តាមរយៈការព្រមព្រៀងរបស់រដ្ឋ
- តាមខ្សែបន្ទាត់មេដ្យាន (ចំណុចកណ្តាល) គឺចម្ងាយស្មើគ្នាពីចំណុចជិតបំផុតនៅលើខ្សែបន្ទាត់មូលដ្ឋានដែលវាស់ចេញពីខ្សែបន្ទាត់នេះ
- តាមខ្សែបន្ទាត់មួយផ្សេងទៀតដែលជាកម្មសិទ្ធិប្រវត្តិសាស្ត្រឬកាលៈទេសៈពិសេសផ្សេងទៀត។[19]

---

[17] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា២៨។

[18] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា២៩-៣១។

[19] លោក នួន សុធិមន្ត, *នីតិសមុទ្រ សមុទ្រលំហអាកាស និងខ្តង់រាបបាតសមុទ្រ វិធីកំណត់ព្រំដែនសមុទ្រគ្រប់គ្រងធនធានសមុទ្រ នាវាចរណ៍ បរិស្ថាន ដំណោះស្រាយវិវាទសមុទ្រ*, ១៣២។

### ១.១.៤ តំបន់តជាប់ឆ្នេរសមុទ្រ

គោលការណ៍នៃតំបន់តជាប់មានប្រភពយូរយារមកហើយ ហើយវាមានការកត់សម្គាល់ថាតំបន់តជាប់ជាផ្នែកមួយនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខ EEZ នាយសមុទ្រដែលស្ថិតក្នុងគោលការណ៍សេរីភាពនៃការធ្វើនាវាចរណ៍។ រដ្ឋជាប់ឆ្នេរមិនមានយុត្តាធិការ ឬសមត្ថកិច្ចអធិបតេយ្យពេញលេញលើតំបន់តជាប់ក្នុងនាមជារដ្ឋជាប់ឆ្នេរនោះទេ។ ប៉ុន្តែមានសមត្ថកិច្ចពិសេសដែរយោងតាមមាត្រា៣៣ នៃUNCLOS។[20]

ស្របតាមមាត្រា៣៣ នៃUNCLOS៖ តំបន់មួយតជាប់សមុទ្រដែនដីហៅថា តំបន់តជាប់រដ្ឋម្ចាស់ឆ្នេរសមុទ្រអាចគ្រប់គ្រងជាចាំបាច់ដើម្បី៖

- ការពារបទល្មើសបំពានច្បាប់ និងបទបញ្ញត្តស្តីពី គយ ពន្ធដារ សុខមាលភាព អន្តោប្រវេសន៍ដែលកើតឡើងលើទឹកដី ឬសមុទ្រដែនដីរបស់ខ្លួន។
- ការដាក់ទោសលើការរំលោភច្បាប់ដែលកើតឡើងក្នុងដែនដី ឬសមុទ្រដែនដី។

តំបន់តជាប់នេះបានកំណត់ចម្ងាយ២៤ ម៉ាល (Miles) ពីខ្សែបន្ទាត់មូលដ្ឋាន ហើយវាមិនអាចពង្រីកលើសពីនេះបានទេ។ ជាទូទៅរដ្ឋជាប់ឆ្នេរសមុទ្រមានសិទ្ធិពេញលេញក្នុងការធ្វើសកម្មភាពមួយចំនួនដូចជាការសាងសង់កោះសិប្បនិម្មិត ការនេសាទ ការស្រាវជ្រាវវិទ្យាសាស្ត្រ ការយករ៉ែធម្មជាតិ ឬឧស្ម័ន។

តារាងខាងក្រោមនេះបានបង្ហាញពីសកម្មភាព និងសិទ្ធិរបស់រដ្ឋដទៃក្នុងតំបន់តភ្ជាប់៖[21]

| សកម្មភាព | សិទ្ធិរបស់រដ្ឋដទៃក្នុងតំបន់តភ្ជាប់ |
|---|---|
| នាវាចរណ៍ | – មានសិទ្ធិពេញលេញក្នុងការធ្វើនាវាចរណ៍ប្រសិនបើស្របតាមសន្និសញ្ញាម៉ុងតេហ្គូបៃ មាត្រា (៥៨.១ ៥៨.២ ៨៧ ៨៨-១១៥)<br>– ការដាក់កំហិតដោយមាត្រា៣៣ ការឆែកឆេរដោយរដ្ឋឆ្នេរសមុទ្រដើម្បីបង្ការ និងដាក់ទោសការដែលរំលោភច្បាប់របស់រដ្ឋឆ្នេរសមុទ្រ<br>– ការដកស្រង់វត្ថុប្រវត្តិសាស្ត្រ និងវត្ថុបុរាណដោយទទួលការព្រមព្រៀងពីរដ្ឋឆ្នេរសមុទ្រ។ |

[20] Anne Bardin,” Coastal States’ Jurisdiction over foreign vessels,” ( Peace International law review, 2002),13។

[21] Arnd Bernaert, Bernaerts’ *Guide to the 1982 United Nation Convention on the Law of the Sea* (Trafford Canada 2005), 30-31។ http://www.bernaert-sealaw.com/_A/index.html

| | |
|---|---|
| ការហោះហើរ | – មានសិទ្ធិពេញលេញក្នុងការហោះហើរខាងលើ។ |
| ការនេសាទ | – គ្មានសិទ្ធិឡើយបន្ទាប់ពីបង្កើតតំបន់សេដ្ឋកិច្ចផ្តាច់មុខ។ |
| ការស្រាវជ្រាវវិទ្យាសាស្រ្ត | – អាចធ្វើបានលុះត្រាតែមានការព្រមព្រៀងពីរដ្ឋឆ្នេរសមុទ្រ នៅ ពេលតំបន់សេដ្ឋកិច្ចផ្តាច់មុខបានបង្កើត។ |
| ការដាក់ខ្សែកាប | – មានសិទ្ធិពេញលេញ (មាត្រា ៥៨ ៧៩) ត្រូវមានការព្រមព្រៀង ពីរដ្ឋឆ្នេរសមុទ្រសម្រាប់ការរៀបចំផ្លូវសម្រាប់ខ្សែកាបនេះ។ |
| ការទាញយករ៉ែ | – គ្មានសិទ្ធិឡើយ (សិទ្ធិរបស់រដ្ឋឆ្នេរសមុទ្រ លើខ្ពង់រាបបាតសមុទ្រមិនត្រូវបានទាមទារ)។ |
| ការសង្កេតច្បាប់បរិស្ថាន | – ត្រូវសង្កេតពីច្បាប់បរិស្ថានអនាម័យនៃរដ្ឋឆ្នេរសមុទ្រ<br>– ត្រូវអង្កេតពីច្បាប់ស្តីពីការ បំពុលបរិស្ថាន (ជំពូក៣) អនុវត្តនៅតំបន់សេដ្ឋកិច្ចផ្តាច់មុខ។ |

### ១.១.៥ តំបន់សេដ្ឋកិច្ចផ្តាច់មុខ

តំបន់សេដ្ឋកិច្ចផ្តាច់មុខ គឺជាតំបន់ដែរនៅជាប់នឹងសមុទ្រដែនដី ហើយមានចំងាយមិនលើសពី ២០០ ម៉ាល (Miles) ពីខ្សែបន្ទាត់មូលដ្ឋាន[22]។ តំបន់សេដ្ឋកិច្ចផ្តាច់មុខគឺជាសមុទ្រដែលនៅចន្លោះគោលការណ៍ ២ គឺគោលការណ៍អធិបតេយ្យភាព និងគោលការណ៍សេរីភាព។ នោះមានន័យថា រដ្ឋជាប់ឆ្នេរមានការកំណត់យុត្តាធិការ (អធិបតេយ្យ)នៅលើតំបន់សេដ្ឋកិច្ចផ្តាច់មុខ និងរដ្ឋដទៃទៀតមានសេរីភាពប្រើតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋជាប់ឆ្នេរ។ យោងតាមការស្រាវជ្រាវទំហំនៃការកាន់កាប់នៅក្នុងតំប-ន់សេដ្ឋកិច្ចផ្តាច់មុខនេះមិនមានទំហំដូចគ្នាទេក្នុងនោះមានដូចជាៈ

– បារាំង ១១,៦៩១,៩០០ គម²

– អាមេរិក ១១,៣៥១,000 គម²

– អូស្រ្តាលី ៨,៥០៥,៣៤៨ គម²

– រុស្ស៊ី ៧,៥៦៦,៦៧៣ គម²

– ចក្រភពអង់គ្លេស ៦,៨០៥,៥៨៦ គម²[23]

[22] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា៥៥,៥៧។

[23] Largest EEZ, https://www.reddit.com/r/europe/comments/3zquvt/map_7_largest_exclusive_economic_zones/

- ឥណ្ឌូនេស៊ី ៦,១៥៩,០៣២ គម$^{២}$
- កាណាដា ៥,៥៩៩,០៧៧ គម$^{២}$
- ជប៉ុន ៤,៤៧៩,៣៨៨ គម$^{២}$

### ១.១.៥.១ សិទ្ធិរបស់រដ្ឋជាប់ឆ្នេរសមុទ្រក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ

រដ្ឋជាប់ឆ្នេរមានសិទ្ធិលើការអធិបតេយ្យរបស់ខ្លួនក្នុងការរុករក ការធ្វើអាជីវកម្ម ការអភិរក្ស ការគ្រប់គ្រងធនធានធម្មជាតិមានជីវិត ឬគ្មានជីវិតនៅក្នុងទឹកលើដីបាតសមុទ្រ ក្រោមដីបាតសមុទ្រ និងសកម្មភាពផ្សេងទៀតក្នុងការធ្វើអាជីវកម្ម ការរុករកក្នុងន័យសេដ្ឋកិច្ច។ ដូចជាផលិតថាមពលពីទឹក ចរន្តទឹកហូរ និងខ្យល់។ រដ្ឋជាប់ឆ្នេរអាចអនុវត្តយុត្តាធិការលើការបង្កើតកោះសិប្បនិម្មិត សំណង់ផ្សេងៗ ការស្រាវជ្រាវ ឬរុករកវិទ្យាសាស្ត្រសមុទ្រ ការការពារ និងថែរក្សាបរិស្ថានសមុទ្រ។[24] នេះយើងអាចនិយាយបានថា UNCLOS ត្រង់មាត្រា៥៦ នេះបានផ្តល់យុត្តាធិការផ្តាច់មុខទៅឲ្យរដ្ឋជាប់ ឆ្នេរលើការប្រើប្រាស់សកម្មភាពជាលក្ខណៈសេដ្ឋកិច្ចនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ (១៨៨ ម៉ាលគិត ចាប់ពីព្រំប្រទល់នៃសមុទ្រដែនដីមក) នោះមានន័យថាគ្មានរដ្ឋដទៃទៀតអាចធ្វើសកម្មភាពទាំងអស់រួម ទាំងការនេសាទដោយគ្មានការអនុញ្ញាតពីរដ្ឋជាប់ឆ្នេរឡើយ។ រដ្ឋជាប់ឆ្នេរមានសិទ្ធិគ្រប់គ្រាន់ក្នុងការ កំណត់នូវបរិវេណនៃការនេសាទរបស់ខ្លួននៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខដោយស្របតាមមាត្រា៦១.១។ ទោះបីជាយ៉ាងណារដ្ឋជាប់ឆ្នេរសមុទ្រដែលអនុវត្តសិទ្ធិរបស់ខ្លួន ក៏ត្រូវគោរពសិទ្ធិរបស់រដ្ឋដទៃក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខផងដែរ។[25]

### ១.១.៥.២ សិទ្ធិរបស់រដ្ឋដទៃក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ

រដ្ឋដទៃមានសិទ្ធិសេរីភាពនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខដោយស្របមាត្រា៥៨.១ នៃសន្ធិសញ្ញាអន្តរជាតិស្តីពីច្បាប់សមុទ្រឆ្នាំ១៩៨២។ រដ្ឋដទៃមានសិទ្ធិលើការធ្វើនាវាចរណ៍ ការហោះហើរខាងលើការដាក់ខ្សែកាប និងបំពង់បង្ហូរប្រេងនៅក្នុងទឹកដូចគ្នានឹងនាយសមុទ្រដែរ។ លើសពីនោះ ការប្រើប្រាស់ផ្សេងទៀតដែលស្របតាមច្បាប់អន្តរជាតិដែលពាក់ព័ន្ធនិងសេរីភាពទាំងដូចជា ការប្រតិបត្តិការនាវាយន្តហោះ និងខ្សែកាប បំពង់បង្ហូរ។ រដ្ឋទាំងនេះត្រូវគោរពសិទ្ធិ និងកាតព្វកិច្ចរបស់រដ្ឋជាប់គ្នា ( នាវា យន្តហោះ) និងបទបញ្ញានានា[26]។

### ១.១.៦ តំបន់ខ្ពង់រាបបាតសមុទ្រ

តំបន់ខ្ពង់រាបបាតសមុទ្រ ជាពាក្យភូមិសាស្ត្រដែលបានប្រើប្រាស់សម្រាប់សំដៅលើផ្នែកជម្រាល ចូលទៅក្នុងទឹកសមុទ្រដែលចេញពីច្រាំងសមុទ្រ ហើយជម្រាលចុះទៅក្នុងដែនទឹកមហាសមុទ្រដែល លាតសន្ធឹងជាមធ្យម ២០០ម៉ាល ឬហួសពីនេះ។ប្រសិនបើបាតសមុទ្រវាមានលក្ខណៈចោទខ្លាំ

---

[24] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា៥៦(១)។

[25] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា៥៦(២), ៦១(១)។

[26] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា៥៨(១,៣)។

ង។ នោះមានន័យថា ចម្ងាយរបស់ខ្ពង់រាបបាតសមុទ្រមានចម្ងាយមិនស្មើគ្នាទៅតាមស្ថានភាពពីកន្លែងមួយ ទៅកន្លែងមួយ។[27]

ខ្ពង់រាបបាតសមុទ្រជាកន្លែងដែលរដ្ឋជាប់ឆ្នេរសមុទ្រ អាចយកមកធ្វើជាកម្មសិទ្ធិក្នុងនាមជាដែនដី ដែលស្ថិតក្រោមអធិបតេយ្យរបស់ខ្លួន។ វាជាកន្លែងដែលសម្បូរទៅដោយធនធានធម្មជាតិទាំងលើដីទាំងក្រោមដីបាតសមុទ្រដូចជា សត្វសមុទ្រ រ៉ែ (ត្បូងថ្ម រ៉ែដែក រ៉ែប្រេងកាត)។ ខ្ពង់រាបបាតសមុទ្ររបស់រដ្ឋឆ្នេរសមុទ្ររួមមានបាតសមុទ្រ ដែលលាតសន្ធឹងហួសពីសមុទ្រដែនដីបន្ត រហូតដល់ចុងកន្លែងបញ្ចប់ជាយទ្វីបដោយផ្អែកតាមមាត្រា៧៦.១ នៃសន្ធិសញ្ញាម៉ុងតេហ្គូបៃស្តីពីច្បាប់ សមុទ្រឆ្នាំ១៩៨២។

«ជាយទ្វីប» ផ្សំឡើងពីការដុះបន្តក្រោមទឹកចេញពីទ្វីបនៃរដ្ឋឆ្នេរសមុទ្រហើយរួមមានបាតសមុទ្រ និងដីក្រោមបាតសមុទ្រជម្រាលចោទ និងជម្រាលទេរ។ វាមិនរាប់បញ្ចូលបាតសមុទ្រទឹកជ្រៅដែលកំពូលមហាសមុទ្រ ឬក្រោមដីសមុទ្រ។ ជាយទ្វីប គឺជាតំបន់មហាសមុទ្រមានតំបន់ខ្ពង់រាបបាតសមុទ្រ ខ្ពង់រាបជម្រាលចោត ខ្ពង់រាបចម្រាលទេរ និងគែមក្រោមផ្ទៃទឹកសមុទ្រនៃសំបកទ្វីប (Continental crust) ។[28]

### ១.១.៦.១ សិទ្ធរបស់រដ្ឋជាប់ឆ្នេរសមុទ្រ

រដ្ឋជាប់ឆ្នេរសមុទ្រអាចប្រើប្រាស់សិទ្ធិអធិបតេយ្យលើខ្ពង់រាបបាតសមុទ្រ ក្នុងគោលបំណងដើម្បីរុករក និងធ្វើអាជីវកម្មឡើងធនធានធម្មជាតិរបស់ខ្លួនបាន។[29] រដ្ឋជាប់ឆ្នេរអាចអនុវត្តយុត្តា ធិការផ្តាច់មុខនៅលើខ្ពង់រាបបាតសមុទ្រ ដោយការគ្រប់គ្រងតំបន់នេះក្នុងនាមជាម្ចាស់កម្មសិទ្ធិនៅលើធនធានរ៉ែ និងធនធានជីវសាស្ត្រដោយពុំមានការប៉ះពាល់ដល់នាវាចរណ៍នៅលើផ្ទៃទឹក។ ប្រសិនបើរដ្ឋឆ្នេរសមុទ្រមិនធ្វើការរុករក ឬធ្វើអាជីវកម្មធនធានធម្មជាតិរបស់ខ្លួន គឺគ្មានរដ្ឋទៃទៀតអាចអនុវត្តសកម្មភាពនេះក្នុងតំបន់ខ្ពង់រាបបាតសមុទ្រនេះទេ ដោយគ្មានការអនុញ្ញាតយល់ព្រមពីរដ្ឋឆ្នេរសមុទ្រ។ ចំពោះធនធានធម្មជាតិនេះសំដៅលើធនធានរ៉ែ និងធនធានគ្មានជីវិតនៅបាតសមុទ្រ និងដីនៅក្រោមបាតសមុទ្រព្រមទាំងពូជសត្វដែលស្រទាប់បាតសមុទ្រ និងដីក្រោមបាតសមុទ្រដែលមិនបម្លាស់ទីបាននៅបាត សមុទ្រ និងនៅបាតសមុទ្រ[30]។ សិទ្ធិរបស់រដ្ឋឆ្នេរសមុទ្រនៅខ្ពង់រាបបាតសមុទ្រ

---

[27] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា៧៦(១)។

[28] Larry James Doyle, "continental Margin", last update 9/23/2010 ចូលទស្សនាថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៧។ https://www.britannica.com/science/continental-margin

[29] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា ៧៦(៣)។

[30] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា៧៧(១,៣,៤)។

មិនអាស្រ័យលើការ កាន់កាប់ជាក់ស្តែង ឬមិនជាក់ស្តែងទេ ឬការប្រកាសច្បាស់ណាមួយទេ។ រដ្ឋឆ្នេរសមុទ្រមានសិទ្ធិផ្តាច់ មុខលើកោះសិប្បនិម្មិត ការសាងសង់សំណង់នានានៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ។ មិនត្រឹមតែ ប៉ុណ្ណោះរដ្ឋឆ្នេរសមុទ្រមានសិទ្ធិគ្រប់គ្រាន់ក្នុងការផ្តល់សិទ្ធិ និងដាក់បញ្ញត្តិរបស់ខ្លួននៅក្នុងតំបន់នោះផងដែរ។[31]

រដ្ឋឆ្នេរសមុទ្រត្រូវបង់ថ្លៃ ឬវិភាគទានចំពោះអាជីវកម្មធនធានធម្មជាតិគ្មានជីវិតដែលចម្ងាយ ២០០ ម៉ាល (Miles) ពីខ្សែបន្ទាត់មូលដ្ឋាន។ ការបង់ថ្លៃត្រូវធ្វើជាប្រចាំឆ្នាំក្នុងរយៈពេលប្រាំឆ្នាំដំបូង បន្ទាប់ពីចូលឆ្នាំទីប្រាំមួយត្រូវកើនមួយភាគរយនៃការផលិត ហើយវាកើនឡើងមួយភាគរយជារៀងរាល់ ឆ្នាំ រហូតដល់រយៈពេលដប់ពីរឆ្នាំ ហើយរក្សាប្រាំពីរភាគរយនៅពេលក្រោយ។ ផលិតផលនោះមិនរាប់ បញ្ចូលធនធានដែលប្រើប្រាស់លើអាជីវកម្មទេ។[32]

### ១.១.៦.២ សិទ្ធិរបស់រដ្ឋដទៃ

សិទ្ធិរបស់រដ្ឋឆ្នេរសមុទ្រនៅខ្ពង់រាបបាតសមុទ្រ មិនប៉ះពាល់របបគតិយុត្តិរបស់តំបន់ទឹកខាងលើ និងលំហអាកាស(ការហោះហើរ) ខាងលើតំបន់ទឹកនោះទេ។ ហើយការប្រើប្រាស់សិទ្ធិរបស់រដ្ឋឆ្នេរស-មុទ្រមិនត្រូវរំលោភបំពាន ឬរំខានដោយគ្មានមូលហេតុសិទ្ធិ និងសេរីភាពរបស់រដ្ឋដទៃទៀតទេ។ នោះមានន័យថា រដ្ឋដទៃមានសិទ្ធិក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួន និងសេរីភាពនាវាចរណ៍ហោះ ហើរពីលើផ្ទៃទឹកបានដោយគ្មានប៉ះពាល់។ រដ្ឋដទៃទៀតមានសិទ្ធិដាក់ខ្សែកាប និងបំពង់បង្ហូរនៅក្រោម បាតសមុទ្រនៅខ្ពង់រាបបាតសមុទ្រនេះ។ ការគូសផ្លូវសម្រាប់ដាក់ខ្សែកាប និងបំពុងបង្ហូរចូលក្នុងបាត សមុទ្រត្រូវស្ថិតនៅក្រោមការព្រមព្រៀងពីរដ្ឋឆ្នេរសមុទ្រ។ វាគ្មានការប៉ះពាល់សិទ្ធិរបស់រដ្ឋឆ្នេរសមុទ្រ ចំពោះការបង្កើតលក្ខខណ្ឌសម្រាប់ខ្សែបំពង់បង្ហូរនោះទេ។ នៅពេលដាក់ខ្សែកាប ឬបំពង់បង្ហូរក្រោម បាតសមុទ្ររដ្ឋនោះត្រូវគោរពឲ្យបានត្រឹមត្រូវនៅកន្លែងនោះជាពិសេសលទ្ធភាពក្នុងការជួសជុល។[33]

### ១.១.៦.៣ ការកំណត់ព្រំដែនខ្ពង់រាបបាតសមុទ្រនៃរដ្ឋជាប់ឆ្នេរ

ការកំណត់ខ្ពង់រាបបាតសមុទ្ររវាងរដ្ឋដែលមានឆ្នេរសមុទ្រទល់មុខ ឬជាប់គ្នាត្រូវកំណត់ដោយការព្រមព្រៀងគ្នាទៅវិញទៅមកតាមកិច្ចព្រមព្រៀងអន្តរជាតិដែលបានចែងក្នុងមាត្រា៣៨ នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ[34]។ ប្រសិនបើមិនមានរដ្ឋជាប់ឆ្នេរសមុទ្រនៅពីមុខ ឬចំហៀងទេរដ្ឋជាប់ឆ្នេរ

[31] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា៨១។

[32] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា៨២។

[33] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា៧៨, ៧៩។

[34] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រាIbid ៨៣(១)។

សមុទ្រត្រូវធ្វើឯកតោភាគីដើម្បីកំណត់ខ្គង់រាបបាតសមុទ្ររបស់ខ្លួន។ ប៉ុន្តែគេត្រូវតែគោរពសន្ធិសញ្ញា អន្តរជាតិ ២ ដូចជា៖

- ត្រូវមានអន្តរាគមន៍របស់គណៈកម្មការកំណត់ខ្គង់រាបបាតសមុទ្រ
- រដ្ឋពាក់ព័ន្ធមានកាតព្វកិច្ចធ្វើការផ្សព្វផ្សាយជាសាធារណៈ

បើរដ្ឋពាក់ព័ន្ធមិនអាចឈានដល់កិច្ចព្រមព្រៀងក្នុងអំឡុងពេលសមគួរបាន(សហការគ្នាព្រមព្រៀងគ្នាបណ្តោះអាសន្នដោយមិនរាំងស្ទះដល់ការព្រមព្រៀង) ជម្រើសចុងក្រោយគឺត្រូវធ្វើការពឹងពាក់ភាគីទី៣ ដែលមានសមត្ថកិច្ចដោះស្រាយដូចជាតុលាការមជ្ឈត្តវិនិច្ឆ័យ ឬតុលាការ ICJ។

### ១.១.៧ នាយសមុទ្រ

នាយសមុទ្រសំដៅចំពោះតំបន់ដែលនៅមហាសមុទ្រ និងដែនទឹកដែលមិនស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ដែនទឹកប្រជុំកោះ តំបន់សមុទ្រដែនដី និងដែនទឹកផ្ទៃក្នុងរបស់រដ្ឋណាមួយ។ នាយ សមុទ្រត្រូវបានបង្កើតឡើងដោយគោលការណ៍សេរីភាព។ វាមានន័យថាអធិបតេយ្យភាពរបស់រដ្ឋមិនលាតសន្ធឹងគ្របដណ្តប់ដល់នាយសមុទ្រទេ នេះដោយផ្អែកតាមមាត្រា៨៩ នៃសន្ធិសញ្ញាស្តីពីច្បាប់ សមុទ្រ ឆ្នាំ១៩៨២ ដែលបានចែងថា «គ្មានរដ្ឋណាអាចយកផ្នែកណាមួយនៃនាយសមុទ្រមកក្រោមអធិបតេយ្យរបស់រដ្ឋនោះឡើយ»។

នាយសមុទ្រត្រូវបានបើកឲ្យប្រើប្រាស់ដោយសេរីសម្រាប់គ្រប់រដ្ឋ និងមនុស្សទាំងអស់ហើយប្រើប្រាស់រួមដោយស្មើភាពគ្នា។ សេរីភាពនៅនាយសមុទ្រមានដូចជា៖ សេរីភាពនាវាចរណ៍ សេរីភាពហោះហើរខាងលើ សេរីភាពដាក់ខ្សែកាប ដាក់បំពង់បង្ហូរក្រោមសមុទ្រ សេរីភាពសង់កោះសិប្បនិម្មិត និងគ្រឿងបន្ទាប់ផ្សេងទៀតតាមច្បាប់អន្តរជាតិ សេរីភាពនេសាទ និងសេរីភាពស្រាវជ្រាវវិទ្យាសាស្ត្រ (មាត្រា ៨៧ UNCLOS)។ នាយសមុទ្រត្រូវបានរក្សាទុកសម្រាប់គោលបំណងសន្តិភាព[35] និងសេរីភាពរដ្ឋទាំងអស់មានសិទ្ធិប្រើប្រាស់ដោយគោរពផលប្រយោជន៍របស់រដ្ឋដទៃ។ ចំពោះសេរីភាពពេលប្រើប្រាស់នៅពេលកំពុងមានសង្គ្រាមដូចជាជម្លោះយោធាអន្តរជាតិ គឺពុំបាននិយាយច្បាស់ក្នុងសន្ធិសញ្ញាស្តីពីច្បាប់សមុទ្រឡើយ។ ដូច្នេះប្រសិនបើមានការប្រយុទ្ធគ្នាក្នុងនាយសមុទ្រ វានាំឲ្យមានការពង្រឹង និងបង្កើតកិច្ចព្រមព្រៀងដោយឡែកផ្សេងទៀតស្តីពីការប្រើប្រាស់នាយសមុទ្រនៅពេលមានសង្គ្រាម។

#### ១.១.៧.១ សេរីភាពក្នុងការធ្វើនាវាចរណ៍ និងសិទ្ធិរបស់រដ្ឋម្ចាស់នាវា

សេរីភាពនៃការធ្វើនាវាចរណ៍ជាសេរីភាពសំខាន់នៅក្រោមសន្ធិសញ្ញាពីច្បាប់សមុទ្រ និងច្បាប់អន្តរជាតិ ស្របតាមមាត្រា៩០ « គ្រប់រដ្ឋទាំងអស់ទោះបីជារដ្ឋជាប់ឆ្នេរសមុទ្រឬ មិនជាប់ឆ្នេរ

[35] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា៨៨

សមុទ្រ គឺ មានសិទ្ធិបើកនាវាដោយមានទង់ជាតិរបស់ខ្លួននៅនាយសមុទ្រ»។ រដ្ឋម្ចាស់នាវាមានយុត្តាធិការផ្តាច់មុខ លើនាវារបស់ខ្លួន និងមានសមត្ថកិច្ចរបស់រដ្ឋម្ចាស់នាវា[36]។ ប៉ុន្តែរសេរីភាពនេះស្ថិតនៅក្រោម យុត្តាធិការរដ្ឋអាចប្រព្រឹត្តិទៅបានលុះត្រាតែគោរពលក្ខខណ្ឌនៃសន្តិសុខ។ មានការប្រៀបប្រដូចសម-ត្ថកិច្ច ម្ចាស់នាវាជាសមត្ថកិច្ចដែនដីនៅពេលមានករណីណាមួយកើតឡើងនៅលើនាវាក្នុងនាយសមុទ្រ គឺជា សមត្ថកិច្ចម្ចាស់នាវាជាអ្នកដែលមានយុត្តាធិការផ្តាច់មុខនៅលើករណីនោះ ហើយអនុវត្តអំណាច របស់ខ្លួនដូចនៅលើដែនដីរបស់ខ្លួន គ្មានរដ្ឋដទៃណាអាចមានសមត្ថកិច្ចលើនាវាបានទេ។ វាមានលក្ខណៈ ខុស គ្នាពីនាវាដែលបានធ្វើនាវាចរណ៍ក្នុងដែនទឹកផ្ទៃក្នុង និងសមុទ្រដែនដីដែលមានសមត្ថកិច្ចរបស់ រដ្ឋជាប់ ឆ្នេរមានអាទិភាពខ្លាំងជាងសមត្ថកិច្ចម្ចាស់នាវាទេ។ នៅក្នុងមាត្រា៩៤ នៃសន្ធិសញ្ញាពីច្បាប់ សមុទ្ររដ្ឋម្ចាស់នាវាមានចែងពីកាតព្វកិច្ចរបស់រដ្ឋម្ចាស់នាវា។

បន្ថែមពីនេះនៅនាយសមុទ្រក៏ដូចជាតំបន់សមុទ្រដទៃទៀតនាវាចម្បាំង និង នាវារបស់រដ្ឋមិនបម្រើពាណិជ្ជកម្មមានអភ័យឯកសិទ្ធិអធិបតេយ្យរបស់ខ្លួនមានន័យថា រដ្ឋម្ចាស់នាវាមានសមត្ថកិច្ចផ្តាច់មុខក្នុងការអនុវត្តលើនាវារបស់ខ្លួន។ ក្នុងករណីនៃការបុក ឬឧបទ្វវហេតុនៅនាយសមុទ្រដែលពាក់ព័ន្ធនិងការបាត់បង់ជីវិតរងរបួសធ្ងន់ធ្ងរ ឬខូចខាតនាវាធ្ងន់ធ្ងររបស់រដ្ឋផ្សេងទៀតដែលបង្ករឲ្យមានការប្រជែងគ្នារវាងរដ្ឋម្ចាស់នាវា និងរដ្ឋរបស់ជនល្មើសដែលមានសញ្ជាតិក្នុងការស៊ើបអង្កេត។ ស្របតាមមា-ត្រា ៩៧.៣ នៃUNCLOS "គ្មានការចាប់ខ្លួន ឬការឃុំខ្លួននៃនាវាទោះបីត្រូវការស៊ើបអង្កេតត្រូវបានបញ្ជាពីអាជ្ញាធរផ្សេងទៀតក្រៅពីរដ្ឋម្ចាស់នាវា»។ រដ្ឋម្ចាស់នាវា និងរដ្ឋផ្សេងទៀតត្រូវតែសហការក្នុងការប្រព្រឹត្តទៅនៃការស៊ើបអង្កេតណាមួយ(មាត្រា ៩៤.៧)។

### ១.១.៧.២ យុត្តាធិការអន្តរជាតិ

យុត្តាធិការផ្តាច់មុខរបស់រដ្ឋម្ចាស់នាវាមិនមែនតែងតែពេញលេញនោះទេ មានស្ថានភាពជាច្រើន[37]បានផ្តល់ឲ្យទៅ រដ្ឋផ្សេងទៀតដោយសារមានការប្រកួតប្រជែងសមត្ថកិច្ចរបស់រដ្ឋដទៃ និងអង្គការអន្តរជាតិ។ គ្រប់រដ្ឋអាចទាមទារឲ្យរដ្ឋម្ចាស់នាវាផ្តល់ជំនួយដល់បុគ្គលណាម្នាក់នៅក្នុង ស្ថានភាពគ្រោះថ្នាក់អាចបាត់បង់ រឺរងទុក្ខ ( នាវិករបស់ខ្លួន អ្នកដំណើរ ឬបុគ្គលណាមួយនៅក្នុងសមុទ្រ) [38]ម្យ៉ាងទៀតរដ្ឋទាំងអស់អាចចាត់វិធានការគ្រប់គ្រាន់ដើម្បីបង្ការ និង ផ្តន្ទាទោសការដឹកជញ្ជូនទាសករ នៅក្នុងនាវាដែលបង្ហោះទង់ជាតិរបស់ខ្លួនអាចសហការគ្នា បង្ក្រាបសកម្មភាព ប្លន់ បង្ក្រាបការ រត់ ពន្ធថ្នាំ

[36] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា៩២។

[37] Arnd Bernaert, *Bernaerts' Guide to the 1982 United Nation Convention on the Law of the Sea* (Trafford Canada 2005), 46។

[38] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា៩៨។

ញៀនខុសច្បាប់ និងចាត់ការការផ្សព្វផ្សាយគ្មានការអនុញ្ញាត មានន័យថាការបញ្ជូនផ្សាយវិទ្យុសម្លេង ឬទូរទ-ស្សន៍ចេញពីនាវា ឬគ្រឿងតម្លង់ដល់សាធារណជនដែលផ្ទុយពីបញ្ញត្តិអន្តរជាតិ។[39]

ចំពោះនាវាពាណិជ្ជកម្ម រដ្ឋអាចធ្វើសកម្មភាពដូចជាទៅជិតអង្កេតនាវាដែលសង្ស័យ ប៉ុន្តែមិនអាចបញ្ឈប់នាវាសង្ស័យ ឡើងនាវា ឆែកមើលឯកសារការសួរនាំ (ប្រសិននៅតែសង្ស័យ) ការបង្វែរទិសនាវាសង្ស័យ ចាប់ឃាត់ និងបង្ខំឲ្យនៅស្ងៀម ការរឹបអូសនាវាសង្ស័យការកម្ទេចនាវាប្រសិននាវាផ្ទុកគ្រោះថ្នាក់ធ្ងន់ធ្ងរដល់បរិស្ថាន។ ចំពោះនាវារដ្ឋមិនបម្រើពាណិជ្ជកម្ម(នាវាចម្បាំង) គ្មានរដ្ឋណាក្រៅពីម្ចាស់នាវាមានសមត្ថកិច្ចទេវាត្រូវស្ថិតក្រោយយុតាធិការបស់រដ្ឋម្ចាស់នាវា។

**សិទ្ធិសាកសួរ** (ការឆែកឆេរ) នាវាចម្បាំង និងនាវាដទៃទៀត និងយន្តហោះបម្រើសេវារដ្ឋ គ្មានហេតុផលត្រឹមត្រូវមិនអាចឡើងនាវានោះបានទេ។ អាចមានសិទ្ធិឡើងលើនាវាបរទេសនោះបាន លុះត្រាតែវាមានការសង្ស័យថាជាប់ពាក់ព័ន្ធ និងការប្លន់ ការជួញដូរទាសករ ការចាក់ផ្សាយដោយ គ្មានការអនុញ្ញាត នាវាគ្មានសញ្ជាតិ (ករណីនាវាស្ថិតក្រោមទង់ជាតិនៃរដ្ឋពីរឬច្រើន) នាវាបដិសេធមិន បង្ហាញទង់ជាតិរបស់ខ្លួន។ ក្នុងករណីនាវាប្រើប្រាស់ទង់ជាតិខ្លួនពាក់ព័ន្ធក្នុងការជួញដូរគ្រឿងញៀនខុស ច្បាប់រដ្ឋអាចសុំអន្តរាគមន៍ពីរដ្ឋដទៃផ្សេងទៀតដើម្បីបង្ក្រាបបាន។[40] លើសពីនេះការធ្វើអន្តរាគមន៍ជួយ រដ្ឋមិនមែនចេះតែជួយនោះទេ ត្រូវតែបញ្ជាក់មូលហេតុសមរម្យដូចជា ក្នុងការបង្ការមុន (ឧទាហរណ៍ ការបង្ការជាតិពុល)រដ្ឋជាប់ឆ្នេរ និងរដ្ឋម្ចាស់កំពង់ផែអាចសហការគ្នាធ្វើអន្តរាគមន៍បាន។

**សិទ្ធិដាក់ខ្សែកាប និងបំពង់បង្ហូរក្រោមសមុទ្រ** រដ្ឋទាំងអស់មានសិទ្ធិដាក់ខ្សែកាប និងបំពង់ បង្ហូរលើបាតសមុទ្រនៃនាយសមុទ្រហួសពីខ្ពង់រាបបាតសមុទ្រ។ បន្ថែមពីនេះ រដ្ឋត្រូវអនុម័តច្បាប់ និងបទបញ្ញត្តិដើម្បីកំណត់ថាការបែកបាក់ ឬការខូចខាតដោយនាវាប្រើទង់ជាតិរបស់ខ្លួន ឬជនស្ថិត ក្រោមយុត្តាធិការរបស់ខ្លួនដោយចេតនា ឬធ្វេសប្រហែសដែលបង្កឲ្យប៉ះពាល់ ឬរាំងស្ទះ ធ្ងន់ធ្ងរ ត្រូវតែចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ។ ប៉ុន្តែសេចក្តីចែងនេះមិនអនុវត្តទេប្រសិនបើជននេះប្រព្រឹត្តក្នុង គោលដៅស្របច្បាប់ដើម្បីជួយសង្គ្រោះជីវិត ឬនាវាព្យាយាមអស់លទ្ធភាព ប៉ុន្តែនៅតែមិនប៉ះពាល់។

**សិទ្ធិនេសាទនៅនាយសមុទ្រ** សិទ្ធិសេរីភាពក្នុងការនេសាទបានបង្កើតនៅEEZ មានចម្ងាយ ២០០ម៉ាល ពីខ្សែបន្ទាត់មូលដ្ឋាន។ ប្រហែល៩០ភាគរយនៃបរិមាណត្រីដែលបានទាញយកទៅធ្វើពាណិជ្ជកម្មមានចំនួនច្រើន ហើយបានផ្តល់ផលប៉ះពាល់បំផុត ។ ដូច្នេះសន្ធិសញ្ញាបានបង្កើតតំបន់

---

[39] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា១០៨(១,២), ១០៩(១,២)។

[40] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា ១១០(១)។

នាយ សមុទ្រសំរាប់នេសាទបន្ថែមពីលើ EEZ[41] ដើម្បីការពារគ្រប់គ្រងលើការនេសាទ និងជួយកាត់បន្ថយការ នេសាទច្រើនពេកនៅEEZ។ រដ្ឋទាំងអស់មានសិទ្ធិសម្រាប់ជនជាតិរបស់ខ្លួនក្នុងការចូលធ្វើការនេសាទ នៅនាយសមុទ្រស្ថិតក្រោមសន្ធិសញ្ញា។ តាមមាត្រា ១១៧ បានចែងពីការសហការរបស់រដ្ឋទាំងអស់ ចំពោះជនជាតិរបស់ខ្លួនចាំបាច់អភិរក្សធនធានមានជីវិតនិង ការធ្វើអាជីវកម្មធនធានមានជីវិតនេះ និងការ គ្រប់គ្រងលើការនេសាទ (ការពារពូជសត្វ)។ម្យ៉ាងទៀត ជៀសវាងការរើសអើងអ្នកនេសាទពីរដ្ឋដទៃ ទៀត[42]ហើយសហការគ្នាបង្កើតអង្គការជលផលថ្នាក់អនុតំបន់ ឬតំបន់ដើម្បីការពារសម្រេចគោលដៅ នេះ។

**សមត្ថកិច្ចរបស់អង្គការអន្តរជាតិ** អង្គការអន្តរជាតិមានសមត្ថកិច្ចដែលទាក់ទង និងការកំណត់ផ្លូវគមនាគមន៍ខាងជើងទឹក និងជើងអាកាសតែប៉ុណ្ណោះ។ ប្រសិនបើចាំបាច់បានត្រឹមត្រួតពិនិត្យ ប៉ុន្តែមិនមានសមត្ថកិច្ចចុះបង្ក្រាបទេ។

**ការប្លន់តាមសមុទ្រ** តាមបញ្ញត្តមាត្រា១០០ ដល់មាត្រា១០៧ នៃUNCLOS "ការប្លន់សមុទ្រ គឺរាល់អំពើទាំងឡាយណាដែលសំដៅធ្វើការរំលោភបំពាន ឬការឃុំឃាំង ឬរាល់ការបំផ្លិចបំផ្លាញរបស់ក្រុមនាវិក ឬអ្នកដំណើរលើនាវា ឬក្នុងយន្តហោះឯកជន។ ផ្អែកតាមអនុសញ្ញាUNCLOS រដ្ឋទាំងអស់អាចធ្វើការសហប្រតិបត្តិការ ឬសុំការអន្តរាគមន៍ដើម្បីប្រឆាំងបង្ក្រាបការប្លន់នាវានេះបានហើយវាក៏ជាកាតព្វកិច្ចរបស់រដ្ឋចំពោះសកម្មភាពប្រព្រឹត្តនេះដែរ។[43]

**១.១.៧.៣ ការគោរពបទបញ្ជារបស់រដ្ឋជាប់ឆ្នេរ**

សិទ្ធិនៃការដេញតាមចាប់ត្រូវបានអនុញ្ញាតដើម្បីពង្រឹកអធិបតេយ្យ នៃរដ្ឋជាប់ឆ្នេរសមុទ្រនៅតំបន់នាយសមុទ្រ ដើម្បីគោលដៅដោយរក្សានូវការមិនរំខាននៃនាវាឯកជនណាមួយ។ ការដេញតាមចាប់អាចចាប់ផ្តើមបាននៅពេល ដែលរដ្ឋឆ្នេរសមុទ្រមានហេតុផលសមស្របដែលធ្វើឲ្យជឿជាក់ថានាវាបរទេសនោះបានរំលោភលើច្បាប់ ឬបទបញ្ញត្តិនានារបស់រដ្ឋ និងនាវានោះមិនស្តាប់ការបញ្ជាណាមួយរបស់រដ្ឋ[44]ដូចជាការលួចនេសាទនៅEEZ របស់រដ្ឋឆ្នេរសមុទ្រ ឬប្រព្រឹត្តល្មើសច្បាប់រដ្ឋជាប់ឆ្នេរអាចនាំនាវានោះចូលកំពង់ផែរបស់ខ្លួន ឬអាចដេញតាមចាប់រហូតដល់នាយសមុទ្រ។

សិទ្ធិដេញចាប់ត្រូវអនុវត្តដោយគោរពលក្ខខណ្ឌតឹងរឹងដូចជាៈ

---

[41]Arnd Bernaert, Bernaerts' *Guide to the 1982 United Nation Convention on the Law of the Sea of the Sea* (Trafford Canada 2005), 49។

[42] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា ១១៦, ១១៩។

[43] Mom Ravin," Law of the sea Maritime Boundaries and Dispute Settlement Machanism ," (2005), 19។ http://www.google.com/url?sa=t&rct=j&q=&esrc=s&source=web&cd=1&ved=0ahUKEwjdw6Kk3JXVA-hUKjJQKHVVPCQgQFggjMAA&url=http%3A%2F%2Fwww.un.org%2Fdepts%2Flos%2Fnippon%2Funnff_pro-gramme_home%2Ffellows_pages%2Fmom%2Fmom_page.pdf&usg=AFQjCNGA2xi3vd3tQDlm4D0JQx3hyRSqFg

[44] Arnd Bernaert, *Bernaerts' Guide to the 1982 United Nation Convention on the Law of the Se* (Trafford Canada 2005), 47។

- ការដេញចាប់ត្រូវធ្វើឡើងដោយមានការប្រមានជាមុន
- ការដេញចាប់ធ្វើបានប្រសិនបើវាស្ថិតក្នុងដែនដីសមុទ្រក្រោមយុត្តាធិការរបស់រដ្ឋ ឬស្ថិតនៅខ្ពង់រាបបាតសមុទ្រ
- ការដេញចាប់នៅក្នុងដែនទឹកប្រជុំកោះ គឺដើម្បីបង្ក្រាបរាល់បទល្មើសខុសច្បាប់ ឬបទបញ្ជារដ្ឋ ប៉ុន្តែបើដេញចាប់នៅ EEZ ឬខ្ពង់រាបបាតសមុទ្រ គឺដើម្បីតែធានាឲ្យគោរពបទបញ្ជាប៉ុណ្ណោះ។ មានតែនាវាចម្បាំង ឬយន្តហោះយោធា ឬនាវាដទៃទៀត ដែលបម្រើសេវាសាធារណៈគយ ដែលអាចយកទៅធ្វើការដេញចាប់បាន។ ចំពោះការដេញចាប់នេះត្រូវតែបញ្ឈប់ភ្លាមប្រសិនបើចូលសមុទ្រដែនដីរដ្ឋដទៃ (គោរពអធិបតេយ្យគេ) អាចដេញចាប់បានរហូតដល់ត្រឹមEEZ រដ្ឋនោះ។
- ការដេញចាប់ត្រូវសមស្រប និងបទល្មើសដែលសង្ស័យ[45]

### ១.១.៨ តំបន់បាតសមុទ្រអន្តរជាតិ

តំបន់បាតសមុទ្រអន្តរជាតិ គឺជាតំបន់បាតសមុទ្រជ្រៅក្បែរតំបន់បាតសមុទ្រជ្រៅក្បែរតំបន់ខ្ពង់រាបបាតសមុទ្រហើយស្ថិតពីក្រោមនាយសមុទ្រ។ តំបន់នេះ គឺជាបេតិកភ័ណ្ឌរួមនៃមនុស្សជាតិ(ជាតំបន់សមុទ្រដែលជាកម្មសិទ្ធិរបស់មនុស្សជាតិទាំងអស់)[46]។ គ្មានរដ្ឋ ឬនីតិបុគ្គលណាអាចអះអាងទាមទារ ឬអនុវត្តអធិបតេយ្យភាពលើផ្នែកណាមួយនៃតំបន់បាតសមុទ្រអន្តរជាតិនេះទេ។[47] ចំពោះប្រភពធនធានសំដៅលើ រ៉ែ ឧស្ម័នជាសារធាតុតូចៗស្ថិតនៅបាតសមុទ្រ ក្រោមបាតសមុទ្រ យោងតាម មាត្រា ១៣៣។ បេតិកភ័ណ្ឌរួមនៃមនុស្សជាតិនៅតំបន់បាតសមុទ្រអន្តរជាតិនេះប្រើសម្រាប់ប្រយោជន៍ ជាតិទាំងអស់ ទោះបីជាយ៉ាងណាការប្រើប្រាស់នេះត្រូវតែប្រើប្រាស់សម្រាប់គោលបំណងសន្តិភាព ដោយគ្មានរើសអើងពីរដ្ឋជាប់ឆ្នេរ និងគ្មានប្រកាន់ពូជសាសន៍។

#### ១.១.៨.១ បេតិកភណ្ឌរួមមនុស្សជាតិ

តំបន់បាតសមុទ្រអន្តរជាតិហៅថា "តំបន់ AREA" និងធនធាននៅទីនោះជាបេតិកភណ្ឌរួមមនុស្សជាតិ (មាត្រា១៣៦ UNCLOS ) ដែលជាកម្មសិទ្ធិរបស់មនុស្សជាតិទាំងអស់ និងជាគោល ការណ៍នៃច្បាប់អន្តរជាតិ និងបញ្ចូលនៅក្នុងអនុសញ្ញាអង្គការអន្តរជាតិស្តីពីច្បាប់សមុទ្រ។

ការប្រកាសនៃបេតិកភណ្ឌរួមមនុស្សជាតិ គឺត្រូវបានចូលជាធរមានយោងតាមគោលការណ៍ដូចជា៖

[45] "អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២", មាត្រា១១១។

[46] Mom Ravin,"Law of the sea Maritime Boundaries and Dispute Settlement Machanism," (2005), 19។

[47] "អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២", មាត្រា ១៣៧(១)។

- សិទ្ធិទាំងអស់ទៅនឹងធាតុរាវ រឹង ឬសារធាតុរ៉ែ ឧស្ម័ន រួមទាំងប៉ូលីលោហៈ វត្ថុបុរាណ ប្រវត្តិសាស្ត្រ ជារបស់មនុស្សជាតិទាំងមូល អាជ្ញាធររបស់អង្គការអន្តរជាតិ ធ្វើសកម្មភាពក្នុងនាមនៃមនុស្សជាតិ ដើម្បីគ្រប់គ្រងធនធានរ៉ែរបស់តំបន់។
- សកម្មភាពក្នុងការស្រាវជ្រាវរ៉ែ និងការធ្វើអាជីវកម្មធនធានពីតំបន់នេះត្រូវបានអនុវត្តសម្រាប់ប្រយោជន៍របស់មនុស្សជាតិ និងបែងចែកផលប្រយោជន៍ឲ្យស្មើភាពគ្នាដោយមិនរើសអើងចំពោះផលប្រយោជន៍សេដ្ឋកិច្ច ហិរញ្ញវត្ថុ
- តំបន់ត្រូវបានបើកចំហរក្នុងការប្រើប្រាស់សម្រាប់រដ្ឋទាំងអស់ ក្នុងគោលការណ៍សន្តិភាព និងសន្តិសុខ
- រដ្ឋទាំងអស់ត្រូវមានឱកាសចូលរួមនៅក្នុងសកម្មភាពនៅតំបន់នេះ ជាពិសេសប្រទេសកំពុងអភិវឌ្ឍ
- កិច្ចសហការអន្តរជាតិត្រូវលើកទឹកចិត្តក្នុងការស្រាជ្រាវជីវសាស្ត្រសមុទ្រការការពារអភិរក្សការផ្លាស់ប្តូរបច្ចេកទេសទាក់ទង និងការរុករក និងធ្វើអាជីវកម្មលើរ៉ែ។[48]

រាល់សកម្មភាពក្នុងតំបន់នេះ គឺធ្វើឡើងដើម្បីប្រយោជន៍របស់មនុស្សជាតិទាំងមូលទោះរដ្ឋជាប់ឆ្នេរ ឬមិនមានឆ្នេរសមុទ្រក៏ដោយពិសេសប្រទេសកំពុងអភិវឌ្ឍ និងប្រទេសដែលមិនទាន់ទទួលស្គាល់ពីអង្គការសហប្រជាជាតិ ក៏ត្រូវតែបែងចែកស្មើគ្នានូវផលប្រយោជន៍ហិរញ្ញវត្ថុ និងសេដ្ឋកិច្ចដែលបានពីធ្វើសកម្មភាពនៅតំបន់តាមរយៈយន្តការមិនរើសអើង [49]។

### ១.១.៨.២ សិទ្ធិស្របច្បាប់របស់រដ្ឋជាប់ឆ្នេរ

ប្រសិនបើហួសដែនដំណាត់នៃស្រទាប់ធនធានរ៉ែ នៅក្នុងតំបន់បាតសមុទ្រអន្តរជាតិចូលទៅខ្ពង់រាបបាតសមុទ្ររបស់រដ្ឋជាប់ឆ្នេរជាសិទ្ធិ និងប្រយោជន៍ស្របច្បាប់របស់រដ្ឋជាប់ឆ្នេរទៅលើរាល់សកម្មភាពដែលធ្វើឡើងតំបន់បាតសមុទ្រអន្តរជាតិ។ ប្រសិនបើសកម្មភាពបានហួសចូលក្នុងក្រោមយុត្តាធិការរបស់រដ្ឋមួយត្រូវតែទទួលបានការយល់ព្រមពីរដ្ឋនោះសិន។

ក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រ រដ្ឋជាភាគីអាចមានកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការទទួលខុសត្រូវលើកកម្ពស់លើការប្រព្រឹត្តសកម្មភាព នៃការស្រាវជ្រាវក្នុងតំបន់បាតសមុទ្រអន្តរជាតិដោយបុគ្គលរដ្ឋ អាជ្ញាធរ និងការទទួលយក ឬផ្ទេរទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍នូវបច្ចេកទេស និងចំនេះ ដឹងផ្នែកវិទ្យាសាស្ត្រ។ រដ្ឋជាភាគីអាចស្របតាមកាតព្វកិច្ចរបស់ខ្លួនដើម្បីធ្វើសកម្មភាព នេះ

[48] Arnd Bernaert, Bernaerts' *Guide to the 1982 United Nation Convention on the Law of the Sea* (Trafford Canada 2005), 55។

[49] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា ១៤០។

ដោយ យោងតាមអនុសញ្ញា និងច្បាប់អន្តរជាតិក្នុងការជំរុញ និងលើកទឹកចិត្តក្នុងការផ្ទេរបច្ចេកទេសនេះ។ អាជ្ញាធរអាចធ្វើសកម្មភាពទាក់ទង និងតំបន់បាតសមុទ្រអន្តរជាតិ ដើម្បីបង្ការកាត់បន្ថយ និងគ្រប់គ្រង នូវការបំពុលបរិស្ថានដែលប៉ះពាល់ដល់តំបន់នេះដូចជា ការខួងទម្លុះ ការកៀរដី ការចាក់ដីចោលកាក សំណល់ និងសាងសង់អាជីវកម្មហើយការការពារ និងអភិរក្សធនធានធម្មជាតិ (សត្វសមុទ្រ និងរុក្ខ ជាតិ) [50]។

**ការលើកកំពស់ធនធានធម្មជាតិ** តំបន់បាតសមុទ្រអន្តរជាតិគេជឿជាក់ថាមានធនធានធម្មជាតិជាច្រើនដែលវាចាំបាច់បំផុតសម្រាប់គោលដៅរបស់ពួកឧស្សាហកម្ម។ ដូចនេះតាមមាត្រា១៥០ បានចែងពីសកម្មភាពក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស និងការអភិវឌ្ឍពាណិជ្ជកម្មអន្តរជាតិ និងលើកទឹកចិត្តការសហប្រតិបត្តិការរបស់រដ្ឋដើម្បីធានាក្នុងការៈ

- លើកកំពស់ធនធានធម្មជាតិ
- គ្រប់គ្រងធនធានក្នុងតំបន់បាតសមុទ្រអន្តរជាតិ
- បង្កើនឱកាសចូលរួមសកម្មភាព
- ចូលរួមរកប្រាក់ចំណូលដោយអាជ្ញាធរ និងផ្ទេរបច្ចេកទេសទៅសហគ្រាស ឬប្រទេសកំពុងអភិវឌ្ឍស្របតាមអនុសញ្ញា
- បង្កើនបរិមាណរ៉ែចេញពីតំបន់បាតសមុទ្រអន្តរជាតិ ដើម្បីធានាឲ្យបានគ្រប់គ្រាន់នូវការប្រើប្រាស់ធនធានរ៉ែ។

### ១.១.៩ ច្រកសមុទ្រ

ច្រកសមុទ្រជាផ្លូវដែលតភ្ជាប់សមុទ្រមួយជាមួយសមុទ្រមួយទៀត។ មាននិយមន័យដទៃទៀតថាជាលំហរសមុទ្រដែលទាក់ទងគ្នារវាងសមុទ្ររដ្ឋ និងសមុទ្រអន្តរជាតិ ហើយវាជាច្រកតូចដែលស្ថិតក្នុងសមុទ្រដែនដី(មាត្រា៣៧) ដែលជាផ្នែកសំខាន់សម្រាប់សេដ្ឋកិច្ច និងយុទ្ធសាស្ត្រនានាមានទំហំចន្លោះពី ៦ដល់២៤ ម៉ាល។

សិទ្ធិឆ្លងកាត់នៅច្រកសមុទ្រនេះបានផ្តល់សិទ្ធិឲ្យនាវា និងយន្តហោះមានសិទ្ធិហោះឆ្លងកាត់ច្រកសមុទ្រ និងនាវាចរណ៍ដោយសេរីដោយពុំត្រូវបានរារាំងការឆ្លងកាត់នេះត្រូវធ្វើដំណើរមានគោលដៅ និងជាការបន្តដំណើរមិនអនុញ្ញាតឲ្យឈប់ ឬចូលក្នុងដែនទឹកក្នុង ឬចូលចតនៅកំពង់ផែរបស់រដ្ឋឆ្នេរសមុទ្រទេ។ ចំពោះនាវាមុជទឹកអាចមុជនៅក្រោមទឹកដោយមិនចាំបាច់ងើបមកផ្ទៃទឹកទេ។[51]

[50] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS មាត្រា ១៤៤, ១៤៥។

[51] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS ១៩៨២, មាត្រា ៣៨។

### ១.១.៩.១ សមត្ថកិច្ចរបស់រដ្ឋជាប់ឆ្នេរ

រដ្ឋជាប់ច្រកសមុទ្រអាចមានសមត្ថកិច្ចនៅច្រកសមុទ្រស្ថិតក្នុងមាត្រា៤១, ៤៤ នៃ UNCLOS។ រដ្ឋជាប់ឆ្នេរអាចចេញបញ្ញាដែលទាក់ទងទៅនឹងការហាមឃាត់ការនេសាទ ការស្រាវជ្រាវ និងការវាស់ស្ទង់។ត្រូវទទួលការអនុញ្ញាតជាមុនពីរដ្ឋច្រកសមុទ្រចំពោះ ការបង្ការជាតិពុល និងសន្តិសុខនៃការនាវាចរណ៍ហើយរដ្ឋជាប់ច្រកសមុទ្រអាចកំណត់បែងចែកផ្លូវសមុទ្រ។

ការឆ្លងកាត់របស់នាវារដ្ឋជាប់ឆ្នេរមិនអាចព្យួរសិទ្ធិនេះបានឡើយ។ ផ្លូវនាវាចរណ៍សំខាន់ៗដែលក្លាយជាច្រកអន្តរជាតិមានដូចជា៖ ច្រកម៉ាឡាកា ច្រកបុស្ហ្វ័រុស និងដាដានែល ច្រកហ័រមុស ច្រកម៉ាប់អែល ម៉ាន់ដេប ច្រកម៉ាហ្សេឡង់ ច្រកសមុទ្រទូគី ច្រកហ្ស៊ីប្រាលតារ ច្រកសមុទ្រដាណឺម៉ាក ច្រកសមុទ្រតូរ៉េស ច្រកសមុទ្រទីវ៉ាន់ ច្រកសមុទ្រអ័រម៉ូស។[52]

### ១.១.១០ រដ្ឋប្រជុំកោះ

រដ្ឋប្រជុំកោះត្រូវបានទាមទារដោយរដ្ឋចំនួន១៧នៅពេលនេះ។ ហើយមាន១២រដ្ឋដែលបានបង្កើតបន្ទាត់មូលដ្ឋានប្រជុំកោះ ហើយរដ្ឋដែលមានប្រជុំកោះធំជាងគេ គឺឥណ្ឌូនេស៊ី និងហ្វីលីពីន។ តាមមាត្រា៤៦ នៃUNCLOS បានចែងពីនិយមន័យរបស់រដ្ឋប្រជុំកោះ "រដ្ឋប្រជុំកោះ ជារដ្ឋដែល បង្កើតឡើងទាំងស្រុងដោយប្រជុំកោះមួយ ឬច្រើនហើយបញ្ចូលកោះដទៃទៀត។ ប្រជុំកោះជាកោះ មួយក្រុមគិតទាំងកោះដែលភ្ជាប់ទឹក និងមានលក្ខណៈធម្មជាតិដែលទាក់ទងគ្នាទៅវិញទៅមកដែល វាបង្កើតនូវរូបរាងដែលមានលក្ខណៈភូមិសាស្ត្រសេដ្ឋកិច្ចនយោបាយដែលនៅក្នុងប្រវត្តិសាស្ត្ររបស់វា។"

រដ្ឋប្រជុំកោះ អាចគូសខ្សែបន្ទាត់មូលដ្ឋានដែលជាខ្សែបន្ទាត់មូលដ្ឋានត្រង់ភ្ជាប់ចំនុចចុងបំផុតនៃកោះ និងថ្មប៉ប្រ៉ះ ទឹកដែលនៅចុះបំផុតនៃប្រជុំកោះ។ ប្រវែងនៃខ្សែបន្ទាត់មូលដ្ឋានមិនត្រូវលើស ១០០ ម៉ាលឡើយ។ ប៉ុន្តែក្នុងករណីលើសអាចយកតែ៣ភាគរយនៃប្រវែងខ្សែបន្ទាត់មូលដ្ឋានទាំងអស់ ដែលព័ទ្ធ ក្តោបបិទប្រជុំកោះ ហើយមិនឲ្យលើសពី១២៥ ម៉ាលទេ។

អធិបតេយ្យរបស់រដ្ឋប្រជុំកោះមានទាំងខាងលើ និងក្រោមទឹកប្រជុំកោះ (ក្រោមដីធនធាន ធម្មជាតិ)។ រដ្ឋប្រជុំកោះផ្តល់សេរីភាពនាវាចរណ៍ចំពោះរដ្ឋទាំងអស់ (សិទ្ធិឆ្លងកាត់របស់វាប្រហាក់ ប្រហែលនិងសិទ្ធិឆ្លងកាត់សមុទ្រ) ដូចជាសិទ្ធិហោះហើរ និងនាវាមុជទឹកមិនចាំបាច់ងើបលើផ្ទៃទឹកដែលមានក្នុងមាត្រា៥៣។ រដ្ឋប្រជុំកោះត្រូវទុកចំណែកផ្លូវទំហំ ៥០ម៉ាល សម្រាប់នាវាចរណ៍ និងហោះហើរជាលក្ខណៈអន្តរជាតិ។ ចំពោះកន្លែងដែលតូចជា ៥០ម៉ាល នាវា ឬយន្តហោះត្រូវឆ្លង កាត់ក្នុងចម្ងាយ១០ភាគរយនៅចន្លោះកោះ។

---

[52]List of Major straits of the world, ចូលទស្សនា ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ http://www.quickgs.com/major-straits-of-world/

# ជំពូក២
# ដែនសមុទ្រកម្ពុជា

## ២.១ ដែនសមុទ្រ

ប្រទេសកម្ពុជា គឺស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងជាប់ព្រំដែនទឹកក្នុងឈូងសមុទ្រថៃរវាងប្រទេសថៃ និងប្រទេសវៀតណាម។ កម្ពុជាមានផ្ទៃដីសរុប ១៨១,០៣៥ គីឡូម៉ែត្រការ៉េ ដែលក្នុងនោះផ្ទៃដីមាន ១៧៦,៥២០ គីឡូម៉ែត្រការ៉េ និងទឹក៤,៥២០គីឡូម៉ែត្រការ៉េ។[53] ឈូងសមុទ្រថៃនេះមាន ប្រវែង ២៤៦០ គីឡូម៉ែត្រ។ ហើយឆ្នេរកម្ពុជាមានប្រវែង៤៦០ គីឡូម៉ែត្រ ចំណែកថៃ ១៥៦០គីឡូម៉ែត្រ និងប្រទេសវៀតណាម ២៣០គីឡូម៉ែត្រ។ ចំពោះប្រវែង៤៦០គីឡូម៉ែត្រ របស់ឆ្នេរសមុទ្រប្រទេសកម្ពុជាដែលព័ទ្ធជុំវិញដោយឆ្នេរនៃឈូងសមុទ្រថៃនេះវាជាប្រវែងមួយភាគប្រាំមួយនៃព្រំដែនកម្ពុជាសរុប។[54] ព្រំដែនសមុទ្រកម្ពុជានូវមានលក្ខណៈស្មុកស្មាញ និងមិនទាន់មានភាពច្បាស់លាស់ក្នុងតំបន់ត្រួតស៊ីគ្នានៅឡើយទេ។ នៅក្នុងដែនសមុទ្រកម្ពុជា តំបន់មួយចំនួនត្រូវបានប្រទេសថៃ និងប្រទេសវៀតណាមរំលោភបំពានលើ ហើយព្រំដែនសមុទ្រខ្លះត្រូវបានបាត់បង់ការកាន់កាប់ នៅពេលកម្ពុជាមានស្ថានភាពពិបាកក្នុងប្រទេស។ កម្ពុជាបានធ្វើការទាមទារការកាន់កាប់តំបន់សមុទ្ររបស់ខ្លួនអស់រយៈពេលជាយូរហើយតាំងពីបានទទួលអធិបតេយ្យពីអាណាព្យាបាលបារាំងរហូតដល់បច្ចុប្បន្ននេះ។ កម្ពុជាកំពុងព្យាយាមកំណត់ព្រំដែនសមុទ្រឲ្យមានភាពច្បាស់លាស់ ដើម្បីកំណត់ដែនអធិបតេយ្យរបស់ខ្លួន។

### ២.១.១ ការទាមទារដែនសមុទ្រ

#### ២.១.១.១ ការទាមទារនៅឆ្នាំ១៩៥៧

ប្រទេសកម្ពុជាបានស្ថិតនៅក្រោមអាណាព្យាបាលបារាំង សម្រាប់រយៈពេលប្រហែល៩០ឆ្នាំ ចាប់ពីឆ្នាំ១៨៦៣ រហូតដល់ឆ្នាំ១៩៥៣។[55] ប៉ុន្តែបារាំងមិនបានទាមទារឲ្យជាក់លាក់ណាមួយនៅតំបន់ ដែនសមុទ្ររបស់កម្ពុជាទេ មានតែនៅឆ្នាំ១៩៣៦ដែលបារាំងបានធ្វើក្រឹត្យស្តីពីតំបន់សមុទ្រដែនដីនៅ ឥណ្ឌូចិនដែលស្តីពីការហាមមិនឲ្យជនបរទេសធ្វើការនេសាទនៅក្នុងតំបន់សមុទ្រដែនដី និងផ្តន្ទាទោសចំពោះអំពើខុសច្បាប់នៅក្នុងសមុទ្រដែនដី។ ផ្អែកតាមក្រឹត្យនេះឆ្នេរសមុទ្រប្រទេសកម្ពុជា ក៏ត្រូវបាន ការពារចំពោះការនេសាទផងដែរ។[56] បន្ទាប់ពីទទួលបានឯករាជ្យពេញលេញពីប្រទេសបារាំង

---

[53] Mom Ravin, “Law of the sea Maritime Boundaries and Dispute Settlement Machanism,”(2005), 29។

[54] ហាង់ ជូនណារ៉ុន, *ទស្សនាទានស្តីពីវិវាទព្រំដែនកម្ពុជា-ថៃក្នុងបរិបទនៃយុត្តិសាស្ត្រអន្តរជាតិ*(២០១៣), ១៨។

[55] Global security.org, lasted accesed 28/04/17 www.globalsecurity.org/military/world/cambodia/history-france-htm

[56] ក្រឹត្យស្តីពីតំបន់សមុទ្រដែនដីនៅឥណ្ឌូចិន, ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៣៩។

នៅឆ្នាំ១៩៥៧ កម្ពុជាបានធ្វើការទាមទារលើកដំបូងលើដែនសមុទ្ររបស់ខ្លួន[57]។ កម្ពុជាបានចាប់ផ្តើមទាមទារខ្សែបន្ទាត់មូលដ្ឋានត្រង់របស់កម្ពុជាស្មើនឹង ១៥០,៨០ nm ប្រវែងមធ្យម១១,៦០ nm ហើយអត់មានអង្កត់បន្ទាត់មូលដ្ឋានណាមួយមានប្រវែងលើសពី ២៣ម៉ាលទេ។[58] ខ្សែបន្ទាត់មូលដ្ឋាន បានបែងចែកជា៣ ចំណុចភ្ជាប់គ្នា គឺភាគខាងជើងចាប់ផ្តើមពីខាងចុងនៃព្រំដែន គោកកម្ពុជា-ថៃ រហូតទៅដល់កោះស្មិចដែលមាន កោះរុង និងកោះសាមិត ដែលស្ថិតនៅជិតឆ្នេរសមុទ្រនេះ។ ផ្នែកកណ្តាលភ្ជាប់ជាមួយកោះមួយចំនួនដែលនៅទូទាំងមាត់នៃឆកកំពង់សោម។ កោះទាំងនេះគឺស្ថិតនៅក្នុងសមុទ្រដែលមិនសូវឆ្ងាយពីឆ្នេរជាងកោះដែលនៅភាគខាងជើង។ ចំណែកភាគខាងត្បូងជា កន្លែងចាប់ពីខ្សែបន្ទាត់មូលដ្ឋានបន្តទៅកាន់ឆ្នេរភាគខាងត្បូងរហូតដល់ដីគោក (ឈានដល់ចំណុច ប្រសព្វនៃព្រំដែនគោកកម្ពុជា-វៀតណាម)។ (សូមមើលរូបភាពផែនទី ការទាមទារខ្សែបន្ទាត់មូលដ្ឋាន ត្រង់កម្ពុជា ក្នុងឆ្នាំ ១៩៥៧)

មុនពេលកម្ពុជាក្លាយជាភាគីនៃអនុសញ្ញាស្តីពីសមុទ្រដែនដី និងតំបន់តជាប់ ឆ្នាំ១៩៥៨ និងរដ្ឋហត្ថលេខីនៃអនុសញ្ញាស្តីពីច្បាប់សមុទ្រឆ្នាំ១៩៨២។ កម្ពុជាបានទាមទារខ្សែបន្ទាត់មូលដ្ឋាននៅឆ្នាំ ១៩៥៧ ហើយការទាមទារនោះវាស្របតាម មាត្រា៤ នៃអនុសញ្ញា១៩៥៨។ ចំនុចខ្សែបន្ទាត់មូលដ្ឋានដែលកម្ពុជាបានទាមទារពុំឃ្លាតឆ្ងាយខ្លាំងពីទិសដៅទូទៅ នៃឆ្នេរសមុទ្រដែលចម្ងាយពីផ្នែកមួយទៅផ្នែកមួយទៀត គឺខ្លីហើយផ្នែកខ្លះនៃខ្សែបន្ទាត់មូលដ្ឋានត្រូវបានគូសដោយផ្អែកលើកម្ពស់ទាបរបស់ទឹកជោរ[59] ហើយរួមបញ្ចូលត្រឹមកោះជាប់ឆ្នេរប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាការទាមទារលើខ្សែបន្ទាត់មូលដ្ឋាន ឆ្នាំ ១៩៥៧ មិនបានទទួលការយល់ស្របគ្នាទេ។ កម្ពុជាបានធ្វើការទាមទារលើសមុទ្រដែនដី និងតំបន់តជាប់ជាលើកដំបូងតាមក្រឹត្យ ៦៦២ ចុះថ្ងៃទី ៣០ ខែធ្នូ ១៩៥៧។ ផ្អែកតាមក្រឹត្យនេះកម្ពុជា បានទាមទារ ៥ម៉ាល នៅសមុទ្រដែនដីពីខ្សែបន្ទាត់មូលដ្ឋាននិង ៧ម៉ាល នៅតំបន់តជាប់គិតពីព្រំប្រទល់ ខាងក្រៅនៃសមុទ្រដែនដី និងខ្ពង់រាបបាតសមុទ្រដែលកំណត់ជម្រៅ៥០ម៉ែត្រ។ ចំពោះមាត្រា៦ នៃក្រឹត្យនេះការទាមទារចម្ងាយម៉ាលមិនសំដៅទៅលើកោះត្រល់ទេ។ កម្ពុជានៅតែទាមទារសិទ្ធិប្រវត្តិ សាស្ត្ររបស់ខ្លួនទៅលើកោះត្រល់ដែរ។ ការចរចារសេរីព្រំដែនទឹករវាងកោះត្រល់ និងដីគោកបាន កំណត់ត្រឹមខ្សែជ្រលងទឹកជ្រៅ។[60] បន្ទាប់ពីកម្ពុជាបានក្លាយជាភាគីនៃអនុសញ្ញា

[57] Clive Howard, *Maritime Boundary Delimitation in the Gulf of Thailand*(Durham University,1999),133

[58] ហង់ ជួនណារ៉ុន, *ទស្សនាទានស្តីពីវិវាទព្រំដែនកម្ពុជា-ថៃក្នុងបរិបទនៃយុត្តិសាស្ត្រអន្តរជាតិ*(២០១៣), ទំព័រ ៦០។

[59] Convention on the Territorial Sea and Contiguous Zone 1958, មាត្រា៤។

[60] ក្រឹត្យស្តីពីការកំណត់ព្រំដែនសមុទ្រដែនដី,លេខ 662, ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៥៧, មាត្រា ២-៤, ៦។

ទីក្រុងហ្សឺណែវ ស្តីពីសមុទ្រដែនដី និងតំបន់តជាប់ ឆ្នាំ១៩៦៤ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើសេចក្តីប្រកាសនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៦៩ លើការកែប្រែការទាមទារសារថ្មីលើសមុទ្រដែនដីឡើងទៅជា ១២ម៉ាល វិញលើស ពីនេះទៀត កម្ពុជាបានទាមទារការប្រើប្រាស់អំណាចនៅតំបន់ខ្ពង់រាបបាតសមុទ្ររបស់ខ្លួន ដោយប្រកាស ពីអធិបតេយ្យភាពពេញលេញលើតំបន់នេះចំពោះការត្រួតពិនិត្យ និងយុត្តាធិការលើធនធានធម្មជាតិ របស់ខ្លួន[61] ប៉ុន្តែមិនបានបញ្ជាក់ដែនកំណត់ណាមួយជាក់លាក់លើតំបន់នេះ។

**២.១.១.២ ការទាមទារនៅក្នុងឆ្នាំ១៩៧២**

បន្ទាប់ពីរាជរដ្ឋាភិបាលបានផ្លាស់ប្តូរពីព្រះរាជាណាចក្រកម្ពុជាទៅជាសាធារណៈរដ្ឋខ្មែរ។ កម្ពុជាមានក្រឹត្យលេខ ៤៣៩/៧២ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៧២ ដែលបានកំណត់ពីព្រំទល់ទាំង សងខាងនៃសមុទ្រដែនដីប្រសព្វជាមួយព្រំប្រទល់ទាំងសងខាងរបស់ខ្ពង់រាបបាតសមុទ្ររបស់កម្ពុជា។[62] កម្ពុជាបានផ្តល់សិទ្ធិរុករកប្រេងនៅលើតំបន់ខ្ពង់រាប បាតសមុទ្រទាំងមូលរបស់កម្ពុជាទៅកាន់ ក្រុមហ៊ុន បារាំង ELF-ERAP នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ១៩៧២ ដែលមានផ្ទៃក្រឡា ៩០.០០០ គីឡូម៉ែតការេ[63]។ លើសពីនេះកម្ពុជាបានកែប្រែការទាមទាររបស់ខ្លួនលើខ្ពង់រាបបាតសមុទ្រដោយក្រឹត្យ ៤៣៩/៧២ PRK ថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៧២។ ក្រឹត្យនេះបានអនុញ្ញាតឲ្យព្រំដែននៅជាប់ចំណុចគ្នាដែលត្រូវបាន បង្កើតឡើងដោយបន្ទាត់ត្រង់បានចូលរួមជាមួយព្រំដែនគោកកម្ពុជា-ថៃ នៃឆ្នេរសមុទ្រនៅចំណុចខ្ពស់ បំផុតនៃកោះគត់ហើយលាតសន្ធឹងដល់ចំណុចP នៃឈូងសមុទ្រថៃ។[64]

(សូមមើលរូបភាព២: ការទាមទារខ្សែបន្ទាត់តំបន់ខ្ពងរាបបាត់សមុទ្រ)

ផ្អែកតាមក្រឹត្យ ៥១៨/៧២ កំណត់ព្រំដែនសមុទ្រដែនដីនៃសាធារណៈខ្មែរចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧២ កម្ពុជាបានទាមទារម្តងទៀតលើសមុទ្រដែនដីមានចម្ងាយ ១២ម៉ាល និងទាមទារខ្សែបន្ទាត់ មូលដ្ឋាន។[65] ខ្សែបន្ទាត់មូលដ្ឋាននៅឆ្នាំ១៩៧២ ខុសគ្នាពីខ្សែបន្ទាត់មូលដ្ឋានឆ្នាំ១៩៥៧។ ការទាមទារ នៅឆ្នាំ១៩៧២ នេះគឺនៅឆ្ងាយពីឆ្នេរដីគោកនៃចំណុចប្រសព្វព្រំដែនគោកកម្ពុជា-ថៃ ជាមួយតំបន់ជាប់ ដែនទឹកនៃឈូងសមុទ្រថៃ និងបញ្ចប់នៅព្រំដែនកម្ពុជា-វៀតណាមនៅលើទឹកដីឆ្នេរសមុទ្រ។

[61] សេចក្តីប្រកាសរបស់រដ្ឋាភិបាលទាក់ទងនឹងសមុទ្រដែនដី និងខ្ពង់រាបបាតសមុទ្ររបស់កម្ពុជា, ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៦៩។

[62] ហង់ ជួនណារ៉ុន, *ទស្សនាទានស្តីពីវិវាទព្រំដែនកម្ពុជា-ថៃក្នុងបរិបទនៃយុត្តិសាស្ត្រអន្តរជាតិ*(២០១៣), ទំព័រ ៧៣។

[63] ហង់ ជួនណារ៉ុន, *ទស្សនាទានស្តីពីវិវាទព្រំដែនកម្ពុជា-ថៃក្នុងបរិបទនៃយុត្តិសាស្ត្រអន្តរជាតិ*(២០១៣), ទំព័រ ៦១។

[64] ក្រឹត្យស្តីពីតំបន់ខ្ពងរាបបាត់សមុទ្ររបស់សាធារណរដ្ឋខ្មែរ, លេខ ៤៣៩-៧២/ប្រក, ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៧២។

[65] ក្រឹត្យកំណត់ព្រំដែនសមុទ្រដែនដីនៃសាធារណៈខ្មែរ, លេខ៥១៨-៧២, ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧២, មាត្រា ១។

ខ្សែបន្ទាត់ មូលដ្ឋានត្រង់នៅឆ្នាំ១៩៧២បានចែងចែកជា ៣ចំណុចភ្ជាប់ គឺភាគខាងជើង តំបន់ភាគកណ្តាល និងតំបន់ជុំវិញកោះត្រល់ និងតំបន់ក្បែរឆ្នេរនៃកោះត្រល់។ វាជាការបន្ថែមផ្នែកសំខាន់លើការទាមទារ របស់កម្ពុជា-ថៃទៅកោះគូស្រ្វីរហូតដល់ក្បែរកោះត្រល់។ ផ្នែកទី២គឺតំបន់ជុំវិញកោះត្រល់ ហើយផ្នែក ទី៣ គឺតំបន់ក្បែរឆ្នេរនៃកោះត្រល់ដែលខ្សែបន្ទាត់ត្រង់ភ្ជាប់ទៅនិងចុងនៃព្រំដែនគោកកម្ពុជា-វៀតណាម ជាចំណុចបញ្ចប់។[66] (រូបភាព ៣ : ការទាមទារខ្សែបន្ទាត់មូលដ្ឋានត្រង់កម្ពុជាក្នុងឆ្នាំ១៩៧២)

ផ្នែកសំខាន់នៃខ្សែបន្ទាត់មូលដ្ឋានឆ្នាំ១៩៧២ នេះគឺរួមបញ្ចូលក្នុងការចាត់ទុកកោះត្រល់ជាកោះកម្ពុជា ដោយកម្ពុជាបានរៀបចំបង្កើត ព្រំប្រទល់សងខាងជាមួយវៀតណាម។ វាបានធ្វើឲ្យខ្សែបន្ទាត់ ព្រំប្រទល់សងខាងរវាងកម្ពុជា និងវៀតណាមក្លាយជាខ្សែមេដ្យាន។ ព្រំប្រទល់សងខាងនៅខាងត្បូងកំណត់សមចម្ងាយដែលស្ថិតនៅចន្លោះ កោះត្រល់ និងកោះ ពូលោប៉ានជ័រ និងម្ខាងទៀតកោះវៀតណាមទាំងអស់[67]។ នៅឆ្នាំ១៩៧៦ ក្រោយពីកិច្ចប្រជុំនៃសន្និសិទ្ធអង្គការសហប្រជាជាតិលើកទី៣ ស្តីពីច្បាប់សមុទ្រ រដ្ឋាភិបាលកម្ពុជាបានធ្វើសេចក្តីថ្លែងការណ៍មួយពីសិទ្ធិ និងកាតព្វកិច្ចនៃរដ្ឋជាប់ឆ្នេរ សមុទ្រនៅក្នុងសមុទ្រដែនដី តំបន់តភ្ជាប់ EEZ និងខ្ពង់រាបបាតសមុទ្រ។[68]

### ២.១.១.៣ ការទាមទារនៅឆ្នាំ១៩៨២

កម្ពុជាបានធ្វើការទាមទារនៅតំបន់ EEZ ២០០ម៉ាល នៅថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៧៨ ក្នុងសេចក្តីប្រកាសដោយអ្នកនាំពាក្យក្រសួងការបរទេស។ បន្ទាប់ពីមានការផ្លាស់ប្តូរនៃរបបនយោបាយ ពីរបបកម្ពុជាប្រជាធិបតេយ្យទៅសាធារណៈរដ្ឋប្រជាមានិតកម្ពុជាមានក្រឹត្យមួយដែល ចេញនៅថ្ងៃ ទី៣១ ខែកក្កដា ឆ្នាំ១៩៨២ បានទាមទារម្តងទៀតលើតំបន់ EEZ ២០០ម៉ាល បានចែងក្នុងមាត្រា៦ និងការទាមទារ ១២ម៉ាលនៅតំបន់តជាប់ដែលជាប់នឹងតំបន់ដែនសមុទ្រ (មាត្រា៤)និងខ្ពង់រាប បាតសមុទ្រដែលនៅហួសពីសមុទ្រដែនដី និងមានចម្ងាយ ២០០ម៉ាល ពីខ្សែបន្ទាត់មូលដ្ឋាន។[69] ក្រឹត្យនេះបានធ្វើឲ្យមានការកែសម្រួលខ្សែបន្ទាត់មូលដ្ឋាន និងបន្ថែមនូវការទាមទាររបស់កម្ពុជាដោយ ប្រើប្រាស់កោះពីដីគោកកម្ពុជាជាចំណុចមូលដ្ឋាន។ កម្ពុជាបានសម្រួលខ្សែបន្ទាត់មូលដ្ឋានត្រង់

[66] Clive Howard, *Maritime Boundary Delimitation in the Gulf of Thailand*(Durham University,1999), 141-142

[67] ហាង់ ជួនណារ៉ុន, *ទស្សនាទានស្តីពីវិវាទព្រំដែនកម្ពុជា-ថៃក្នុងបរិបទនៃយុត្តិសាស្ត្រអន្តរជាតិ*(២០១៣), ទំព័រ ៧៥។

[68] សេចក្តីថ្លែងការរបស់កម្ពុជាប្រជាធិបតេយ្យនៅសម័យប្រជុំទី៤ នៃសន្និសិទ្ធលើកទី៣ របស់អង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ, ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ១៩៧៦ ។

[69] ក្រឹត្យកំណត់ព្រំដែនតំបន់សមុទ្រ និងខ្ពង់រាបបាតសមុទ្រនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា, ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៨២។

របស់ខ្លួនដោយកាត់បន្ថយចំនួនចំណុចភ្ជាប់ពី២០ចំណុចទៅជា៥ចំណុចវិញ។ ខ្សែបន្ទាត់មូលដ្ឋាននៅឆ្នាំ១៩៨២ នេះមានចំណុចភ្ជាប់ពីដីគោកនៃព្រំដែនកម្ពុជា-ថៃ ជាចំណុចចាប់ផ្តើមទៅកោះកូស្រូវីបន្តទៅកោះវៀ កោះពូឡាវៃ (ចំណុចពាក់កណ្តាលរវាង កោះពូឡូវ៉ៃនេះ)។ ចំពោះចំណោមចំណុចទាំង៥ នេះមានចំណុចមួយដែលមិនទាន់សម្រេច គឺចំនុចនៅខ្សែបន្ទាត់មូលដ្ឋានត្រង់ភ្ជាប់ប្រជុំកោះថូជូ និងកោះពូឡូវ៉ៃ តាមមាត្រា៣នៃកិច្ចព្រមព្រៀងទឹកប្រវត្តិសាស្ត្ររវាង កម្ពុជា-វៀតណាម។[70] (រូបភាព៥: ការទាមទារខ្សែបន្ទាត់មូលដ្ឋានត្រង់កម្ពុជាក្នុងឆ្នាំ១៩៨២ និងការទាមទារខ្សែបន្ទាត់មូលដ្ឋានត្រង់វៀត ណាមក្នុងឈូវសមុទ្រថៃ)

តាមកិច្ចព្រមព្រៀងស្តីពីតំបន់ទឹកប្រវត្តិសាស្ត្រចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ១៩៨២ កម្ពុជាមានបំណងបោះបង់ការទាមទារនៅឆ្នាំ១៩៧២ ដោយសារវាមិនបានបង្កើតព្រំដែនសមុទ្រជាក់លាក់ ប៉ុន្តែគ្រាន់តែកាត់បន្ថយ តំបន់ត្រួតស៊ីគ្នានោះទេដូច្នេះបានកម្ពុជា និងវៀតណាមបានទាមទារប្រជុំ កោះប៉ូឡូវ៉ៃ កោះត្រល់ និងកោះថូជូ ហើយកម្ពុជាទទួលបាន កោះប៉ូឡូវ៉ៃ វៀតណាមបាន កោះថូជូបានសម្រេច ដាក់ស្ថិតក្រោមតំបន់ទឹកប្រវត្តិសាស្ត្រ ដែលជាតំបន់ត្រួតស៊ីគ្នាមានក្រឡាផ្ទៃថយពាក់កណ្តាលនៃគំនូស ជុំវិញជាក់លាក់។[71]

### ២.១.២ តារាងអនុសញ្ញាព្រំដែនសមុទ្រ

ការសង្ខេបនៃការទាមទាររបស់កម្ពុជា

| | | | |
|---|---|---|---|
| សមុទ្រដែនដី | កញ្ញា ១៩៦៤ | ១៩៥៨អនុសញ្ញាស្តីពីសមុទ្រដែនដី និងតំបន់តជាប់ | ក្លាយជាភាគីនៃសនុសញ្ញាស្តីពីសមុទ្រដែនដី និងតំបន់តជាប់ ១៩៥៨ |
| | កញ្ញា ១៩៦៩ | សេចក្តីប្រកាសរបស់រដ្ឋាភិបាល ១២nm | ទាមទារកោះទាំងអស់នៃកម្ពុជាក្នុងសមុទ្រដែនដី តំបន់តជាប់ តំបន់សមុទ្រ |
| | មករា ១៩៧៨ | សេចក្តីថ្លែងការណ៍ក្រសួងកិច្ចការបរទេស ១២nm | សេដ្ឋកិច្ចផ្តាច់មុខ តំបន់ខ្ពង់រាបបាតសមុទ្រ ដកស្រង់សន្ធិសញ្ញាឆ្នាំ ១៩០៧ ជាមួយប្រទេសថៃ |

[70] Clive Howard, *Maritime Boundary Delimitation in the Gulf of Thailand*(Durham University,1999), 149-150, 211, 220, 244

[71] ហង់ ជួនណារ៉ុន, *ទស្សនាទានស្តីពីវិវាទព្រំដែនកម្ពុជា-ថៃក្នុងបរិបទនៃយុត្តិសាស្ត្រអន្តរជាតិ*(២០១៣), ទំព័រ ៧៦។

| | | | |
|---|---|---|---|
| | កក្កដា ១៩៨២ | ក្រឹត្យរបស់ក្រុមប្រឹក្សារដ្ឋ ១២nm | |
| ប្រជុំកោះ ខ្សែបន្ទាត់មូលដ្ឋានត្រង់ និងការទាមទារដែនទឹកប្រវត្តសាស្ត្រ | កក្កដា ១៩៧២ | ក្រឹត្យលេខ ៤៣៩-៧២/PRK | បង្កើតប្រព័ន្ធខ្សែបន្ទាត់មូលដ្ឋានត្រង់ |
| | កក្កដា ១៩៨២ | ក្រឹត្យរបស់ក្រុមប្រឹក្សារដ្ឋ | ខ្សែបន្ទាត់មូលដ្ឋានច្បាស់លាស់ |
| | កក្កដា ១៩៨២ | កិច្ចព្រមព្រៀងជាមួយប្រទេសវៀតណាម | ការទាមទារដែនទឹកប្រវត្តិសាស្ត្រក្នុងឈូងសមុទ្រថៃ ដែលគោរពតាមកិច្ចព្រមព្រៀងព្រំដែនជាមួយវៀតណាម |
| តំបន់តជាប់ | មករា ១៩៧៨ | របាយការណ៍របស់ក្រសួងកិច្ចការបរទេស ២៤ nm | ទាមទារសិទ្ធិគ្រប់គ្រង់លើតំបន់តជាប់ |
| | កក្កដា ១៩៨២ | ក្រឹត្យរបស់ក្រុមប្រឹក្សារដ្ឋ ២៤ nm | ទាមទារការអនុវត្ត សិទ្ធិនៃការគ្រប់គ្រង់ការត្រួតពិនិត្យ សុវត្ថិភាព ការពារការរំលោភបំពាន សុខភាព សារពើពន្ធ និងអន្តោប្រវេសន៍ |
| តំបន់ខ្ពង់រាបបាតសមុទ្រ | មិនា ១៩៦០ | អនុសញ្ញាស្តីពីតំបន់ខ្ពង់រាបបាតសមុទ្រ ១៩៥៨ | ក្លាយជាសមាជិកក្នុងអនុសញ្ញា |
| | កញ្ញា ១៩៦៩ | សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាល | ទាមទារយុត្តាធិការផ្តាច់មុខ និងគ្រប់គ្រង់បាតសមុទ្រ និងដីក្រោមបាតសមុទ្រ |
| | កក្កដា ១៩៧២ | ក្រឹត្យលេខ ៤៣៩-៧២/PRK | ការអះអាងឯកតោភាគីដើម្បីកំណត់ព្រំដែនតំបន់ខ្ពង់រាបបាតសមុទ្រ |
| | មករា ១៩៧៨ | សេចក្តីថ្លែងការណ៍ក្រសួងកិច្ចការបរទេស | ការអះអាងពង្រីក "ធនធានធម្មជាតិលើដែនដី" |

| | | | |
|---|---|---|---|
| | កក្កដា ១៩៨២ | ក្រឹត្យរបស់ក្រុមប្រឹក្សារដ្ឋ ២០០ nm | ការអះអាង "សិទ្ធិផ្តាច់មុខក្នុងការកំណត់ការប្រើប្រាស់ឧបករណ៍លើកោះសិប្បនិម្មិត ឬការខួង រុករកផ្សេងៗ។ សកម្មភាពរបស់ជនបរទេសត្រូវទទួលការអនុញ្ញាត និងព្រមព្រៀង(ប្រទេសកម្ពុជា) អនុលោមតាមច្បាប់ និងបទបញ្ញត្ត។" |
| តំបន់នេសាទ/តំបន់សេដ្ឋកិច្ចផ្តាច់មុខ | មករា ១៩៧៨<br><br>កក្កដា ១៩៨២ | សេចក្តីថ្លែងការណ៍ក្រសួងកិច្ចការបរទេស ២០០ nm<br>ក្រឹត្យរបស់ក្រុមប្រឹក្សារដ្ឋ ២០០ nm | បង្កើតតំបន់សេដ្ឋកិច្ចផ្តាច់មុខ<br><br>ការអះអាង "យុត្តាធិការផ្តាច់មុខទាក់ទងនឹងការបង្កើត ការប្រើប្រាស់ឧបករណ៍កោះសិប្បនិម្មិត និងការស្រាវជ្រាវក្នុងសមុទ្រ" |
| បទបញ្ញត្តបរិស្ថាន | កក្កដា ១៩៨២ | ក្រឹត្យរបស់ក្រុមប្រឹក្សារដ្ឋ ២០០ nm | ការអះអាង "យុត្តាធិការលើការអភិរក្សបរិស្ថាន និងការត្រួតពិនិត្យការបំពុលក្នុង EEZ" |
| ព្រំដែនសមុទ្រ | មិនា ១៩០៧<br>កក្កដា ១៩៨២<br><br>កក្កដា ២០០១ | កិច្ចព្រមព្រៀង<br><br>កិច្ចព្រមព្រៀង<br><br>កិច្ចព្រមព្រៀង | កិច្ចព្រមព្រៀងព្រំដែនសមុទ្រជាមួយប្រទេសថៃ<br><br>កិច្ចព្រមព្រៀងជាមួយវៀតណាមលើការគូរព្រំដែន និងទាមទារដែនទឹកប្រវត្តសាស្ត្រនៅឈូងសមុទ្រថៃ<br><br>អនុស្សារណនៃការយោគយល់គ្នា ទាក់ទងនិងការទាមទារតំបន់ត្រួតស៊ីគ្នានៃតំបន់ខ្ពង់រាបបាតសមុទ្រ |
| | | | |
| អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ UNCLOS | កក្កដា ១៩៨៣ | | ចុះហត្ថលេខាអនុសញ្ញា មិនផ្តល់សច្ចាប័ន |

### ២.១.៣ បញ្ហាវិវាទព្រំដែន

វិវាទព្រំដែនសមុទ្រកម្ពុជាបានកើតឡើងរវាងភាគីប្រទេសថៃ និងវៀតណាម។ វិវាទព្រំដែននេះកើតឡើងបណ្តាលមកពីការទាមទាររបស់ភាគីនីមួយៗ និងការជំទាស់ពីភាគីម្ខាងដោយមិនឯកភាពលើការទាមទារ។ ចំពោះវិវាទសមុទ្រក្នុងឈូងសមុទ្រថៃរវាងកម្ពុជា-ថៃ នៅក្នុងខ្ពង់រាបបាតសមុទ្រកើតចេញពីការទាមទារតំបន់ត្រួតស៊ីគ្នាលើការធ្វើអាជីវកម្មធនធានប្រេងកាត និងជំទាស់ពីភាគីថៃ មិនឲ្យពង្រីកលំហសមុទ្ររបស់កម្ពុជា។ ជម្លោះនៃការទាមទាររបស់ភាគីថៃ លើការផ្តល់សិទ្ធិពេញលេញ ទៅកាន់ កោះគុត ដើម្បីបង្កើតព្រំដែន ប៉ុន្តែភាគីកម្ពុជានូវតែគោរពលើសន្ធិសញ្ញាព្រំដែនបារាំង-សៀមនៅឆ្នាំ១៩០៧ ដើម្បីទទួលសិទ្ធិក្នុងតំបន់អធិបតេយ្យ ។

តាមសន្ធិសញ្ញាស្តីពីច្បាប់សមុទ្រ រដ្ឋជាប់ឆ្នេរមានសិទ្ធិទទួលបានខ្ពង់រាបបាតសមុទ្រដែលមាន ចម្ងាយ ២០០ម៉ាល ប៉ុន្តែជាក់ស្តែងប្រវែងទទឹងឈូងសមុទ្រថៃមានប្រវែងពុំលើសពី ៤០០ម៉ាលទេ។ វាបង្កឲ្យមានវិវាទពីការទាមទារសិទ្ធិគ្រប់គ្រងលំហសមុទ្ររៀងៗខ្លួន បង្កើតឲ្យមានតំបន់ត្រួតស៊ីគ្នានៅ ឈូងសមុទ្រថៃ។[72] កម្ពុជាបានអះអាងនៅឆ្នាំ១៩៧២ លើការទាមទារខ្ពង់រាបបាតសមុទ្រនៅតំបន់ត្រួត ស៊ីគ្នា[73]។ នៅឆ្នាំ១៩៩៥ ខ្មែរបានស្នើឲ្យមានការធ្វើអាជីវកម្មរ៉ែប្រេងកាតរួមគ្នាជាមួយថៃនៅក្នុងតំបន់ ជម្លោះ (តំបន់ត្រួតស៊ីគ្នា) ខ្ពង់រាបបាតសមុទ្រ។ ឆ្នាំ២០០១ កម្ពុជា និងថៃបានធ្វើអនុស្សរណៈយោគយល់ គ្នាដើម្បីបែងចែកតំបន់ជា២ផ្នែក គឺតំបន់ភាគខាងជើង និងតំបន់អភិវឌ្ឍរួមគ្នាភាគខាងត្បូងតាម បណ្តោយខ្សែបន្ទាត់រយៈទទឹង។ មានការបញ្ជាក់ថាតំបន់ភាគខាងត្បូង មានធនធានធម្មជាតិជាច្រើន សន្ធឹកសន្ធាប់។[74] ការទាមទារតំបន់ត្រួតស៊ីគ្នានេះស្ថិតនៅ ២៧ ០០០ គីឡូម៉ែត្រការ៉េ នៅក្នុងឈូង សមុទ្រថៃដែលមានការប៉ាន់ប្រមាណថាមាន ១១ពាន់លានហ្វីត នៃឧស្ម័នធម្មជាតិ និងមិនកំណត់ប្រេង ខាប់។ កម្ពុជាបានស្នើសុំឲ្យបែងចែកតំបន់ជម្លោះជា ៤ ហើយបែងចែកប្រាក់ចំនូលគ្រប់គ្រង់ស្មើគ្នា ប៉ុន្តែថៃបានស្នើសុំឲ្យបែងចែកតែ ៣តំបន់ទេ (ជើង ត្បូង និងប្រាក់ចំនូលពីតំបន់ភាគកណ្តាល បែងចែកស្មើគ្នា។ ក្រោយពីជម្លោះប្រាសាទព្រះវិះហារនៅ ឆ្នាំ២០០៩ ថៃបានលុបអនុស្សរណៈនេះចោល រហូតដល់ឆ្នាំ ២០១១ ទើបស្នើសុំបន្តម្តងទៀត។[75]

កម្ពុជា-វៀតណាមមានជម្លោះលើការទាមទារកាន់កាប់ កោះពូឡូវៃ (កោះអាចម៍សេះ) កោះនេះស្ថិតក្នុងចម្ងាយ ១០០គម ពីក្រុងព្រះស៊ីហនុរួមទាំងមានចំណតឧទ្ធម្ភាចក្រផែកប៉ាល់ ដែលសហគ្រាស ElF-Erap ជាអ្នកកសាង ស្របតាមកិច្ចសន្យា ឆ្នាំ១៩៦៩។ វៀតណាម បានស្នើទាមទារបន្ទាត់កែងជាប់បន្ទាត់ត្រង់ដែលភ្ជាប់កោះពូលោប៉ានជ័រ(កោះក្រចកសេះ) ជាមួយកោះពូឡូវៃស្ថិតក្រោមអាជ្ញាធររបស់ខ្លួន និងខ្មែរ (ខ្មែរបានទាត់ចោលការស្នើនេះ)។ ឆ្នាំ១៩៩៩ គណៈកម្មការខ្មែរពុំបានទទួលការយល់ ព្រមពីវៀតណាម ដែលសុំត្រឹមបន្ទាត់ប្រេវីយេជាព្រំប្រទល់នោះទេដោយវៀតណាមនូវតែអះអាងយក កិច្ចព្រមព្រៀងឆ្នាំ១៩៨២ ខ្មែរបានព្រមទទួលស្គាល់កោះត្រល់ និងកោះពូលោប៉ានជ័រ (កោះក្រចកចេះ) ជារបស់វៀតណាម។[76] តំបន់ដែនទឹកប្រវត្តិសាស្ត្រជាកម្មវត្ថុនៃ

---

[72] ហង់ ជួនណារ៉ុន, *ទស្សនាទានស្តីពីវិវាទព្រំដែនកម្ពុជា-ថៃក្នុងបរិបទនៃយុត្តិសាស្ត្រអន្តរជាតិ*(២០១៣), ទំព័រ២៩-៣៤។

[73] Amrih Jinangkung, “Maritime Boundary Disputes Among ASEAN Member Counties”. http://pustakahpi.kemlu.go.id/app/Volume%203,%20september-Desember%202011_2_8_PDF

[74] Ciptadi and Andromedo Windra,”The influence of the Wealth and Sovereignty in Southeast Asean Maritime Dispute,”(The NPS Institution Aichive, California 2016), 43-44

[75] Jonh Topham Abrahamsom, “Joint Development of offshore Polar oil and gas resource and the United Nation Convention on the Law of the Sea,”(ANU College of Law, 2015), 94-95

[76] គណៈកម្មាធិការព្រំដែនកម្ពុជា, *ព្រំដែនដី និងសមុទ្រនៃប្រទេសកម្ពុជាឆ្នាំ ២០០០* (១៩៩៩-២០០១), ១៣។

ជម្លោះអធិបតេយ្យរវាងកម្ពុជា និងវៀត ណាម។ ភាគីទាំងពីរបានធ្វើការអះអាងទាមទារទៅកាន់ដែនទឹកប្រវត្តិសាស្ត្រ។ កម្ពុជា និងថៃបានធ្វើ កិច្ចព្រមព្រៀងអភិវឌ្ឍរួមគ្នានៅឆ្នាំ១៩៨២ សំរាប់ដែនទឹកប្រវត្តិសាស្ត្រនៃតំបន់ខ្ពង់រាបបាតសមុទ្រ។ កិច្ចព្រមព្រៀងបានបញ្ជាក់ពីការធ្វើអាជីវកម្មលើធនធានធម្មជាតិនៅតំបន់នេះ។ តំបន់ទឹកប្រវត្តិសាស្ត្រ ជាតំបន់ចតុកោណដែលជាតំបន់អភិវឌ្ឍរួមគ្នានៅ ភាគខាងត្បូងខាងលិច នៃកោះភូគុកផ្តល់សិទ្ធិឲ្យ កម្ពុជាលើខ្សែបន្ទាត់ក្បែរឆ្នេរវៀតណាមមានសិទ្ធិបន្តពីខ្សែបន្ទាត់នេះ[77] "កិច្ចព្រមព្រៀងតំបន់ទឹកប្រវត្តិ សាស្ត្រនេះបានកំណត់យកតំបន់ទឹកប្រវត្តិសាស្ត្រម្ខាងពី ចំណុចកោះវ៉ៃ ជាកោះកម្ពុជា ហើយតជាប់ ទៅចំណុចម្ខាងទៀតកោះថូជូជារបស់វៀតណាម"[78]។ បញ្ហាព្រំដែនបានប៉ះពាល់ដល់កោះភូគុកនៅក្បែរ ឆ្នេរ និងអធិបតេយ្យភាពរបស់កោះភូគុកដែលត្រូវទាមទារដោយកម្ពុជា។ កម្ពុជានៅតែអះអាងលើ កិច្ចព្រមព្រៀងរបស់កម្ពុជាពីអធិបតេយ្យរបស់ខ្លួនលើកោះភូគុក ផ្អែកតាមការស្រាយបំភ្លឺរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ខ្សែបន្ទាត់ព្រំដែននៅក្នុងតំបន់ទឹកប្រវត្តិសាស្ត្រមិនទាន់ បានកំណត់នៅឡើយទេ ចំណែកកិច្ចព្រមព្រៀងតំបន់ទឹកប្រវត្តិសាស្ត្រមានគោលដៅចម្បងលើការ កំណត់អធិបតេយ្យភាពរបស់កម្ពុជាលើកោះវ៉ៃ។[79]

## ២.២ វិសាលភាពលំហសមុទ្រកម្ពុជា

### ២.២.១ តំបន់អធិបតេយ្យ

តំបន់ឆ្នេរសមុទ្រដែលមានដែនទឹកក្នុង និងសមុទ្រដែនដីត្រូវចាត់ចូលជាតំបន់អធិបតេយ្យរបស់រដ្ឋជាប់ឆ្នេរ។ រដ្ឋជាប់ឆ្នេរមានសិទ្ធិ និងសមត្ថកិច្ចពេញលេញលើតំបន់នេះ។ កម្ពុជាមានតំបន់ឆ្នេរសមុទ្រ ៤៣៥km [80] ដែលលាតសន្ធឹងទាំងក្នុងដែនទឹកក្នុង និងក្រៅដែនទឹកដែលមានប្រវែង ១២ ម៉ាលពីខ្សែបន្ទាត់មូលដ្ឋាន។ តំបន់ឆ្នេរកម្ពុជាមានខេត្ត៤ នៅតាមឆ្នេរគឺ ខេត្តកោះកុង ខេត្តកំពត ក្រុងព្រះសីហនុ និងក្រុងកែប[81]។ តំបន់ឆ្នេរទាំងអស់នេះស្ថិតក្រោមអធិបតេយ្យរបស់កម្ពុជា។

---

[77] Jonh Topham Abrahamsom, "Joint Development of offshore Polar oil and gas resource and the United Nation Convention on the Law of the Sea,"(ANU College of Law, 2015), 83។

[78] សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន, "អត្ថបទគោលរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាសម្រាប់អធិប្បាយ ផ្តល់ការបំភ្លឺស្តីពី ការងារបោះបង្គោលខណ្ឌសីមាព្រំដែនគោក និងការកំណត់ព្រំដែនសមុទ្ររវាង ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម(២០១២), ២៥។

[79] សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន, អត្ថបទគោលរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាសម្រាប់អធិប្បាយ ផ្តល់ការបំភ្លឺស្តីពី ការងារបោះបង្គោលខណ្ឌសីមាព្រំដែនគោក និងការកំណត់ព្រំដែនសមុទ្ររវាង ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម(២០១២), ២៤។

[80] Ali Raza Rizvi and Uwe Singer, "Cambodia Coastal Situation analysis,"(IUCN Swilzerland 2011), 5។

[81] WEPA, State of water environment issues( 14/05/17) www.wepa-db.net/policies/state/cambodia/seaarea3-9.htm

#### ២.២.១.១ តំបន់ដែនទឹកផ្ទៃក្នុង

តំបន់ដែនទឹកផ្ទៃក្នុងនៅជាប់ឆ្នេររបស់រដ្ឋ និងស្ថិតក្នុងខ្សែបន្ទាត់មូលដ្ឋាន តាមមាត្រា ៨ UNCLOS ក្រោមសមត្ថកិច្ចផ្តាច់មុខរបស់រដ្ឋ។ ដែនទឹកផ្ទៃក្នុងរបស់កម្ពុជារួមមានកំពង់ផែ ផែតំបន់ទឹកប្រវត្តិសាស្ត្រ ឆកឆេងឆ្ងង និងឆកសមុទ្រតូចៗព្រមទាំងខ្សែបន្ទាត់មូលដ្ឋាន។ ខ្សែបន្ទាត់មូលដ្ឋាន ឆ្នាំ១៩៨២ របស់កម្ពុជារួមមានឆកសមុទ្រកោះកុង ឆកកំពង់សោម ឆករាម និងឆកវាលរេញ[82]។ កម្ពុជា-វៀតណាមបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទាមទារដែនទឹកប្រវត្តិសាស្ត្រនៅឈូងសមុទ្រថៃ ដាក់ ក្រោមដែនទឹកផ្ទៃក្នុងដែលនៅចន្លោះកោះភូគុក និងកោះថូជូនៃប្រទេសវៀមណាម និងឆ្នេរសមុទ្រខេត្ត កំពត និងក្រុមកោះពូឡូវ៉ៃកម្ពុជា[83]។

##### ២.២.១.១.១ កំពង់ផែសមុទ្រកម្ពុជា

កំពង់ផែសមុទ្រកម្ពុជាធំៗមានកំពង់ផែក្រុងព្រះសីហនុ កំពង់ផែកោះកុង និងកំពង់ផែកំពត។ កំពង់ផែក្រុងព្រះសីហនុ ជាកំពង់ផែសមុទ្រទឹកជ្រៅដែលចាត់ទុកជាកំពង់ផែអន្តរជាតិដ៏សំខាន់ និងចាត់ទុកជាតំបន់សេដ្ឋកិច្ចមួយក្នុងប្រទេសកម្ពុជា។ កំពង់ផែនេះស្ថិតនៅក្នុងឆកសមុទ្រកំពង់សោម នៃដែនសមុទ្រកម្ពុជាដែលត្រូវបានសាងសង់នៅឆ្នាំ ១៩៥៩ បច្ចុប្បន្នមានការប៉ាន់ប្រមាណអាចផ្ទុកបាន ៩៥០ ០០០តោន ក្នុងមួយឆ្នាំដោយមិនរាប់បញ្ចូលកន្លែងដាច់ឆ្ងាយ។ ម្យ៉ាងទៀតអាចផ្ទុកនាវាបាន ១០ ០០០ ទៅ ១៥ ០០០ តោន (dead weight) ហើយផ្ទៃប្រមាណ ៦ ០០០ ម៉ែត្រការ៉េ សំម្រាប់ឃ្លាំងស្តុកទុកអ៊ីវ៉ាន់[84]។ លើសពីនេះកំពង់ផែសមុទ្រក្នុងព្រះសីហនុ បានអភិវឌ្ឍឲ្យមាន វាលប្រេងចំនួន៦ ដែលនៅមិនឆ្ងាយពីសមុទ្រ នៅក្បែរកំពង់ផែស្វយ័តនេះមានកំពង់ផែតូចៗដូចជា កំពង់ផែស្រែអំបិល (ផ្ទុកបាន ១២០-១៣០ តោន) កំពង់ផែឧកញ្ញ៉ាម៉ុង (មានសកម្មភាពនាំទំនិញ ខ្នាតតូច)កំពង់ផែកំពត។ កំពង់ផែកោះកុងក៏ជាកំពង់ផែអន្តរជាតិដែលស្ថិតនៅក្បែរព្រំដែនថៃប្រើ សម្រាប់តែទូកតូចៗ និងជាកំពង់ផែសំខាន់សម្រាប់ការនេសាទ។ កំពង់ផែនេះទទួលទូកមានទម្ងន់ ៣០០តោន ប៉ុណ្ណោះដែលអាចឆ្លងកាត់ឆកកោះកុងបាន ឬ៥០០តោន នៅកន្លែងចតនាវា។ នាវាភាគច្រើនដែលមកពីប្រទេសសង្ហបុរី ប្រទេសមាឡេស៊ី និងប្រទេសថៃ ចូលចតនៅបាកលង់ នៅឈូងសមុទ្រថៃមានចម្ងាយ ១៥គីឡូម៉ែត្រពីព្រំដែនថៃ។ ចំណែកកំពង់ផែកំពតស្ថិតនៅទីក្រុងលើ ច្រាំងទន្លេរមានចម្ងាយ ៤គីឡូម៉ែត្រពីសមុទ្រ។ កំពង់ផែកំពតជាកំពង់ផែដ៏សំខាន់នៃការធ្វើពាណិជ្ជកម្ម ជាប្រចាំជាមួយខេត្ត

---

[82] ហង់ ជួនណារ៉ុន, *ទស្សនាទានស្តីពីវិវាទព្រំដែនកម្ពុជា-ថៃក្នុងបរិបទនៃយុត្តិសាស្ត្រអន្តរជាតិ*(២០១៣), ៦៧។

[83] កិច្ចព្រមព្រៀងស្តីពីដែនទឹកប្រវត្តិសាស្ត្រនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងសាធារណរដ្ឋប្រជាមានិតកម្ពុជា, ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ១៩៨២។

[84] Port in Cambodia, ចូលទស្សនាថ្ងៃទី 14/05/17 http://www.business-in-asia.com/cambodia/cambodia_ports.html

កោះកុងក្នុងការផ្លាស់ប្តូរទំនិញពីថៃ ប៉ុន្តែកំពង់ផែនេះមិនមែនជាកំពង់ផែសម្រាប់ ចរាចរណ៍អន្តរជាតិទេ។

កំពង់សមុទ្របានដើរតួនាទីយ៉ាងសំខាន់សម្រាប់វិស័យសេដ្ឋកិច្ច និងការធ្វើពាណិជ្ជកម្ម។ ដូច្នេះ បានជាកំពង់ផែបានទទួលការយកចិត្តទុកដាក់យ៉ាងខ្លាំង រាជរដ្ឋាភិបាលមានគំរោងអភិវឌ្ឍកំពង់ផែថ្មី នៅក្នុង ស្រុកគីរីសាគរ ខេត្តកោះកុងដែលជាច្រកទឹកជ្រៅ។ ស្ទឹងហាវ នៅខេត្តព្រះសីហានុជាច្រក អន្តរជាតិ និងខេត្តកែបជាច្រកទេសចរណ៍[85]។ នៅឆ្នាំ២០១៣ កម្ពុជាបានចុះហត្ថលេខាលើអនុស្សរណ យោគយល់គ្នាលើកំពង់ផែស្វយ័តក្រុងព្រះសីហានុ ក្នុងការនាំចេញផលិតផលដោយផ្ទាល់ពីកម្ពុជាទៅ ប្រទេសចិន។ ការពង្រីកកំរិតកំពង់ផែឲ្យមានភាពទំនើបបានធ្វើឲ្យពាណិជ្ជកម្មរវាងកម្ពុជា និងចិន បាន កើនដល់ ៣,៧៧ពាន់លានដុល្លា។ ហើយរាជរដ្ឋាភិបាលមានគោលដៅកំណត់ឲ្យបាន ៥ ពាន់លាន ដុល្លា។[86] ហើយកាលពីពេលថ្មីៗនេះមានការប្រកាសលក់ភាគហ៊ុនកំពង់ផែស្វយ័តក្នុងតម្លៃ ៥ ៣៦០ រៀល ក្នុងគោលដៅឲ្យកំពង់ផែមានការរីកចំរើន។[87]

### ២.២.១.២ តំបន់សមុទ្រដែនដី

តំបន់សមុទ្រដែនដីត្រូវបានបង្កើតឡើងនៅក្នុងតំបន់នេសាទផ្តាច់មុខ (៣ម៉ាល) ដែលធ្វើដោយ អាណានិគមបារាំងនៅឆ្នាំ១៩២៦។ បន្ទាប់មកតំបន់នេះត្រូវបានពង្រីកពី ៣ ម៉ាលទៅជា២០ ម៉ាលដោយ បានកំណត់តំបន់នេសាទផ្តាច់មុខហាមមិនឲ្យនេសាទបរទេសចូលបាន។ កម្ពុជាបានធ្វើការអះអាងពី អធិបតេយ្យពេញទាំងស្រុងរបស់ខ្លួននៅសមុទ្រដែនដីដែលបានពង្រីកទៅជា ១២ម៉ាល រាប់ពីខ្សែបន្ទាត់ មូលដ្ឋាន ផ្អែកតាមក្រឹត្យនៅឆ្នាំ ១៩៦៩ ១៩៧៨ និង១៩៨២។ ចំពោះព្រំដែនសងខាងនៃសមុទ្រ ដែនដី ជាមួយថៃស្ថិតនៅចន្លោះកោះគុត និងចំនុចចុងបង្អស់ព្រំដែនគោកកម្ពុជា-ថៃដល់ព្រំប្រទល់ សមុទ្រដែន ដីតាមខ្សែបែងចែកទឹកសមុទ្រដែលកំណត់ដោយព្រំដែនទឹកប្រវត្តិសាស្ត្រ[88]។យោងតាមព្រំដែននៃស មុទ្រដែនដីចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧២ កម្ពុជាបានចែងពីសិទ្ធិ និងសមត្ថកិច្ចរបស់រដ្ឋនៅតំបន់ស មុទ្រដែនដីដូចជានាវារបស់រដ្ឋជាប់ឆ្នេរ ឬមិនជាប់ឆ្នេរមានសិទ្ធិឆ្លង

---

[85] ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា CDC, គណកម្មការវិនិយោគកម្ពុជា CIB, គណកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជាCSEZB. កំពង់ផែសមុទ្រ, http://www.cambodiainvestment.gov.kh/investors-information/infrastructure/sea-port.html

[86] Chinese Investors focusing on Sihanoukville port,Khmer Time, lasted accessed 09/June/2017 http://www.khmer-timeskh.com/news/17010/chinese-investors-focusing-on-sihanoukville-port/

[87] កម្ពុជាថ្មី, " ភាគហ៊ុនកំពង់ផែស្វយ័តក្រុងព្រះស៊ីហានុ បើកលក់ជាផ្លូវការ," http://kampucheathmey.com/2016/archives/639158

[88] ក្រឹត្យស្តីពីការកំណត់ព្រំដែនសមុទ្រកម្ពុជា និងខ្លង់រាបបាតសមុទ្រនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា, ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៨២ មាត្រា៣។

កាត់ដោយស្មោះត្រង់ក្នុងដែនសមុទ្រនិងអធិបតេយ្យលាតសន្ធឹង ទៅដល់លំហអាកាសពីលើសមុទ្រដែនដី បាត និងដីក្រោមសមុទ្រនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខ[89]។ ម្យ៉ាងទៀតកម្ពុជាបានអនុវត្តតាម UN-CLOS លើសមុទ្រដែនដីកម្ពុជាមានសេរីភាពនាវាចរណ៍ ការពារខ្សែកាប បំពង់នាំប្រេង និងឧស្ម័ន ការអភិរក្សធនធានជីវសាស្ត្រ ការទប់ស្កាត់បទល្មើស ទាក់ទងពន្ធ គយ សុខាភិបាល ការនេសាទ អន្តោប្រវេសន៍ ការការពារបរិស្ថាន និងការស្រាវជ្រាវជីវសាស្ត្រសមុទ្រ[90] ហើយនាវាបរទេសត្រូវតែ គោរពសិទ្ធិឆ្លងកាត់ស្មោះត្រង់ដោយមិនបង្ករឲ្យប៉ះពាល់ដល់ឆ្នេរសមុទ្ររបស់កម្ពុជា។

### ២.២.២ តំបន់សិទ្ធិអធិបតេយ្យ

រដ្ឋឆ្នេរសមុទ្រមានសិទ្ធិអធិបតេយ្យ និងយុត្តាធិការលើតំបន់ខ្ពង់រាបបាតសមុទ្រ តំបន់សេដ្ឋកិច្ចផ្តាច់មុខ និងតំបន់តជាប់ ប៉ុន្តែមិនមានយុត្តាធិការពេញលេញទាំងស្រុងនោះទេ។ រដ្ឋអាចមានសិទ្ធិ សេរីភាព ប្រើប្រាស់ក្នុងវិស័យខ្លះក្នុងតំបន់ទាំងនេះតាមច្បាប់របស់រដ្ឋជាប់ឆ្នេរបានចែង។

#### ២.២.២.១ តំបន់តជាប់ និងតំបន់សេដ្ឋកិច្ចផ្តាច់មុខ

តំបន់តជាប់ជាលំហសមុទ្រដែលលាតសន្ធឹងបន្តពីសមុទ្រដែនដី តាមច្បាប់សមុទ្រអន្តរជាតិ បានកំណត់ចម្ងាយ ១២ម៉ាល បន្ទាប់ពីសមុទ្រដែនដី។ រដ្ឋជាប់ឆ្នេរពុំមានអធិបតេយ្យភាពរបស់ខ្លួន ពេញទាំងស្រុង រដ្ឋអាចមានអំណាចអនុសិទ្ធិលើវិស័យខ្លះ ដែលទាក់ទង់និងសិទ្ធិគយ នគរបាល (សិទ្ធិដេញចាប់លើបទល្មើសជាក់ស្តែង សិទ្ធិចាប់ខ្លួនលើការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្ម បទក្លែង បន្លំពន្ធដារ គយ)[91]។ តាមមាត្រា៣ ក្នុងក្រឹត្យ ៦៦២ ឆ្នាំ១៩៥៧ កម្ពុជាបានកំណត់ដែនវិសាល ភាពនៃតំបន់តជាប់ "ទទឹងនៃតំបន់តជាប់របស់កម្ពុជាដែលគិតចាប់ពីព្រំប្រទល់ខាងក្រៅនៃសមុទ្រដែនដីត្រូវកំណត់ត្រឹម ៧ម៉ាល"[92] ។ បន្ទាប់មកតំបន់តជាប់ត្រូវបានកំណត់មិនឲ្យលាតសន្ធឹងលើសពី ១២ម៉ាលទេ។ រដ្ឋចង់ពង្រីកដែនអធិបតេយ្យរបស់ខ្លួនឲ្យកាន់តែធំ និងជាក់លាក់តាមច្បាប់អន្តរជាតិ ដោយរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាចេញក្រឹត្យមួយនៅឆ្នាំ ១៩៨២ ក្នុងមាត្រា៤ បានចែងពីតំបន់តជាប់របស់កម្ពុជាជាលំហសមុទ្រដែលលាតសន្ធឹងបន្តពីសមុទ្រដែនដី និងមាន ចម្ងាយ ១២ម៉ាល។ កម្ពុជាមានសិទ្ធិលើការអនុវត្តការត្រួតពិនិត្យនានា ដើម្បីរក្សាសន្តិសុខ ទប់ស្កាត់បទ ល្មើសដែលពាក់ព័ន្ធនិងច្បាប់គយ សារពើពន្ធ សុខាភិបាល និងអន្តោប្រវេសន៍។

[89] សេចក្តីថ្លែងការ របស់កម្ពុជាប្រជាធិបតេយ្យនៅសម័យប្រជុំទី៤ នៃសន្និសិទ្ធលើកទី៣ របស់អង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ, ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ១៩៧៦។

[90] ហង់ ជួនណារ៉ុន, *ទស្សនាទានស្តីពីវិវាទព្រំដែនកម្ពុជា-ថៃក្នុងបរិបទនៃយុត្តិសាស្ត្រអន្តរជាតិ*(២០១៣), ៦៨។

[91] លោក ឃឹម ឈុនអ៊ី, *ច្បាប់អន្តរជាតិសាធារណៈច្បាប់សមុទ្រ*(២០០២), ២៥។

[92] ក្រឹត្យស្តីពីការកំណត់ព្រំដែនសមុទ្រដែនដី, លេខ 662, ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៥៧។

រដ្ឋភាគច្រើនបង្កើតតំបន់សេដ្ឋកិច្ចរបស់ខ្លួនក្នុងចម្ងាយ ២០០ម៉ាល (៣៧០ គីឡូម៉ែត្រ) ពីខ្សែបន្ទាត់មូលដ្ឋាន។ ច្បាប់អន្តរជាតិបានកំណត់សិទ្ធិ និងយុត្តាធិការឲ្យរដ្ឋជាប់ឆ្នេរ ផ្តល់សេរីភាពឲ្យ រដ្ឋដទៃទៀតក្នុងការប្រើប្រាស់សិទ្ធិក្នុងតំបន់នេះ។ កម្ពុជាបានកំណត់តំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ខ្លួន ក្នុងចម្ងាយ ២០០ម៉ាល ក្នុងមាត្រា៤ នៃក្រឹត្យ ១៩៨២ ហើយក៏បានថែងពីសិទ្ធិ អធិបតេយ្យផ្តាច់មុខ ក្នុងការរុករក ធ្វើអាជីវកម្ម អភិរក្ស គ្រប់គ្រងធនធានសេរីវាង្គ ឬអសេរីវាង្គក្នុងបាតសមុទ្រ លើទឹក និងក្រោមដី។ លើសពីនេះកម្ពុជានបានថែងថាប្រសិនបើគ្មានការអនុញ្ញាត ឬការព្រមព្រៀងពីកម្ពុជា នាវាបរទេសទាំងអស់ហាមមិនឲ្យនេសាទ ឬធ្វើអាជីវកម្មលើធនធានធម្មជាតិការស្រាវជ្រាវវេជ្ជ សាស្ត្រណាមួយ។ ទោះបីទទួលការអនុញ្ញាតពីកម្ពុជាក៏រដ្ឋ ឬនាវាបរទេសត្រូវគោរពច្បាប់ និងបទបញ្ជា របស់រដ្ឋ (ការអនុញ្ញាតចំពោះរដ្ឋទាំងនេះបានតែក្នុងគោលបំណងពាណិជ្ជកម្ម)[93]។ នៅតំបន់សេដ្ឋកិច្ចផ្តាច់ មុខរដ្ឋដទៃទៀតពុំជាប់ឆ្នេរមានសេរីភាពធ្វើចរាចរណ៍ដោយសេរី ការហោះហើរពីលើការដាក់ខ្សែកាប បំពង់នាំប្រេងឧស្ម័នក្រោមសមុទ្រ និងសេរីភាពប្រើប្រាស់សមុទ្រដោយស្របច្បាប់។[94]

**២.២.២.២ តំបន់ខ្ពង់រាបបាតសមុទ្រ**

តំបន់ខ្ពង់រាបបាតសមុទ្រជាតំបន់ដែលផ្តល់សិទ្ធិលើជីវធនធានធម្មជាតិចម្រុះ និងរ៉ែផ្សេងទៀត ដូចតំបន់សេដ្ឋកិច្ចផ្តាច់មុខដែរ។ តំបន់ខ្ពង់រាបបាតសមុទ្រកម្ពុជា ជាតំបន់ដែលមានការទាមទារច្រើន។ នៅឆ្នាំ ១៩៥៧ កម្ពុជាបានធ្វើការទាមទារតំបន់នេះនៅឈូងសមុទ្រថៃក្នុងជម្រៅ ៥០ម៉ែត្រ រហូតដល់ឆ្នាំ ១៩៦៩ កម្ពុជាបានអះអាងអធិបតេយ្យពេញលេញលើតំបន់នេះ។ ពីព្រោះកាលពីឆ្នាំ១៩៥៧ កម្ពុជាមិន ទាន់ទាមទារអះអាងលើអធិបតេយ្យរបស់ខ្លួនទេ។ កម្ពុជាបានអនុវត្តតាមអនុសញ្ញាម៉ុងតេហ្គោបៃ (២០០ម៉ាល) ទោះបីមិនបានផ្តល់សច្ចាប័នលើអនុសញ្ញានេះក៏ដោយ។ ម៉្យាងទៀតកម្ពុជាបានកំណត់ ព្រំដែនខ្ពង់រាបបាតសមុទ្រជាកម្មសិទ្ធិរបស់កម្ពុជា និងកំណត់និយមន័យថា ខ្ពង់រាបបាតសមុទ្រជាបាត សមុទ្រដីក្រោមដីដែលបន្តពីឆ្នេរ។ ប៉ុន្តែស្ថិតនៅក្រៅសមុទ្រដែនដីបន្តរហូត ដល់ជម្រៅ ២០០ម៉ាល ដល់តំបន់ដែលអាច ធ្វើអាជីវកម្មធនធានធម្មជាតិក្នុងតំបន់នេះបាន[95]។

សាធារណរដ្ឋខ្មែរបានចេញក្រឹត្យលេខ ៤៣៩/៧២ ក្នុងការបញ្ជាក់ថាខាងជើងរវាងតំបន់ខ្ពង់រាបបាតសមុទ្រស្ថិតក្នុងអធិបតេយ្យរៀងខ្លួនរបស់កម្ពុជា-ថៃ ដោយបង្កើតខ្សែបន្ទាត់ត្រង់មួយដែលភ្ជាប់ពីចំ-នុច "A" លើឆ្នេរទៅកំពូលបំផុតនៃកោះគុក "S" លាតរហូតដល់ "P" [96] ( P ជាចំនុចសម

[93] លោក ឃឹម ឈុនអ៊ី, *ច្បាប់អន្តរជាតិសាធារណៈ ច្បាប់សមុទ្រ*(២០០២), ២៥។

[94] សេចក្តីថ្លែងការ របស់កម្ពុជាប្រជាធិបតេយ្យនៅសម័យប្រជុំទី៤ នៃសន្និសិទ្ធលើកទី៣ របស់អង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ, ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ១៩៧៦។

[95] ហង់ ជួនណារ៉ុន, *ទស្សនាទានស្តីពីវិវាទព្រំដែនកម្ពុជា-ថៃក្នុងបរិបទនៃយុត្តិសាស្ត្រអន្តរជាតិ*(២០១៣), ទំព័រ ៨០។

[96] ក្រឹត្យស្តីពីការកំណត់ព្រំដែនខ្ពង់រាបបាតសមុទ្ររបស់សាធារណខ្មែរ, លេខ ៤៣៩/៧២, ចុះថ្ងៃទី០១ ខែមករា ឆ្នាំ១៩៧២។

ចម្ងាយ រវាងកោះ តូស្រេីកម្ពុជា និងកោះថូជូវៀតណាម ចំណុចខាងលិចនៃកោះគុត ជាកោះព្រំដែនថៃ ខាងកើតនៃ កោះភូគុក និងកោះថូជូជាព្រំដែនវៀតណាម)។ ព្រំដែនសង់ខាងនៃខ្ពង់រាបបាតសមុទ្រ ជាមួយ វៀតណាម ផ្អែកលើសន្ធិសញ្ញាស្តីពីតំបន់ទឹកប្រវត្តិសាស្ត្របានឲ្យកោះពូឡូវ៉ៃឲ្យកម្ពុជា កោះភូគុក(កោះត្រល់)និងកោះថូជូឲ្យវៀតណាម។

តំបន់ខ្ពង់រាបបាតសមុទ្ររបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា បានកំណត់សិទ្ធិផ្តាច់មុខលើការរុករក ការធ្វើអាជីវកម្ម អភិរក្ស និងការគ្រប់គ្រងធនធានធម្មជាតិរាប់បញ្ចូលរ៉ែ និងអសរីរាង្គ។ ចំពោះរដ្ឋបរទេសដែលចង់ធ្វើសកម្មភាពនានានៅក្នុងខ្ពង់រាបបាតសមុទ្រត្រូវបានអនុញ្ញាត ឬព្រម ព្រៀងពីរាជរដ្ឋាភិបាលជាមុនសិន។ បន្ថែមពីនេះរដ្ឋត្រូវគោរពច្បាប់វិធានរបស់រដ្ឋឆ្នេរនេះ និងដោះ ស្រាយការប្រើប្រាស់សម្ភារសមុទ្រសិប្បនិម្មិត[97]។

### ២.២.៣ កោះរបស់ប្រទេសកម្ពុជា

កោះជាផ្ទៃដីធម្មជាតិដែលមានទឹករព័ទ្ធជុំវិញ និងអាចមើលឃើញបាននៅពេលមានទឹកជោរ តាមមាត្រា១២១ នៃUNCLOS។ លើសពីនេះកោះនីមួយៗ អាចមានសមុទ្រដែនដី តំបន់តជាប់ តំបន់សេដ្ឋកិច្ចផ្តាច់មុខ និងតំបន់ខ្ពង់រាបបាតសមុទ្រ។ ចំពោះកោះដែលមិនមានលទ្ធភាពជាជំរក របស់មនុស្ស ឬប្រើជីវភាពសេដ្ឋកិច្ច កោះនោះមិនអាចមានតំបន់សេដ្ឋកិច្ចផ្តាច់មុខ និងតំបន់ខ្ពង់រាបបាត សមុទ្របានទេ[98]។ កោះជាផ្នែកសំខាន់យកសម្រាប់កំណត់ព្រំដែនសមុទ្រដោយ សារមានសមត្ថភាព បង្កើតលំហសមុទ្រផ្ទាល់ ប្រើសម្រាប់ជាចំណុចនៃខ្សែបន្ទាត់មូលដ្ឋានត្រង់ ឬចំណុចមូលដ្ឋាន។ កោះពូឡូវ៉ៃអាចបង្កើតលំហរផ្ទាល់ខ្លួន ដែលផ្អែកតាមអនុសញ្ញាច្បាប់សមុទ្រអន្តរជាតិ។ នៅប៉ែកខាង កើតក្បែរឆ្នេរនៃឈូងសមុទ្រថៃមានកោះ និងកូនកោះប្រមាណ ២០០ ផ្តុំគ្នា។ តាមបណ្តោយឆ្នេររបស់ កម្ពុជាមានឆក (ឆកជាផ្នត់សមុទ្រដែលផតចូលក្នុងដី) ចំនួន ៥ គឺ ឆកកោះកុង ឆកកំពង់សោម ឆករាម ឆកទឹកសាប និងឆកវាលរេញ។ ឆកសំខាន់ជាងគេ គឺជាឆកកំពង់សោមមានលក្ខណៈជាឆកប្រវត្តិ សាស្ត្រ[99]។

- កោះនៃឆកកោះកុងរួមមានកោះកុង (11°20N; G: 103 °00E) ជាកោះធំជាង គេបំផុតរបស់កម្ពុជាប្រហែល ៨០ គីឡូម៉ែត្រក្រឡា មានកំពស់ ៩១០ម៉ែត្រ និងដាច់ពីដីគោក ដោយរបាក់ភ្នំនៃបន្ទុះភ្នំភ្លើង (ខាងលិចនៃកោះសំបូរផ្ទាំងថ្មក្រហោង ក្រហូង)។ កោះកុង

[97] ក្រឹត្យស្តីពីការកំណត់ព្រំដែនសមុទ្រកម្ពុជា និងខ្ពង់រាបបាតសមុទ្រ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា, ចុះ ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ១៩៨២។

[98] លោក ឃឹម ឈុនអ៊ី, *ច្បាប់អន្តរជាតិសាធារណៈ ច្បាប់សមុទ្រ* (២០០២), ៥៧។

[99] ហង់ ជូនណារ៉ុន, *ទស្សនាទានស្តីពីវិវាទព្រំដែនកម្ពុជា-ថៃក្នុងបរិបទនៃយុត្តិសាស្ត្រអន្តរជាតិ*(២០១៣), ១៦១,១៦២។

មានប្រជាជនរស់ ភាគច្រើន ជាអ្នកនេសាទ និងអ្នកចំការរស់នៅ។ កោះគូស្រូវី (L: 11 °06,8N; G: 102 °47,5E) ជាកូនកោះថ្ម។ កូនកោះតាប កូនកោះកូនសត្វ (L: 11 °03,5; G: 102° 04,5) ។ ចង្កោមកូនកោះថ្មនៅ អមបណ្តោយឆ្នេរសមុទ្រជុំវិញកំពូលស្រួចកោះស្មាច់ មានកោះសាមិត (L: 10 ° 54,80; G: 103° 02) កោះថ្ម (L:10° 29, G: 104° 11,5) កូនកោះតុ កូនកោះថ្ម(L: 11° 00N, G: 103° 02,7)

- កោះនៃឆកសមុទ្រកំពង់សោមមាន (L: 10° 51, G: 103 ° 09) កោះម្នាស់ (L: 10° 49, G: 103 ° 10) កោះរ៉ុង (L: 10° 43,1; G: 103° 14) កោះរុងសន្លឹម (L:10° 35, G: 103° 17,3) កោះថាស (L: 10° 36,6; G: 103° 25) កោះពស់(10° 33,7; G: 103° 28,8) កោះកណ្តុរ (L: 10° 43,8; G: 102° 47,6)។ កោះរ៉ុង និងកោះរ៉ុសសន្លឹមនៅមុខឆកកំពង់សោម និងមាន ប្រជាជនអ្នកនេសាទរស់នៅភ្ជាប់ដីគោក ដោយចង្កោមកោះ។
- កោះនៃឆករាម ពីខេត្តព្រះសីហនុដល់ឆកវាលរេញមាន កោះត្រេះ (L: 10° 33,5; G: 103° 32) កោះច្រឡោះ (L: 10° 32, G: 103° 33) កោះក្របី (L:10° 31, G:103° 34) កោះឬស្សី (L:10° 30, G:103° 33,5) កោះតាកៀវ (L:10° 30, G:103° 35) កោះស្រមោច (L:10° 30; G:103° 35) កោះថ្មី (L:10° 28, G:103° 46) កោះសេះ (L:10° 25, G:103° 48) កោះព្រីង (L:10° 22,5; G:105° 57) កោះវារ (L:10° 14; G:102° 52) កោះតាង (L:10° 15,3; G:103° 10,0) ជាក្រុមកោះមានអ្នកនេសាទ និងកសិកររស់នៅ។
- កោះនៃឆកវាលរេញមាន កោះក្រាស់ កោះម៉ាក់ប្រាង កោះអន់តៃ(L:10° 26) កោះពោ (L:10° 24; G:104° 20) កោះអង្រ្កង (L:10° 22; G:104° 18) កោះសេះ (L:10° 21; G:104° 19) កោះស្វាយ និងកោះត្បាល់។
- ក្រុមកោះពូឡូវៃ (កោះអាចម៍សេះL:09° 55; G:102° 53) មានរយកម្ពស់ ៩១ម៉ែត្រ និងកោះដេប៉ុងមានរយកម្ពស់ ០,៨ម៉ែត្រ។ កោះពូឡូវៃមានព្រលានយន្តហោះ។[100]

[100] ហង់ ជួនណារ៉ុន, ទស្សនាទានស្តីពីវិវាទព្រំដែនកម្ពុជា-ថៃក្នុងបរិបទនៃយុត្តិសាស្ត្រអន្តរជាតិ(២០១៣), ១៩៥,១៩៦។

# ជំពូក៣

# ធនធានសេដ្ឋកិច្ចសមុទ្រ

ដែនសមុទ្រនៃឈូងសមុទ្រថៃមានប្រវែង ២ ៤៦០ គីឡូម៉ែត្រស្ថិតនៅខ្ពង់រាបបាតសមុទ្រមានលក្ខណៈមិនសូវជ្រៅ(ជម្រៅមិនហួសពី ១០០ម៉ែត្រ)[101]។ ឈូងសមុទ្រនេះសម្បូរដោយធនធានធម្មជាតិ និងមានដីមានជីវជាតិដោយសារមានការច្រោះដីមានជីជាតិពីទន្លេ និងស្ទឹងបឹងបួរហូរចាក់ចូលក្នុងសមុទ្រ។ ការអំណោយផលនៃជម្រៅរាក់ និងមានលក្ខណៈសម្បូរបែបខាងជីវសាស្ត្រក្នុងទឹក សមុទ្រ បានជាឈូងសមុទ្រមានពូជវន្តជាតិ និងមច្ឆាសមុទ្រច្រើនប្រភេទដែលជាទីចាប់អារម្មណ៍ក្នុងការធ្វើ អាជីវកម្មពីបរទេស រួមមានធនធានធម្មជាតិមានជួរថ្មផ្កាថ្ម ផូស៊ីល ប្រេងកាត រ៉ែ និងឧស្ម័នធម្មជាតិ នៅបាតសមុទ្រ ព្រមទាំងមានឆ្នេរមានទេសភាពស្អាតដែលជាទីទាក់ទាញទេសចរណ៍។ ម៉្យាងទៀតឆ្នេរ នៃឈូងសមុទ្រនៅជាប់ឆ្នេរទឹកសាប និងទឹកប្រៃនាំឲ្យសម្បូរដើមកោងកាងដែលជាប្រព័ន្ធអេកូឡូស៊ី។ ធនធានទាំងអស់នេះមិនត្រឹមតែមានសារសំខាន់លើជីវចម្រុះនៃប្រព័ន្ធអេកូឡូស៊ីតែម្យ៉ាងនោះទេ តែធនធាននេះបានផ្តល់ប្រយោជន៍លើ ប្រព័ន្ធសេដ្ឋកិច្ចចំពោះបណ្តាលប្រទេសស្ថិតនៅជុំវិញឈូងសមុទ្រថៃ។ ក្នុងចំនោមប្រទេសទាំងនេះតំបន់សមុទ្រកម្ពុជាបានគ្រប់ដណ្តប់ ៤៣៥គីឡូម៉ែត្រ តាមបណ្តោយឈូង ហើយរួមមានខេត្តកោះកុង កំពត ក្រុងព្រះសីហនុ និងខេត្តកែប។ តំបន់ឆ្នេររបស់ កម្ពុជាបានបង្កើត ប្រព័ន្ធពីរទាក់ទងគ្នាគឺ ប្រព័ន្ធអេកូឡូស៊ី(ធនធានធម្មជាតិផ្តល់ឲ្យ មនុស្ស និងសភាវរស់នៅ) និងប្រព័ន្ធសេដ្ឋកិច្ចសមុទ្រដែលអាស្រ័យលើ មុខងារអាជីវកម្ម និងផលិតផលនៃប្រព័ន្ធអេកូឡូស៊ី។[102] តំបន់សមុទ្រកម្ពុជាមានធនធានធម្មជាតិ រ៉ែ ប្រេងកាត ឧស្ម័ន និងធនធានផ្សេងទៀតជាច្រើន។ បន្ថែមពីនេះ តំបន់សមុទ្រកម្ពុជាបានផ្តល់អំណោយផលលើការនេសាទ ដែលជាផ្នែកមួយដ៏សំខាន់ ក្នុងវិស័យសេដ្ឋកិច្ច និងផ្គត់ផ្គង់ជីវភាពប្រជាជនរស់នៅតំបន់ឆ្នេរ ។

## ៣.១ ធនធានរ៉ែប្រេងកាត និងឧស្ម័ន

ធនធានរ៉ែប្រេងកាត និងឧស្ម័ននៅឈូងសមុទ្រថៃមានច្រើនសន្ធឹកសន្ធាប់ណាស់។ ប្រទេសខ្លះនៅ តាមបណ្តោយឈូងសមុទ្រមិនទាន់បានទាញយករ៉ែទេ។ ក្នុងនោះប្រទេសកម្ពុជាក៏ជាប្រទេសដែលកំពុងតែ ធ្វើការស្រាវជ្រាវ ក៏ប៉ុន្តែមិនទាន់បានទាញយកប្រេងដែរ។ កម្ពុជាមានសកម្ម ភាព រុករករ៉ែលើកដំបូងនៅ ឆ្នាំ១៩៥០ ដោយក្រុមស្រាវជ្រាវភូគក្កវិទូចិន។ បន្ទាប់មកក្រុមហ៊ុនបារាំងអែហ្វ EIF បានជីកអណ្តូងដំបូង គេរកឃើញថាប្រេងមានលក្ខណៈស្ងួត ។ កម្ពុជាបានបែងចែកការរុករកប្រេង

---

[101] គណៈកម្មាធិការព្រំដែនកម្ពុជា, *ព្រំដែនដី និងសមុទ្រនៃប្រទេសកម្ពុជាឆ្នាំ ២០០០*(១៩៩៩-២០០១), ៩។

[102] WEPA, State of water environment issues, ទស្សនា ថ្ងៃទី ១៤ ខែឧសភា ឆ្នាំ២០១៧

និងឧស្ម័នជា៣ តំបន់គឺ តំបន់ដីគោកមាន ១០ប្លុក តំបន់ដែនសសមុទ្រស្ថិតនៅក្រោមអធិបតេយ្យពុំមានទំនាស់មានចំនួន៦ ប្លុក(A-F) និងតំបន់ទំនាស់រវាងខ្មែរ ថៃដែលដ្ឋិតនៅភាគខាងលិចដែន សមុទ្រកម្ពុជាហៅថា តំបន់ត្រួតស៊ី គ្នា(OCA)មាន៩តំបន់។

### ៣.១.១ តំបន់រ៉ែពុំមានជម្លោះក្នុងប្រទេសកម្ពុជា

តំបន់ដែនសមុទ្រកម្ពុជាពុំមានជម្លោះ (A-F) ក្នុងនោះមាន ប្លុកA: ៦ ២៧៨គីឡូម៉ែត្រការ៉េប្លុកB: ៦ ៣៩៧គីឡូម៉ែត្រការ៉េ ប្លុកC: ៥៥២១គីឡូម៉ែត្រការ៉េ ប្លុកD: ៥ ២៩៦ គីឡូម៉ែត្រការ៉េ ប្លុកE: ៤ ៨២៨គីឡូម៉ែត្រការ៉េ ប្លុកF: ៥ ២៥២ គីឡូម៉ែត្រការ៉េ។[103] នៅក្នុងឆ្នាំ ១៩៩១ ប្លុកមួយចំនួនត្រូវបាន ផ្តល់ឲ្យក្រុមហ៊ុន Enterprise oil ក្រុមហ៊ុន Cambodian Petroleum (complex, Japen) និងក្រុមហ៊ុន Premier oil (អង់គ្លេស)។ រហូតដល់ឆ្នាំ១៩៩៧ ប្លុកពីរទៀតត្រូវបានផ្តល់ឲ្យក្រុមហ៊ុន Woodside Energy (អូស្ត្រាលី) ក្រុមហ៊ុនបានចុះហត្ថលេខាកិច្ចព្រមព្រៀងស្រាវជ្រាវរួមគ្នាដើម្បីវាយតម្លៃ ប្រេងនៅតំបន់ សមុទ្រនេះ។ បន្ទាប់ពីទទួលបានលទ្ធផលនៃការស្រាវជ្រាវ គ្រប់ប្លុកទាំងអស់ត្រូវបានប្រគល់ឲ្យ ក្រុមហ៊ុនឯកជន។ ប្លុក A ដែលជាប្លុកទី១ត្រូវបានរដ្ឋាភិបាលបានផ្តល់ឲ្យក្រុមហ៊ុនឯកជន ប៉ុន្តែនៅឆ្នាំ ២០០៧ ផ្ទៃក្រឡាប្រមាណ ២៥% បានប្រគល់ឲ្យអាជ្ញាធរប្រេងកាតជាតិកម្ពុជាវិញតាមកិច្ចសន្យាបែង ចែកការផលិត។ រដ្ឋាភិបាលបានចុះកិច្ចសន្យាបែងចែកការផលិតជាមួយក្រុម ហ៊ុន Chevron ក្នុងការរុក រកអណ្តូងចំនួន ១៥។ ដែរការរុករកនោះត្រូវបានចាប់ផ្តើមខួង ក្នុងនោះអណ្តូង៥បានខួងនៅឆ្នាំ ២០០៤-២០០៥ ៥អណ្តូងទៀតឆ្នាំ២០០៦ ចំណែក៥ចុងក្រោយឆ្នាំ២០០៧។ ក្នុងពេលខួង បានរកឃើញ អណ្តូង៤មានប្រេងកាត និងអណ្តូង១មានឧស្ម័ន។ ប្រេងកាតនៅក្នុងប្លុកA មានកំរិត បរិមាណទាប ក្រុមហ៊ុនរុករក Chevron បានប្រកាសថាអាចទាញយកប្រេងបានតែ ១៥%ប៉ុណ្ណោះ ដែលប៉ានប្រមាណ ស្ថិតចន្លោះពី ៨០ ដល់ ១០០លានធុង ។

### ៣.១.២ តំបន់រ៉ែមានជម្លោះក្នុងប្រទេសកម្ពុជា

តំបន់ជម្លោះ រដ្ឋាភិបាលបានចែកជា ៤តំបន់មាន៩ប្លុក។ ក្រុមហ៊ុនប្រេងកាត Conoco Philips (សហរដ្ឋអាមេរិច) និងក្រុមហ៊ុន Idemitsu (ជប៉ុន) ត្រូវបានរដ្ឋាភិបាលប្រគល់តំបន់ I និងII សម្រាប់រយៈពេលមិនកំណត់។ ចំណែកតំបន់III ប្រគល់ឲ្យក្រុមហ៊ុន Shell និងក្រុមហ៊ុន BHP ប៉ុន្តែនៅឆ្នាំ២០០៧ ត្រូវប្រគល់ឲ្យក្រុមហ៊ុន Total វិញ ចំណែកតំបន់IV នៅទំនេរ។ ថៃបានសម្បទានប្រេងកាតទៅឲ្យក្រុមហ៊ុន Chevron នៅតំបន់ជម្លោះ (តំបន់ត្រួតស៊ីគ្នាដែល សម្បូរដោយរ៉ែប្រេងកាតច្រើន)។[104]

---

[103] OpenDevelopment Cambodia , *oil and gas block* ចូលទស្សនាថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០១៧ https://opendevelopmentcambodia.net/profiles/oil-and-gas-blocks/

[104] ហាង ជូនណារ៉ុន, *ទស្សនាទានស្តីពីវិវាទព្រំដែនកម្ពុជា-ថៃក្នុងបរិបទនៃយុត្តិសាស្ត្រអន្តរជាតិ*(២០១៣), ២៦-២៩។

ទោះបីជាប្រេង និងឧស្ម័នត្រូវបានរកឃើញក្នុងដែនសមុទ្រកម្ពុជា ប៉ុន្តែប្រេង និងឧស្ម័នទាំងនេះមិនទាន់មានការទាញយកជាលក្ខណៈពាណិជ្ជកម្មនៅឡើយទេ។ ជាក់ស្តែង ផលិតផលប្រេងទាំងអស់កំពុងបម្រើតម្រូវការក្នុងស្រុកបានពីការនាំចូលដែលប៉ាន់ប្រមាណ ៥៥៣ ០០០ តោន ក្នុងរយៈពេល៣ ខែដំបូងក្នុងឆ្នាំ២០១៥[105]។ នៅឆ្នាំ២០១៦ ក្រុមហ៊ុន Kris Energy មានការចាប់អារម្មណ៍លើការគ្រប់គ្រងប្លុកA ក្នុងគោលបំណងផលិតប្រេង រដ្ឋាភិបាលបានផ្តល់ឲ្យ ក្រុមហ៊ុននេះជាម្ចាស់ ៩៥% និងអាជ្ញាធរប្រេងកាតជាតិកម្ពុជា មានភាគហ៊ុន ៥%នៅប្លុកA នេះ។ នៅឆ្នាំ២០១៧ ក្រុមហ៊ុនបានបង្ហាញពីការពិនិត្យឡើងវិញនូវកិច្ចសន្យាបែងចែកជាមួយរដ្ឋាភិបាលដែល បានបញ្ចប់ហើយខ្លួនក៏បានត្រៀមខ្លួនចុះហត្ថលេខាជាថ្មី (ឯកសារមួយនៃការអភិវឌ្ឍប្លុកនេះបានចុះ ហត្ថលេខាហើយ)។[106]

ធនធានរ៉ែប្រេង និងឧស្ម័ននៅកម្ពុជាមិនទាន់មានច្បាប់ជាក់លាក់ណាមួយបានចែងពីការគ្រប់គ្រងនៅឡើយទេ។ ក្នុងក្រមរដ្ឋធម្មនុញគ្រាន់តែចែងពីធនធាន រ៉ែ ទាំងអស់ជាសម្បត្តិរបស់រដ្ឋក្នុងមាត្រា៥៨ នៃក្រមរដ្ឋធម្មនុញ។ ប្រេង និងឧស្ម័នស្ថិតក្រោមការគ្រប់គ្រងដោយបទបញ្ញត្តិប្រេងកាតដែលបានធ្វើវិសោធនកម្មឆ្នាំ១៩៩១ ម៉្យាងទៀតរដ្ឋាភិបាលបានបង្កើតអាជ្ញាធរប្រេងកាតជាតិកម្ពុជា(CNPA) ស្ថិតក្រោមក្រសួងឧស្សាហកម្មរ៉ែ និងថាមពល (MIME) ដើម្បីគ្រប់គ្រងធនធានរ៉ែ និងប្រេងកាត។ ក្រសួងនេះទទួលខុសត្រូវការវាយតម្លៃសំណើរ និងផ្តល់អនុសាសន៍ដល់រដ្ឋាភិបាលលើកិច្ចព្រមព្រៀងប្រេងកាតជាមួយក្រុមហ៊ុននានា។[102]

### ៣.២ ការនេសាទ

នៅតាមឆ្នេរសមុទ្រប្រជាជនភាគច្រើនធ្វើអាជីវកម្មលើការនេសាទជាយូរមកហើយ។ ការនេសាទជា ផ្នែកសេដ្ឋកិច្ចដ៏សំខាន់សម្រាប់អ្នករស់នៅតំបន់ឆ្នេរ ការនេសាទត្រីសមុទ្រស្មើនិង ៣០% នៃវិស័យជលផល របស់ប្រទេសកម្ពុជាទាំងមូល។ នៅក្នុងសមុទ្រមានមច្ឆាច្រើនសន្ធឹកសន្ធាប់ដូចជាក្តាម បង្កង បបែល ឆ្លាម ត្រីស្បែកា និង ត្រីanchois មឹក (ត្រីយាវហឺ) បង្គា ដែលជាទីចាប់អារម្មណ៍របស់អ្នកនេសាទ។ ត្រីសមុទ្រ និងសត្វសមុទ្រទាំងអស់នេះមានតម្លៃខ្ពស់ ដែលដើរតួរយ៉ាងសំខាន់ក្នុងចំណែកវិស័យសេដ្ឋ កិច្ចជាតិ (ផ្អែកតាមUNEP 2007)។ ប្រាក់ចំណូលដែលទទួលបានពីការនាំចេញនៅឆ្នាំ២០០៦ ប្រមាណ ៦,៣៥លាន (វិទ្យាស្ថានសិក្សាស្រាវជ្រាវនិងបណ្តុះបណ្តាល២០១០) នេះមិនរាប់បញ្ចូលពីការនេសាទ ខុសច្បាប់ និងទូកនេសាទខុសច្បាប់ពីប្រទេសជិតខាង។[102]

---

[105] Opendevelopment Cambodia, *Oil and gas resourses* ចូលទស្សនា ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៧ https://opendevelopmentcambodia.net/topics/oil-and-gas-resources/

[106] *off-shore oil and gas block 2016-05-19* ចូលទស្សនាថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៧ https://opendevelopmentcambodia.net/topics/off-shore-oil-and-gas-exploration-and-extraction/

ភូមិអ្នកនេសាទមាននៅលើឆ្នេរសមុទ្រកម្ពុជានៃព្រំដែនថៃនៅ ព្រែកគគីរក្នុងនោះមានថ្មលក្របី បឹងក្រសាប កោះថៅលាវ កោះកាពិ។[107] អ្នកនេសាទភាគច្រើននៅខេត្តកំពតធ្វើការនេសាទ នៅជិតច្រាំងជាមធ្យមចម្ងាយ ៩គីឡូម៉ែត្រ ពីឆ្នេរ។ ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ និងការនេសាទក្នុងទឹករាក់ជាង ២០ម៉ែត្រ ដែលខុសទៅ និងច្បាប់កំណត់ជម្រៅជាមធ្យម ៥០ម៉ែត្រ ស្ថិតនៅ មាត់ឆ្នេរខាងកើតឈូងសមុទ្រ។[108] ម៉្យាងទៀតការនេសាទហួសប្រមាណដែលប៉ះពាល់ ដល់សារ៉ាយ ការបាត់បង់ស្មៅសមុទ្រ (អាហារ) និងផ្កាថ្មដែលជាជំរកត្រី។ ផលនេសាទជាមធ្យម នៅឆ្នាំ២០១៣ មានចំនួន ១,១លានតោន បើធៀបនឹងឆ្នាំ១៩៨៨មាន ចំនួន២,៧លានតោន109។ សកម្មភាពទាំងនេះ បានបង្កឲ្យមានការថយចុះត្រី និងសត្វសមុទ្រហើយបានជះឥទ្ធិពលដល់ ជីវភាពរបស់ប្រជាជនរស់ នៅតាមតំបន់ឆ្នេរ និងសេដ្ឋកិច្ចជាតិ។

ការគ្រប់គ្រងធនធានជលផលក្នុងប្រទេសកម្ពុជាត្រូវបែងចែកជា២តំបន់គឺតំបន់ថ្នាក់ណ្តាល និងតំបន់របស់រដ្ឋាភិបាល។ តំបន់ថ្នាក់កណ្តាល រដ្ឋបាលជលផល FIA នៃក្រសួងកសិកម្ម រុក្ខប្រម៉ាញ់ និងនេសាទ MAF ជាអ្នកទទួលបន្ទុកក្នុងការអភិវឌ្ឍស្រាវជ្រាវលើវិស័យជលផល និងជាអ្នកត្រួត ពិនិត្យ។ នៅក្នុងថ្នាក់មូលដ្ឋានមូលដ្ឋាន ជលផលត្រូវគ្រប់គ្រងដោយអាជ្ញាធរខេត្តក្រុងមានអំណាច ធានាការគោរពតាមច្បាប់នៅតំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន។

## ៣.៣ ធនធានធម្មជាតិផ្សេងៗ

នៅក្នុងដែនសមុទ្រកម្ពុជាមានធនធានធម្មជាតិច្រើនប្រភេទចម្រុះដោយ ដីខ្សាច់ ភក់ ថ្មច្រាំង ស្មៅសមុទ្រ ថ្មប៉ប្រះទឹក ផ្កាថ្មព្រមទាំងអណ្តើកសមុទ្រ ត្រីផ្សោត ដែលកំពុងកើនឡើងនៅក្នុងឈូង សមុទ្រ។ ដែនសមុទ្រស្ថិតនៅជាប់ឆ្នេរទឹកសាប និងទឹកប្រៃអំណោយផលឲ្យមានប្រព័ន្ធអេកូឡូស៊ី សមុទ្រដើមកោងកាង និងព្រៃជម្រាលតាមឆ្នេរ។

### ៣.៣.១ ដើមកោងកាង

ដើមកោងកាងជាផ្នែកសំខាន់នៃប្រព័ន្ធអេកូឡូស៊ីទឹកប្រៃចម្រុះនៅក្នុងតំបន់ឆ្នេរសមុទ្រដែលមាននាទីផ្តល់អាហារ និងជំរកសម្រាប់សត្វមានជីវិតរស់នៅក្នុងសមុទ្រ ពិសេសជាកន្លែងបង្កាត់ពូជ។ លើសពីនេះ ដើមកោងកាងការពារឆ្នេរពីសំណើក និងខ្យល់ព្យុះ។ ផ្អែកតាមវិទ្យាស្ថានមជ្ឈមណ្ឌល

---

[107] ហង់ ជួនណារ៉ុន, *ទស្សនាទានស្តីពីវិវាទព្រំដែនកម្ពុជា-ថៃក្នុងបរិបទនៃយុត្តិសាស្ត្រអន្តរជាតិ*(២០១៣), ១៦២។

[108] Fisheries and Aqaculture Development ចូលទស្សនាថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧www.Fao.org/Fishery/Facp/KHM/en.

[109] ហង់ ជួនណារ៉ុន, *ទស្សនាទានស្តីពីវិវាទព្រំដែនកម្ពុជា-ថៃក្នុងបរិបទនៃយុត្តិសាស្ត្រអន្តរជាតិ*(២០១៣), ២០-២១។

អភិវឌ្ឍការស្រាវជ្រាវ និងក្រសួងបរិស្ថានបានបញ្ជាក់ថា ដើមកោងកាងលាតសន្ធឹងជាច្រើនហិចតានៅខេត្តកោះកុង និងតាមបណ្តាលឆ្នេរសមុទ្រកម្ពុជាដទៃទៀត។ បន្ថែមលើសពីនេះមានការបង្ហាញថាមានសត្វសមុទ្រ ប្រមាណ៩០ប្រភេទ(ខ្លះមិនស្គាល់) រស់នៅក្នុងដើមកោងកាងតាមព្រៃពាមក្រ-សោប។

**៣.៣.២ ផ្កាថ្ម និងថ្មប៉ប្រះទឹក**

ផ្កាថ្ម និងថ្មប៉ប្រះទឹក មានស្ទើតែទាំងអស់នៅក្នុងតំបន់ជុំវិញប្រជុំកោះនៃប្រទេសកម្ពុជា ជាពិសេសនៅក្នុងបាត សមុទ្រនៃខេត្តកំពត និងចេញពីក្រុងកែបទៅតាមបណ្តោយឆ្នេរសមុទ្រទៅ ព្រំដែនវៀតណាម។ មានការប៉ាន់ប្រមាណថាតំបន់ផ្កាថ្ម និងថ្មប៉ប្រះទឹកមាន ២ ៨០៦ហិចតា (MOE2006)។ នៅក្រុងព្រះសីហនុ ផ្កាថ្មទាំងអស់មានទីតាំងនៅជុំវិញកោះភាគច្រើននៅកោះរុង និងកោះរុងសន្លឹម ដែលជាកន្លែងពេញនិយមមុជទឹកមើល ផ្កាថ្ម របស់អ្នកទេសចរណ៍។[110] ផ្កាថ្មនៅក្នុងតំបន់សមុទ្រកម្ពុជា មិនទាន់មានការស្រាវជ្រាវណាមួយជាក់លាក់ជាប្រព័ន្ធឡើយ។ ទោះបីជា យ៉ាងណាក៏មានការបង្ហាញ ថាផ្កាថ្មមាន ១៦ប្រភេទនៅតាមបណ្តាលកោះនានា។ ផ្កាថ្មបានដើរតួរយ៉ាង សំខាន់សម្រាប់ជាទីជម្រក ឬប្រជាជន នៅតាមបណ្តាយឆ្នេរអាចយកធ្វើជាវត្ថុ អនុស្សាវរីយ៍ក្នុងការផ្គត់ ផ្គង់ជីវភាព។ បន្ថែមពីនេះ ផ្កាថ្ម និងឆ្នេរសមុទ្រកម្ពុជាបានចូលក្នុងចំណោមឆ្នេរដែលស្អាតជាចំណែក លើកស្ទួយវិស័យទេសចរណ៍ជាតិ និងអន្តរជាតិ។

**៣.៣.៣ ស្មៅសមុទ្រ**

នៅក្នុងសមុទ្រកម្ពុជាមិនត្រឹមតែមានផ្កាថ្ម និងថ្មប៉ប្រះទឹកទេមានទាំងស្មៅសមុទ្រ ជាច្រើនថែមទៀត។ ស្មៅសមុទ្រនៅកម្ពុជាបានចែកជា ២ប្រភេទសំខាន់ មានវាលស្មៅសមុទ្រដុះនៅបណ្តោយ ដីគោក និងបំណះតូចៗនៃស្មៅសមុទ្រជាមួយផ្កាថ្មនៅជុំវិញកោះ។

| ធនធាន | កំពត | កោះកុង | ព្រះសីហនុ | កែប |
|---|---|---|---|---|
| ស្មៅសមុទ្រ | ២៥២៤០ហិចតា | ៣៩៩៣ហិចតា | ១៦៤ហិចតា | ៣០៩៥ហិចតា |
| ព្រៃកោងកាង | ១៩០០ហិចតា | ៦២០០០ហិចតា | ១៣៥០០ហិចតា | ១០០៥ហិចតា |

នៅកោះរុង និងកោះរុងសន្លឹមមាន ស្មៅសមុទ្រតូចៗដុះនៅបាតសមុទ្រ។ ស្មៅសមុទ្រមាននាទីជាកន្លែងសម្រាប់បន្តពូជ ឬរក្សាទុកកូន មច្ឆាតូចៗ ផ្តល់សារធាតុចញ្ចឹម អាហារសម្រាប់ត្រី បង្គា និងសត្វសមុទ្រដទៃទៀត។[111] ខេត្តកំពតជា តំបន់ស្មៅសមុទ្រធំជាងគេបំផុតនៅកម្ពុជា ហើយអាចនៅ តំបន់អាស៊ីអាគ្នេយ៍ដែលគ្រប់ដណ្តប់ ២៥ ២៤០ហិចតា។

[110]Ali Raza Rizvi and Uwe Singer, “Cambodia Coastal Situation Analysis” (IUCN Swilzerland 2011), ទំព័រ ១៣ ១៦-១៨

[111] WEPA, State of Water environment issues ចូលទស្សនាថ្ងៃទី ១៤ ខែឧសភា ឆ្នាំ២០១៧

# សេចក្តីសន្និដ្ឋាន

តាមរយៈការស្រាវជ្រាវលើប្រធានបទខាងលើស្តីពី **ដែនសមុទ្រកម្ពុជា** នេះមកយើងខ្ញុំបានយល់ឃើញថាជាជម្លោះដើម្បីដណ្តើមផលប្រយោជន៍ និងការកាន់កាប់អាស្រ័យផលទៅលើធនធានធម្មជាតិ នៅក្នុងបាតសមុទ្រ។ ជាក់ស្តែងនៅក្នុងខ្លឹមសារខាងលើនេះយើងឃើញមាន សន្ធិសញ្ញាម៉ុងតេហ្គោបៃ ស្តីពីច្បាប់សមុទ្រ។ ប៉ុន្តែដោយឡែកប្រទេសកម្ពុជាពុំទាន់បានក្លាយជាសមាជិកក្នុងសន្ធិ-សញ្ញាមួយនេះឡើយ។ ប្រទេសកម្ពុជាបានស្ថិតនៅក្រោមអាណានិគមរបស់ប្រទេសបារាំងអស់រយៈពេល ៩០ឆ្នាំ ដោយក្រោយពីអាណានិគមត្រូវបានបញ្ចប់ ប្រទេសកម្ពុជាក៏បានជួបជាមួយបញ្ហានូវការទាមទារដែនសមុទ្រមកកាន់កាប់។ ជាទូទៅរាល់បណ្តាប្រទេសទាំងអស់សុទ្ធតែមានការគិត និងចង់បាននូវការគ្រប់គ្រងដែនសមុទ្រក្នុងគោលបំណងដើម្បីប្រើប្រាស់ ក្នុងវិស័យទេសចរណ៍ក៏ដូចជា វិស័យសេដ្ឋកិច្ចជាដើម។ ហើយមហិច្ឆិតាក្នុងការចង់បាននេះហើយបានជម្រុញឲ្យប្រទេសមួយដែរ ទើបតែងើបពី សង្គ្រាមជួបជាមួយនឹងផលវិបាកដ៏ធំមួយនេះក្នុងការការពារទឹកដីរបស់ខ្លួន។ នៅក្នុងឆ្នាំ ១៩៥៧ ប្រទេសកម្ពុជាបានធ្វើការទាមទារឲ្យមានការកំណត់ខ្សែបន្ទាត់មូលដ្ឋានត្រង់របស់ ប្រទេសកម្ពុជា។ ដោយខ្សែបន្ទាត់មូលដ្ឋានត្រង់នេះបានចែកជា៣ចំណុច។ នៅក្នុងឆ្នាំ ១៩៧២ ក្រោយពី ព្រះរាជាណាចក្រកម្ពុជាបានផ្លាស់ប្តូរពីទៅជាសាធារណៈរដ្ឋខ្មែរ កម្ពុជាបានកំណត់ព្រំប្រទល់ទាំងសងខាងនៃ សមុទ្រដែនដីប្រសព្វជាមួយព្រំប្រទល់ទាំងសងខាងរបស់ខ្ពង់រាបបាតសមុទ្ររបស់កម្ពុជា។ នៅក្នុងឆ្នាំ ១៩៨២ ក្រោយពីប្រទេសកម្ពុជាបានរួចផុតពីរបបប្រល័យពូជសាសន៍។ កម្ពុជាបានធ្វើការទាមទារនូវ តំបន់សេដ្ឋកិច្ចផ្តាច់មុខ(EEZ)។ ដោយការទាមទារក្រោយពីប្រទេសកម្ពុជាបានផ្លាស់ប្តូរមុខមាត់ពីរបប កម្ពុជាប្រជាធិបតេយ្យ ទៅជាសាធារណរដ្ឋប្រជាមានិតកម្ពុជា។ នៅក្នុងក្រឹត្យច្បាប់ ដែលបានចេញនៅ ក្នុងថ្ងៃ ៣១ ខែកក្កដា ឆ្នាំ១៩៨២ នេះមានលក្ខណៈកែសម្រួលនៅខ្សែបន្ទាត់មូលដ្ឋាន។ ក៏ប៉ុន្តែក្នុងការ ទាមទានៅក្នុងឆ្នាំ១៩៨២ មានចំណុចមួយចំនួនមិនទាន់បានសម្រេច គឺនៅចំណុចខ្សែបន្ទាត់មូលដ្ឋាន ត្រង់ភ្ជាប់ប្រជុំ កោះថូជូ និងកោះពូឡូវ៉ៃ។ ក្នុងការទាមទារនូវការកំណត់ព្រំដែនសមុទ្រវាពិតជាមិនមាន ភាពងាយស្រួលក្នុងការកំណត់នោះទេ។ ប្រសិនបើយើងមើលពីតថភាពជាក់ស្តែងដែនសមុទ្រកម្ពុជាបានជាប់ជាមួយព្រំប្រទល់ប្រទេសជិតខាងដែរជាហេតុធ្វើឲ្យ ប្រទេសមួយនេះមានភាពពិបាកក្នុងការទាមទារ។ ប្រសិនបើមានការទាមទារណាមួយមិនឯកភាពនោះ ទេវាអាចឈានដល់ការប៉ះពាល់ ដល់ចំណងមិត្តភាពរបស់ប្រទេសទាំងពីរ។ ក្នុងករណីដែលមានជម្លោះរវាងប្រទេសជិតខាងក្នុងការទាមទារដែនសមុទ្រតើវាមិនភាពលំបាកអ្វីខ្លះ? ជាការពិតណាស់វា ពិតជាបានផ្តល់នូវបញ្ហាលំបាកជាច្រើន ផ្ទុយទៅវិញដោយសារតែការដឹកនាំដ៏ឈ្លាសវៃទើបរាល់ការទាមទាររបស់យើងមិនមានផលប៉ះពាល់ដល់ចំណងមិត្តភាពរបស់ប្រទេសជិតខាង។

## អនុសាសន៍

បន្ទាប់ពីបានធ្វើការស្រាវជ្រាវក្នុងប្រធានបទមួយនេះរួចមក ក្រុមរបស់យើងខ្ញុំសូមផ្តល់នូវអនុសាសន៍មួយចំនួនដើម្បីជាការពង្រឹងប្រសិទ្ធិភាព និងកែតម្រូវចំណុចខ្វះខាតមួយចំនួនរបស់ស្ថានប័នមួយនេះដើម្បីបង្កើនប្រសិទ្ធិភាពការងារ និងពង្រឹងឯករាជ្យភាពរបស់ប្រទេសខ្លួន ដែលអនុសាសន៍នោះមានដូចជា៖

- ធ្វើការកំណត់បន្ថែមនៅតាមបណ្តាព្រំដែនក្នុងតំបន់មួយចំនួនឲ្យបានច្បាស់លាស់

# ឯកសារយោង

## I. លិខិតបទដ្ឋានគតិយុត្តិអន្តរជាតិ

១. អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ ១៩៨២

២. អនុសញ្ញាស្តីពីសមុទ្រដែនដី និងតំបន់តជាប់ ១៩៥៨

## II. ក្រឹត្យច្បាប់ និងកិច្ចព្រមព្រៀង

១. ក្រឹត្យស្តីពីតំបន់សមុទ្រដែនដីនៅឥណ្ឌូចុន ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៣៦។

២. ក្រឹត្យលេខ ៦៦២ នស ស្តីពីការកំណត់ព្រំដែន សមុទ្រ ដែនដី ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ ១៩៥៧

៣. ក្រឹត្យលេខ៩៣៩-៧២/របក ស្តីពីការកំណត់ព្រំដែនខ្ពង់រាបបាតសម្រុទរបស់សាធារណៈរដ្ឋខ្មែ ចុះថ្ងៃទី ០១ខែកក្កដាឆ្នាំ១៩៧២

៤.ក្រឹត្យស្តីពីការកំណត់ព្រំដែនសមុទ្រដែនដីនៃសាធារណៈរដ្ឋខ្មែរចុះថ្ងៃទី១២ ខែសីហា

៥. ក្រឹត្យស្តីពីការកំណត់ដែនសមុទ្រ និងខ្ពង់រាបបាទសមុទ្រនៃសាធារណៈរដ្ឋប្រជាមាណិតកម្ពុជា ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៨២

៦.កិច្ចព្រមព្រៀងស្តីពីដែនទឹកប្រវត្តិសាស្ត្រនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម និងសាធារណៈរដ្ឋប្រជាមាណិតកម្ពុជា ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ១៩៨២

៧.សេចក្តីប្រកាសរបស់រដ្ឋាភិបាលទាក់ទងនឹងសមុទ្រដែនដី និងខ្ពង់រាបបាទសមុទ្ររបស់កម្ពុជា ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៩៨

## III. សៀវភៅ


១.គណម្មាធិការព្រំដែនកម្ពុជា. ២០០០. ព្រំដែនដី និងសមុទ្រប្រទេសកម្ពុជា ។

២. លោកបណ្ឌិត ហាង់ ជួន ណារ៉ុង . ២០១៣. ទស្សនាទាននស្តីពីវិវាទ ព្រំដែនសមុទ្រកម្ពុជា និងថៃក្នុងបិរបទយុត្តិសាស្ត្រអន្តរជាតិ

៣. លោកសាស្ត្រាចារ្យ អ៊ឹង រដ្ឋា . ច្បាប់សមុទ្រអន្តរជាតិ។

៤. លោកសាស្ត្រាចារ្យ យឹម ឈុន អ៊ី ២០០២. ច្បាប់សមុទ្រ។

៥. Bernaert, Arnd. 2005. Bernaert′s Guide to the 1982 United Nation Convention on Law of the Sea។ ៦. Howard, Clive. 1999. Maritime Boundaries Delimitation in the Gulf of Thailand. Durham University។

៧. លោកនួន សួធិមន. ២០០២. នីតិសមុទ្រ សមុទ្រ លំហាសមុទ្រ និងខ្ពង់រាបបាតសមុទ្រ. បណ្ណាគារអង្គរ។


## IV. អត្ថបទនិក្ខេបបទ


១.សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ២០១២. អត្ថបទគោលរបស់ហ៊ុន សែន សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាច្រកកមុជា ស្រមាប់អធិប្បាយ ផ្ទាល់ពី ការបំភ្លឺ ការងារបោះបង្គោលខណ្ឌសីមាព្រំដែនគាក និងការកំណត់ព្រំដែនសមុទ្រនៃព្រះរាជាណា ចក្រកម្ពុជា និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម។

២. Ciptadi និង Windra, Andromedo. 2016. Sailing the calm and rough seas: The Influence of the Wealth and Sovereignty in Southeast ASEAN Maritime Dispute. The NPS Institution Aichive។ ៣. Abraham-

som, Jonh Topham. 2015. Joint Development of Offshore Polar oil and Gas resource and the United Nation Convention on Law of the Sea. ANU College of Law។

៤. Raza, Ali និង Singer, Uwe. 2011. Cambodia Coastal Situation Analysis. Switzerland:

IUCN។ ៥. Ravin, Mom. 2005. Law of the Sea Maritime Boundaries and Dispute Settlement Mechanism ។ ៦. Bardin, Anne. 2002. Coastal State's Jurisdiction over Foreign Vessels, Peace International Law review។ ៧. Jinangkung, Amrih. Maritime Boundary Disputes Among ASEAN Member countries ៨. James Doyle, Larry. 2010. Continental Margin។

## V. ប្រភពគេហទំព័រ

១. កំពង់ផែសមុទ្រក្រុមប្រឹក្សាគណកម្មាធិការវិនិយោគកម្ពុជាតំបន់សេដ្ឋកិច្ចពិសេស ដែលអាចរកបាននៅ http://www.cambodiainvestment.gov.kh/investors-information/infrastructure/sea-port.html

២. Fisheries and Agriculture Department. Food and Agriculture Organization of the United Nations ដែលអាចរកបាននៅ http://www.fao.org/fishery/facp/KHM/en

៣.ភាគហ៊ុនកំពង់ផែព្រះសីហនុដែលបានដាល់លក់ជាផ្លូវការ ដែលអាចរកបាននៅhttp://kampucheathmey.com/2016/archives/639158

៤. Global security.org ដែលអាចរកបាននៅwww.globalsecurity.org/military/world/cambodia/history-france-htm

៥. Port in Cambodia ដែលអាចរកបាននៅ http://www.business-in-asia.com/cambodia/cambodia_ports.html ៦. WEPA. State of Water environment issue ដែលអាចរកបាននៅ

http://www.wepa-db.net/policies/state/cambodia/seaarea3_9.htm

៧. Khmer Time. 2015. Chinese Investors focusing on Sihanoukville port ដែលអាចរកបាននៅ

http://www.khmertimeskh.com/news/17010/chinese-investors-focusing-on-shihanoukville-port/

៨. OpenDevelopment Cambodia. 2016. Oil and Gas resource ដែលអាចរកបាននៅ

https://opendevelopmentcambodia.net/topics/oil-and-gas-resources/

៩. OpenDevelopment Cambodia. 2016. Oil and Gas Block ដែលអាចរកបាននៅ https://opendevelopmentcambodia.net/profiles/oil-and-gas-blocks

១០. OpenDevelopment Cambodia. 2015. Off-shore oil and gas block ដែលអាចរកបាននៅ

https://opendevelopmentcambodia.net/topics/off-shore-oil-and-gas-exploration-and-extraction/

## VI. ប្រភពអ៊ីនធើណេត

១. http://www.jag.navy.mil/organization/documents/mcrm/Cambodia2016.pdf

២. http://www.offshoreenergytoday.com/mirach-energy-partners-with-landocean-in-cambodia- offshore-block-d/

៣. http://khmerization.blogspot.com/2011/08/

៤. http://processoilgas.blogspot.com/2012/01/cambodia-oil-and-gas-industry.html

៥. http://www.quickgs.com/major-straits-of-world/

# ឧបសម្ព័ន្ធ

# ផែនទី នៃការទាមទាររបស់កម្ពុជា




រូបទី ១ ការទាមទារខ្សែបន្ទាត់មូលដ្ឋានត្រង់កម្ពុជា១៩៥៧

ប្រភព Clive Howerd , Maritime Boundary Delimitation in the Gulf of Tailand from Durham University , 1999




រូប២ ការទាមទារខ្សែបន្ទាត់តំបន់ខ្ពងរាបបាតសមុទ្រ




រូប៣ ការទាមទារខ្សែបន្ទាត់មូលដ្ឋានត្រង់កម្ពុជាក្នុងឆ្នាំ១៩៧២




រូប៤ ការទាមទារខ្សែបន្ទាត់មូលដ្ឋានត្រង់កម្ពុជាក្នុងឆ្នាំ១៩៨២ និង ការទាមទារខ្សែបន្ទាត់មូលដ្ឋានត្រង់វៀតណាមក្នុងឈូងសមុទ្រថៃ

# លំហសមុទ្ររបស់រដ្ឋមើលពីលើអាកាស



# ឆក និង បន្ទាត់គ្រង់






## ៣៥ River-mouth



# តំបន់ប្លុកប្រេងភាគក្នុងឈូងសមុទ្រថៃ



# តំបន់ត្រួតស៊ីគ្នា


THAILAND
CAMBODIA
Gulf of Thailand
crude & gas reserve
VIETNAM
Cambodia's claims limit
Thailand's claims limit
MALAYSIA
Sourse: Bangkok Post


Block E
Block F
Block C
Block A
(Chevron)
Block B
Approximate Extent
of Khmer Trough

dangerous or noxious substances . . . 29
Article 24. Duties of the coastal State . . . 29
Article 25. Rights of protection of the coastal State . . . 29
Article 26. Charges which may be levied upon foreign ships . . 29
SUBSECTION B. RULES APPLICABLE TO MERCHANT SHIPS AND GOVERNMENT SHIPS OPERATED FOR COMMERCIAL PURPOSES . . . 30
Article 27. Criminal jurisdiction on board a foreign ship . . . 30
Article 28. Civil jurisdiction in relation to foreign ships . . . 30
SUBSECTION C. RULES APPLICABLE TO WARSHIPS AND OTHER GOVERNMENT SHIPS OPERATED FOR NON-COMMERCIAL PURPOSES . . . 31
Article 29. Definition of warships . . . 31
Article 30. Non-compliance by warships with the laws and regulations of the coastal State . . . 31
Article 31. Responsibility of the flag State for damage caused by a warship or other government ship operated for non-commercial purposes . . . 31
Article 32. Immunities of warships and other government ships operated for non-commercial purposes . . . 31
SECTION 4. CONTIGUOUS ZONE . . . 31
Article 33. Contiguous zone . . . 31

PART III. STRAITS USED FOR INTERNATIONAL NAVIGATION . . . 32

SECTION 1. GENERAL PROVISIONS . . . 32
Article 34. Legal status of waters forming straits used for international navigation . . . 32
Article 35. Scope of this Part . . . 32
Article 36. High seas routes or routes through exclusive economic zones through straits used for international navigation . . . 32
SECTION 2. TRANSIT PASSAGE . . . 33
Article 37. Scope of this section . . . 33
Article 38. Right of transit passage . . . 33
Article 39. Duties of ships and aircraft during transit passage . . 33
Article 40. Research and survey activities . . . 34
Article 41. Sea lanes and traffic separation schemes in straits

| | | | |
|---|---|---|---|
| | | used for international navigation | 34 |
| | Article 42. | Laws and regulations of States bordering straits relating to transit passage | 35 |
| | Article 43. | Navigational and safety aids and other improvements and the prevention, reduction and control of pollution | 35 |
| | Article 44. | Duties of States bordering straits | 35 |
| SECTION 3. | INNOCENT PASSAGE | | 36 |
| | Article 45. | Innocent passage | 36 |
| PART IV. | ARCHIPELAGIC STATES | | 36 |
| | Article 46. | Use of terms | 36 |
| | Article 47. | Archipelagic baselines | 36 |
| | Article 48. | Measurement of the breadth of the territorial sea, the contiguous zone, the exclusive economic zone and the continental shelf | 37 |
| | Article 49. | Legal status of archipelagic waters, of the air space over archipelagic waters and of their bed and subsoil | 37 |
| | Article 50. | Delimitation of internal waters | 37 |
| | Article 51. | Existing agreements, traditional fishing rights and existing submarine cables | 38 |
| | Article 52. | Right of innocent passage | 38 |
| | Article 53. | Right of archipelagic sea lanes passage | 38 |
| | Article 54. | Duties of ships and aircraft during their passage, research and survey activities, duties of the archipelagic State and laws and regulations of the archipelagic State relating to archipelagic sea lanes passage | 39 |
| PART V. | EXCLUSIVE ECONOMIC ZONE | | 40 |
| | Article 55. | Specific legal regime of the exclusive economic zone | 40 |
| | Article 56. | Rights, jurisdiction and duties of the coastal State in the exclusive economic zone | 40 |
| | Article 57. | Breadth of the exclusive economic zone | 40 |

| | | |
|---|---|---|
| Article 58. | Rights and duties of other States in the exclusive economic zone | 40 |
| Article 59. | Basis for the resolution of conflicts regarding the attribution of rights and jurisdiction in the exclusive economic zone | 41 |
| Article 60. | Artificial islands, installations and structures in the exclusive economic zone | 41 |
| Article 61. | Conservation of the living resources | 42 |
| Article 62. | Utilization of the living resources | 43 |
| Article 63. | Stocks occurring within the exclusive economic zones of two or more coastal States or both within the exclusive economic zone and in an area beyond and adjacent to it | 44 |
| Article 64. | Highly migratory species | 44 |
| Article 65. | Marine mammals | 44 |
| Article 66. | Anadromous stocks | 45 |
| Article 67. | Catadromous species | 45 |
| Article 68. | Sedentary species | 46 |
| Article 69. | Right of land-locked States | 46 |
| Article 70. | Right of geographically disadvantaged States | 47 |
| Article 71. | Non-applicability of articles 69 and 70 | 48 |
| Article 72. | Restrictions on transfer of rights | 48 |
| Article 73. | Enforcement of laws and regulations of the coastal State | 48 |
| Article 74. | Delimitation of the exclusive economic zone between States with opposite or adjacent coasts | 49 |
| Article 75. | Charts and lists of geographical coordinates | 49 |
| PART VI. | CONTINENTAL SHELF | 49 |
| Article 76. | Definition of the continental shelf | 49 |
| Article 77. | Rights of the coastal State over the continental shelf | 51 |
| Article 78. | Legal status of the superjacent waters and air space and the rights and freedoms of other States | 51 |
| Article 79. | Submarine cables and pipelines on the continental shelf | 51 |

Article 80. Artificial islands, installations and structures on the continental shelf . . . . . 52
Article 81. Drilling on the continental shelf . . . . . 52
Article 82. Payments and contributions with respect to the exploitation of the continental shelf beyond 200 nautical miles . . . . . 52
Article 83. Delimitation of the continental shelf between States with opposite or adjacent coasts . . . . . 52
Article 84. Charts and lists of geographical coordinates . . . . . 53
Article 85. Tunnelling . . . . . 53

PART VII. HIGH SEAS . . . . . 53

SECTION 1. GENERAL PROVISIONS . . . . . 53
Article 86. Application of the provisions of this Part . . . . . 53
Article 87. Freedom of the high seas . . . . . 53
Article 88. Reservation of the high seas for peaceful purposes . . . . . 54
Article 89. Invalidity of claims of sovereignty over the high seas . . . . . 54
Article 90. Right of navigation . . . . . 54
Article 91. Nationality of ships . . . . . 54
Article 92. Status of ships . . . . . 54
Article 93. Ships flying the flag of the United Nations, its specialized agencies and the International Atomic Energy Agency . . . . . 55
Article 94. Duties of the flag State . . . . . 55
Article 95. Immunity of warships on the high seas . . . . . 56
Article 96. Immunity of ships used only on government non-commercial service . . . . . 56
Article 97. Penal jurisdiction in matters of collision or any other incident of navigation . . . . . 56
Article 98. Duty to render assistance . . . . . 56
Article 99. Prohibition of the transport of slaves . . . . . 57
Article 100. Duty to cooperate in the repression of piracy . . . . . 57
Article 101. Definition of piracy . . . . . 57
Article 102. Piracy by a warship, government ship or government aircraft whose crew has mutinied . . . . . 58
Article 103. Definition of a pirate ship or aircraft . . . . . 58

# Convention on the Territorial Sea and the Contiguous Zone 1958

Done at Geneva on 29 April 1958. Entered into force on 10 September 1964. United Nations, Treaty Series, vol. 516, p. 205.

Copyright © United Nations

2005

Convention on the Territorial Sea and the Contiguous Zone Done at Geneva on 29 April 1958

The States Parties to this Convention Have agreed as follows:

PART I. TERRITORIAL SEA

SECTION I. GENERAL

Article 1

1. The sovereignty of a State extends, beyond its land territory and its internal waters, to a belt of sea adjacent to its coast, described as the territorial sea.

2. This sovereignty is exercised subject to the provisions of these articles and to other rules of international law.

Article 2

The sovereignty of a coastal State extends to the air space over the territorial sea as well as to its bed and subsoil.

SECTION II. LIMITS OF THE TERRITORIAL SEA

Article 3

Except where otherwise provided in these articles, the normal baseline for measuring the breadth of the territorial sea is the low-water line along the coast as marked on large-scale charts officially recognized by the coastal State.

Article 4

1.In localities where the coastline is deeply indented and cut into, or if there is a fringe of islands along the coast in its immediate vicinity, the method of straight baselines joining appropriate points may be employed in drawing the baseline from which the breadth of the territorial sea is measured.

2.The drawing of such baselines must not depart to any appreciable extent from the general direction of the coast, and the sea areas lying within the lines must be

sufficiently closely linked to the land domain to be subject to the regime of internal waters.

2

3.Baselines shall not be drawn to and from low-tide elevations, unless lighthouses or similar installations which are permanently above sea level have been built on them.

4.Where the method of straight baselines is applicable under the provisions of paragraph 1, account may be taken, in determining particular baselines, of economic interests peculiar to the region concerned, the reality and the importance of which are clearly evidenced by a long usage.

5.The system of straight baselines may not be applied by a State in such a manner as to cut off from the high seas the territorial sea of another State.

6.The coastal State must clearly indicate straight baselines on charts, to which due publicity must be given.

Article 5

1.Waters on the landward side of the baseline of the territorial sea form part of the internal waters of the State.

2.Where the establishment of a straight baseline in accordance with article 4 has the effect of enclosing as internal waters areas which previously had been considered as part of the territorial sea or of the high seas, a right of innocent passage, as provided in articles 14 to 23, shall exist in those waters.

Article 6

The outer limit of the territorial sea is the line every point of which is at a distance from the nearest point of the baseline equal to the breadth of the territorial sea.

Article 7

1.This article relates only to bays the coasts of which belong to a single State.

2.For the purposes of these articles, a bay is a well-marked indentation whose penetration is in such proportion to the width of its mouth as to contain land-locked waters and constitute more than a mere curvature of the coast. An indentation shall not,

however, be regarded as a bay unless its area is as large as, or larger than, that of the semicircle whose diameter is a line drawn across the mouth of that indentation.

3.For the purpose of measurement, the area of an indentation is that lying between the low-water mark around the shore of the indentation and a line joining the low-water marks of its natural entrance points. Where, because of the presence of islands, an indentation has more than one mouth, the semicircle shall be drawn on a line as long as the sum total of the lengths of the lines across the different mouths. Islands within an indentation shall be

included as if they were part of the water areas of the indentation.

3

4.If the distance between the low-water marks of the natural entrance points of a bay does not exceed twenty-four miles, a closing line may be drawn between these two low-water marks, and the waters enclosed thereby shall be considered as internal waters.

5.Where the distance between the low-water marks of the natural entrance points of a bay exceed twenty-four miles, a straight baseline of twenty-four miles shall be drawn within the bay in such a manner as to enclose the maximum area of water that is possible with a line of that length.

6.The foregoing provisions shall not apply to so-called "historic" bays, or in any case where the straight baseline system provided for in article 4 is applied.

Article 8

For the purpose of delimiting the territorial sea, the outermost permanent harbour works which form an integral part of the harbour system shall be regarded as forming part of the coast.

Article 9

Roadsteads which are normally used for the loading, unloading and anchoring of ships, and which would otherwise be situated wholly or partly outside the outer limit of the territorial sea, are included in the territorial sea. The coastal State must clearly

demarcate such roadsteads and indicate them on charts together with their boundaries, to which due publicity must be given.

Article 10

1.An island is a naturally formed area of land, surrounded by water, which is above water at high tide.

2.The territorial sea of an island is measured in accordance with the provisions of these articles.

Article 11

1.A low-tide elevation is a naturally formed area of land which is surrounded by and above water at low tide but submerged at high tide. Where a low-tide elevation is situated wholly or partly at a distance not exceeding the breadth of the territorial sea from the mainland or an island, the low-water line on that elevation may be used as the baseline for measuring the breadth of the territorial sea.

2.Where a low-tide elevation is wholly situated at a distance exceeding the breadth of the territorial sea from the mainland or an island, it has no territorial sea of its own.

Article 12

1.Where the coasts of two States are opposite or adjacent to each other, neither of the two States is entitled, failing agreement between them to the contrary, to extend its territorial sea beyond the median line every point of which is equidistant from the nearest points on the baselines from which the breadth of the territorial seas of each of the two States is measured. The provisions of this paragraph

shall not apply, however, where it is necessary by reason of historic title or other special circumstances to delimit the territorial seas of the two States in a way which is at variance with this provision.

2.The line of delimitation between the territorial seas of two States lying opposite to each other or adjacent to each other shall be marked on large-scale charts officially recognized by the coastal States.

Article 13

If a river flows directly into the sea, the baseline shall be a straight line across the mouth of the river between points on the low-tide line of its banks.

## SECTION III. RIGHT OF INNOCENT PASSAGE

### Subsection A. Rules applicable to all ships

### Article 14

1.Subject to the provisions of these articles, ships of all States, whether coastal or not, shall enjoy the right of innocent passage through the territorial sea.

2.Passage means navigation through the territorial sea for the purpose either of traversing that sea without entering internal waters, or of proceeding to internal waters, or of making for the high seas from internal waters.

3.Passage includes stopping and anchoring, but only insofar as the same are incidental to ordinary navigation or are rendered necessary by force majeure or by distress.

4.Passage is innocent so long as it is not prejudicial to the peace, good order or security of the coastal State. Such passage shall take place in conformity with these articles and with other rules of international law.

5.Passage of foreign fishing vessels shall not be considered innocent if they do not observe such laws and regulations as the coastal State may make and publish in order to prevent these vessels from fishing in the territorial sea.

6.Submarines are required to navigate on the surface and to show their flag.

### Article 15

1.The coastal State must not hamper innocent passage through the territorial sea.

2.The coastal State is required to give appropriate publicity to any dangers to navigation, of which it has knowledge, within its territorial sea.